លឹម ផល្គុន និង សែន ពិសិដ្ឋ
បរិញ្ញាបត្រផ្នែក គណិតវិទ្យា

# កំណែលំហាត់

# គណិតវិទ្យា

## កំរិតខ្ពស់

## ១២



ស្របតាមកម្មវិធីសិក្សាថ្មី

លឹម ផល្គុន និង សែន ពិសិដ្ឋ
បរិញ្ញាបត្រផ្នែក គណិតវិទ្យា

# កំណែលំហាត់

# គណិតវិទ្យា

## កំរិតខ្ពស់

## ១២




ស្របតាមកម្មវិធីសិក្សាថ្មី

# គណៈកម្មការនិពន្ធ និង រៀបរៀង

លោក លឹម ផល្គុន

លោក សែន ពិសិដ្ឋ

# គណៈកម្មការត្រួតពិនិត្យបច្ចេកទេស

| | |
|---|---|
| លោក លឹម ឆុន | លោក អ៊ឹង សំណាង |
| លោកស្រី ទុយ រីណា | លោក ទិត្យ ម៉េង |
| លោក នន់ សុខណា | លោក ព្រឹម សុនិត្យ |

# គណៈកម្មការត្រួតពិន្យអក្ខរាវិរុទ្ធ

លោក លឹម មិគ្គសិរ

| ការិយកុំព្យូទ័រ | រចនាទំព័រ និង ក្រប |
|---|---|
| លោក អ៊ឹង សំណាង | លោក ព្រំ ម៉ាឡា |
| កញ្ញា លី គុណ្ណាកា | |

# អារម្ភកថា

សួស្តីមិត្តអ្នកសិក្សា ជាទីមេត្រី !!

សៀវភៅ កំណែលំហាត់គណិតវិទ្យាថ្នាក់ទី12 កំរិតខ្ពស់ដែលយើងខ្ញុំបាន រៀបរៀងនេះ រួមមានប្រាំជំពូកធំៗ ដែលបានដកស្រង់ចេញពីសៀវភៅគណិតវិទ្យា ថ្នាក់ទី១២កំរិតខ្ពស់ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

ក្នុងជំពូកនីមួយៗយើងខ្ញុំបានសង្ខេបមេរៀន និង ដកស្រង់លំហាត់ក្នុងមេរៀននៃជំពូក នីមួយៗមកធ្វើដំណោះស្រាយយ៉ាងក្បោះក្បាយ ដែលអាចជាជំនួយស្មារតីដល់អ្នកសិក្សា ក្នុងគ្រប់មជ្ឈដ្ឋាន ។

ទោះជាយ៉ាងណាក៏ដោយ ការបកស្រាយនូវរាល់លំហាត់ក្នុងសៀវភៅ នេះវាមិនល្អហួសគេហួសឯង ទាំងស្រុងនោះទេ ។

កំហុសឆ្គងនានា ទាំងបច្ចេកទេស និង អក្ខរាវិរុទ្ធប្រាកដជាកើតមានដោយអចេតនា ពុំខានឡើយ អាស្រ័យហេតុនេះ យើងខ្ញុំរង់ចាំជានិច្ចនូវមតិរិះគន់បែបស្ថាបនាពីសំណាក់ អ្នកសិក្សាក្នុងគ្រប់មជ្ឈដ្ឋាន ដើម្បីកែតម្រូវសៀវភៅនេះឱ្យកាន់តែមានសុក្រិត្យភាព ថែមទៀត ។

ជាទីបញ្ចប់ យើងខ្ញុំអ្នករៀបរៀង សូមជូនពរដល់អ្នកសិក្សាទាំងអស់ ទទួលបានជោគជ័យក្នុងជីវិត និង មានសុខភាពល្អ ។

បាត់ដំបងថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១០

អ្នករៀបរៀង **លឹម ផល្គុន**

# មាតិការឿង

ទំព័រ

**ជំពូកទី១**

លីមីតនៃស្ទីត 01

**ជំពូកទី២**

អនុវត្តន៍ដេរីវេនៃអនុគមន៍ ២៧

**ជំពូកទី៣**

មេរៀនទី១ អនុគមន៍ អសនិទាន ៥៣

មេរៀនទី២ អនុគមន៍ត្រីកោណមាត្រចម្រុះ ៦៥

**ជំពូកទី៤**

មេរៀនទី១ អាំងតេក្រាលកំណត់ ៨៣

មេរៀនទី២ មាឌសូលីដ និង ប្រវែងធ្នូ ៩៦

**ជំពូកទី៥**

មេរៀនទី១ សមីការឌីផេរ៉ង់ស្យែលលំដាប់ទី១ ១១៥

មេរៀនទី២ សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី២ ១៣៦

# ជំពូកទី១

## មេរៀនសង្ខេប លីមីតនៃស្វ៊ីត

◆ ប្រមាណវិធីលើលីមីត

គេមានស្វ៊ីត $(a_n)$ និង $(b_n)$ ដែលមាន $\lim\limits_{n\to+\infty} a_n = M$

និង $\lim\limits_{n\to+\infty} b_n = N$ គេបាន

ក. $\lim\limits_{n\to+\infty} ka_n = k.M$

ខ. $\lim\limits_{n\to+\infty}(a_n + b_n) = M + N$ , $\lim\limits_{n\to+\infty}(a_n - b_n) = M - N$

គ. $\lim\limits_{n\to+\infty}(a_n b_n) = M.N$

បើ $N \neq 0$ នោះ $\lim\limits_{n\to+\infty} \frac{a_n}{b_n} = \frac{M}{N}$

◆ លីមីតស្វ៊ីតធរណីមាត្រអនន្ត

ក.បើ $r > 1$ នោះ $\lim\limits_{n\to+\infty} r^n = +\infty$ ហើយ $r^n$ ជាស្វ៊ីតរីកទៅរក $+\infty$

ខ.បើ $r = 1$ នោះ $(r^n)$ ជាស្វ៊ីតថេរហើយ $\lim\limits_{n\to+\infty} r^n = 1$ ។

គ.បើ $r = 0$ នោះ $(r^n)$ ជាស្វ៊ីតថេរហើយ $\lim\limits_{n\to+\infty} r^n = 0$ ។

ឃ.បើ $r \leq -1$ នោះស្វ៊ី $(r^n)$ ជាស្វ៊ីតឆ្លាស់ ហើយកាលណា $n \to +\infty$

គេមិនអាចកំណត់លីមីតនៃ $(r^n)$ បានទេ ។

◆ ស៊ីតធរណីមាត្រអនន្តដែលរួម :

ស៊ីត $(r^n)$ សមមូល $-1 \le r \le 1$

◆ ស៊េរីរួម និង ស៊េរីរីក :

ក-បើស៊េរី $\sum_{n=1}^{\infty}(a_n)$ ជាស៊េរីរួមនោះ $\lim_{n\to+\infty} a_n = 0$

ខ-បើស៊ីត $(a_n)$ មិនរួមរក 0 ទេនោះ $\sum_{n=1}^{\infty}(a_n)$ ជាស៊េរីរីក ។

◆ ភាពរួមនិងរីកនៃស៊េរីធរណីមាត្រអនន្ត :

គ្រប់ស៊េរីធរណីមាត្រអនន្ត $a + ar + ar^2 + ar^3 + .... + ar^{n-1} + ...$

ដែល $a \ne 0$ ជាស៊េរីរួម ឬ រីកទៅតាមករណីដូចខាងក្រោម :

ក-បើ $|r| < 1$ នោះស៊េរីរួមទៅរក $\frac{a}{1-r}$ ។

ខ-បើ $|r| \ge 1$ នោះស៊េរីរីក ។

## លំហាត់

1.តើស្វ៊ីត $(U_n)$ ដែលមានតួទូទៅដូចខាងក្រោម ជាស្វ៊ីតរួម ឬ រីក ?

ក. $U_n = 3n^2 + 5n + 1$

ខ. $U_n = \dfrac{n^2 + n}{2n^2 + 5}$

គ. $U_n = \dfrac{\sin 2n}{5^n}$

ឃ. $U_n = \dfrac{2n}{n+3} + \dfrac{3n^3}{n^2 + 5}$

ង. $U_n = \dfrac{n \sin n}{n^2 + 1}$

ច. $U_n = 2 - \dfrac{3}{n} + \dfrac{4}{\sqrt{n}}$

2.គណនាលីមីតនៃស្វ៊ីតខាងក្រោម

ក. $\lim\limits_{n\to+\infty} \dfrac{n^2 + 3n - 1}{8n^2 - n + 1}$

ខ. $\lim\limits_{n\to+\infty} \dfrac{5n^3 + n^2 - n}{n^2 + n - 1}$

គ. $\lim\limits_{n\to+\infty} \dfrac{5n^3 + (-1)^n}{n + (-1)^n}$

ឃ. $\lim\limits_{n\to+\infty} \dfrac{n^2 + \sin n}{5n^2 + \cos \pi n}$

ង. $\lim\limits_{n\to+\infty} (n^2 - \cos^2 \pi n)$

ច. $\lim\limits_{n\to+\infty} \left[-5n^3 + (-1)^n n^3\right]$

3. គណនាលីមីតនៃស្វ៊ីតខាងក្រោម

ក. $\lim\limits_{n\to+\infty} \left(\sqrt{n+1} - \sqrt{n}\right)$

ខ. $\lim\limits_{n\to+\infty} \sqrt{n}\left(\sqrt{n-3} - \sqrt{n}\right)$

គ. $\lim\limits_{n\to+\infty} \left(n\sqrt{n^2 + 1} - 1\right)$

ឃ. $\lim\limits_{n\to+\infty} \left(\dfrac{n!}{(n+1)! - n!} - \dfrac{2}{n} + 3\right)$ ។

4.គេមានស្វ៊ីតដែលកំនត់ចំពោះគ្រប់ $n \in IN$ មានតួទូទៅដូចខាងក្រោម៖

$$U_n = \frac{n^3}{2^n} \text{ , } V_n = \frac{2^n}{n!} \text{ ដែល } n! = n(n-1)\times\ldots\times 1$$

ក.គណនា $\lim_{n\to+\infty} \frac{U_{n+1}}{U_n}$ និង $\lim_{n\to+\infty} \frac{V_{n+1}}{V_n}$

ខ.គណនា $\lim_{n\to+\infty} \frac{2^n + n^3}{n!+n^3}$

5.គណនាលីមីតនៃស្វ៊ីត $(a_n)$ ដែលគេស្គាល់តួដូចខាងក្រោម៖

ក.$a_1 = 2 \quad , \quad a_{n+1} = \frac{1}{2}a_n + 3$

ខ.$a_1 = 3 \quad , \quad a_{n+1} = 2a_n - 5$

គ.$a_1 = 1 \quad , \quad a_{n+1} = \frac{1}{3}a_n + \frac{4}{3}$ ។

6.ពិនិត្យស៊េរីខាងក្រោមនេះ តើជាស៊េរីរីក រឺ រួម?

ក.$\sum_{n=0}^{\infty} 3.\left(\frac{3}{2}\right)^n$

ខ.$\sum_{n=0}^{\infty} 1000(1.055)^n$

គ.$\sum_{n=1}^{\infty} \frac{n+\sqrt{n}}{2n^3-1}$

ឃ.$\sum_{n=1}^{\infty} \frac{2^n+1}{2^{n-1}}$

ង.$2 + \frac{3}{2} + \frac{9}{8} + \frac{27}{32} + \frac{81}{128}\ldots$

ច.$\sum_{n=1}^{\infty} \left(\sqrt{2n+1} - \sqrt{2n-1}\right)$

7.រកផលបូកនៃស៊េរីខាងក្រោម៖

ក.$1+0.1+0.01+0.001+...$

ខ.$\sum_{n=1}^{\infty}\frac{2}{4n^2-1}$

គ.$\sum_{n=1}^{\infty}\frac{1}{(2n-1)(2n+1)}$

ឃ.$\sum_{n=0}^{\infty}2\left(\cos\frac{\pi}{3}\right)^n$

ង.$\sum_{n=1}^{\infty}\frac{5(-1)^n}{4^n}$

ច.$\frac{2}{3}+\left(\frac{2}{3}\right)^2+\left(\frac{2}{3}\right)^3+...$

8.គណនា

ក. $\lim_{n\to+\infty}\left(1-\frac{1}{2^2}\right)...\left(1-\frac{1}{n^2}\right)$

ខ. $\lim_{n\to+\infty}\left(\frac{n}{\sqrt{n^4+1}}+\frac{n}{\sqrt{n^4+2}}+...+\frac{n}{\sqrt{n^4+n}}\right)$

12.គណនា

$$\lim_{n\to+\infty}\left[(q-1)+q^2(q^2-q)+...+q^{2(n-1)}(q^n-q^{n-1})\right]$$

ដែល $q=2^{\frac{1}{2}}$ ។

9. គេឱ្យស្វ៊ីត $(a_n)$ កំណត់ដោយ $a_n=\frac{1}{2+q^n}$ ដែល $q\neq-1$ ។

សិក្សាលីមីតនៃស្វ៊ីត $(a_n)$ កាលណា $n\to+\infty$ ។

10.ចំពោះគ្រប់ $n\in IN$ គេមាន

$$S_n=\frac{2}{1\times3}+\frac{2}{3\times5}+...+\frac{2}{(2n-1)(2n+1)}=\sum_{p=0}^{n}\frac{2}{(2p+1)(2p+3)}$$

ក.គណនា $S_n$ ជាអនុគមន៍នៃ n ដោយប្រើ $\frac{2}{(2p+1)(2p+3)}$ ជាទម្រង់ $\frac{a}{(2p+1)}+\frac{b}{(2p+3)}$ ។

ខ.គណនា $\lim\limits_{n\to+\infty} S_n$ ។

11.គេមានស៊េរីអនន្តមួយ

$r^2+\frac{r^2}{r^2+1}+\frac{r^2}{(r^2+1)^2}+...+\frac{r^2}{(r^2+1)^{n-1}}+...$ បង្ហាញថាស៊េរីអនន្ត នោះរួមចំពោះគ្រប់តម្លៃ r ។

12.កំណត់ស៊េរីខាងក្រោម តើស៊េរីមួយណារួម មួយណារីក? បើជាស៊េរីរួម

ចូររកផលបូក ។

ក.$\sum\limits_{n=1}^{\infty} 2\left(\cos\frac{\pi}{3}\right)^n$ ខ.$\sum\limits_{n=1}^{\infty}\left(\tan\frac{\pi}{4}\right)^n$

គ.$\sum\limits_{n=1}^{\infty}\frac{n}{2n+5}$ ឃ.$\sum\limits_{n=1}^{\infty}\frac{5(-1)^n}{4^n}$ ។

17.គេមាន $\Delta ABC$ មួយមានក្រលាផ្ទៃស្មើនឹង 6 ឯកតា។

សង់$\Delta A'B'C'$ ដោយ $A'$, $B'$ និង $C'$ ជាចំនុចកណ្តាលនៃជ្រុង ។

ចូរកំណត់ផលបូក $S = S_1 + S_2 + S_3 + ...$ ។

## ដំណោះស្រាយ

1. តើស្វ៊ីត $(U_n)$ ដែលមានតួទូទៅដូចខាងក្រោម ជាស្វ៊ីតរួម ឬ រីក ?

ក. $U_n = 3n^2 + 5n + 1$

ខ. $U_n = \dfrac{n^2 + n}{2n^2 + 5}$

គ. $U_n = \dfrac{\sin 2n}{5^n}$

ឃ. $U_n = \dfrac{2n}{n+3} + \dfrac{3n^3}{n^2+5}$

ង. $U_n = \dfrac{n \sin n}{n^2 + 1}$

ច. $U_n = 2 - \dfrac{3}{n} + \dfrac{4}{\sqrt{n}}$

### ដំណោះស្រាយ

សិក្សាភាពរួម ឬ រីកនៃស្វ៊ីត

ក. $U_n = 3n^2 + 5n + 1$

គេមាន $\lim\limits_{n\to+\infty} U_n = \lim\limits_{n\to+\infty}(3n^2 + 5n + 1)$

$$= \lim_{n\to+\infty}\left[n^2\left(3 + \frac{5}{n} + \frac{1}{n^2}\right)\right]$$

$$= \lim_{n\to+\infty}(3n^2) = +\infty$$

ដូចនេះ $(U_n)$ ជាស្វ៊ីតរីកខិតទៅរក $+\infty$ ។

ខ. $U_n = \dfrac{n^2 + n}{2n^2 + 5}$

គេមាន $\lim\limits_{n\to+\infty} U_n = \lim\limits_{n\to+\infty} \dfrac{n^2 + n}{2n^2 + 5} = \lim\limits_{n\to+\infty} \dfrac{n^2}{2n^2} = \dfrac{1}{2}$

ដូចនេះ $(U_n)$ ជាស្វ៊ីតរួមខិតទៅរក $\frac{1}{2}$ ។

គ.$U_n = \frac{\sin 2n}{5^n}$

គេមាន $-1 \le \sin 2n \le 1$ នាំឱ្យ $-\frac{1}{5^n} \le U_n \le \frac{1}{5^n}$

ដោយ $\lim_{n\to+\infty} \frac{1}{5^n} = 0$ នោះ $\lim_{n\to+\infty} U_n = 0$ ។

ដូចនេះ $(U_n)$ ជាស្វ៊ីតរួមខិតទៅរក $0$ ។

ឃ.$U_n = \frac{2n}{n+3} + \frac{3n^3}{n^2+5}$

គេមាន $\lim_{n\to+\infty} U_n = \lim_{n\to+\infty}\left(\frac{2n}{n+3} + \frac{3n^3}{n^2+5}\right)$

$$= \lim_{n\to+\infty}\left(\frac{2n}{n} + \frac{3n^3}{n^2}\right)$$

$$= \lim_{n\to+\infty}(2+3n) = +\infty$$

ដូចនេះ $(U_n)$ ជាស្វ៊ីតរីកខិតទៅរក $+\infty$ ។

ង.$U_n = \frac{n\sin n}{n^2+1}$

គេមាន $-1 \le \sin n \le 1$ នាំឱ្យ $-\frac{n}{n^2+1} \le u_n \le \frac{n}{n^2+1}$

ដោយ $\lim_{n\to+\infty} \frac{n}{n^2+1} = 0$ នោះ $\lim_{n\to+\infty} U_n = 0$ ។

ដូចនេះ $(U_n)$ ជាស្វ៊ីតរួមខិតទៅរក $0$ ។

ច. $U_n = 2 - \frac{3}{n} + \frac{4}{\sqrt{n}}$

គេមាន $\lim\limits_{n\to+\infty} U_n = \lim\limits_{n\to+\infty}\left(2 - \frac{3}{n} + \frac{4}{\sqrt{n}}\right)$

$= 2$ ( ព្រោះ $\lim\limits_{n\to+\infty}\frac{3}{n} = \lim\limits_{n\to+\infty}\frac{4}{\sqrt{n}} = 0$ )

ដូចនេះ $(U_n)$ ជាស្វ៊ីតរួមខិតទៅរក 2 ។

2.គណនាលីមីតនៃស្វ៊ីតខាងក្រោម

ក. $\lim\limits_{n\to+\infty}\frac{n^2+3n-1}{8n^2-n+1}$

ខ. $\lim\limits_{n\to+\infty}\frac{5n^3+n^2-n}{n^2+n-1}$

គ. $\lim\limits_{n\to+\infty}\frac{5n^3+(-1)^n}{n+(-1)^n}$

ឃ. $\lim\limits_{n\to+\infty}\frac{n^2+\sin n}{5n^2+\cos\pi n}$

ង. $\lim\limits_{n\to+\infty}(n^2-\cos^2\pi n)$

ច. $\lim\limits_{n\to+\infty}\left[-5n^3+(-1)^n n^3\right]$

**ដំណោះស្រាយ**

គណនាលីមីតនៃស្វ៊ីតខាងក្រោម

ក. $\lim\limits_{n\to+\infty}\frac{n^2+3n-1}{8n^2-n+1}$

$= \lim\limits_{n\to+\infty}\frac{n^2}{8n^2} = \frac{1}{8}$

ខ. $\lim\limits_{n\to+\infty}\frac{5n^3+n^2-n}{n^2+n-1}$

$= \lim\limits_{n\to+\infty}\frac{5n^3}{n^2} = \lim\limits_{n\to+\infty} 5n = +\infty$

គ. $\lim\limits_{n\to+\infty} \dfrac{5n^3+(-1)^n}{n+(-1)^n}$

$= \lim\limits_{n\to+\infty} \dfrac{5n^3}{n} = \lim\limits_{n\to+\infty} 5n^2 = +\infty$

ឃ. $\lim\limits_{n\to+\infty} \dfrac{n^2+\sin n}{5n^2+\cos \pi n}$

$= \lim\limits_{n\to+\infty} \dfrac{1+\dfrac{\sin n}{n^2}}{5+\dfrac{\cos \pi n}{n^2}}$

ដោយ $-1 \le \sin n \le 1$ នោះ $-\dfrac{1}{n^2} \le \dfrac{\sin n}{n^2} \le \dfrac{1}{n^2}$

ហើយ $\dfrac{1}{n^2} \to 0$ កាលណា $n \to +\infty$ នោះ $\lim\limits_{n\to+\infty} \dfrac{\sin n}{n^2} = 0$

ដូចគ្នាដែរ $-1 \le \cos(\pi n) \le 1$ នោះ $-\dfrac{1}{n^2} \le \dfrac{\cos(\pi n)}{n^2} \le \dfrac{1}{n^2}$

ហើយ $\dfrac{1}{n^2} \to 0$ កាលណា $n \to +\infty$ នោះ $\lim\limits_{n\to+\infty} \dfrac{\cos(\pi n)}{n^2} = 0$

ដូចនេះ $\lim\limits_{n\to+\infty} \dfrac{n^2+\sin n}{5n^2+\cos \pi n} = \dfrac{1}{5}$ ។

ង. $\lim\limits_{n\to+\infty} (n^2 - \cos^2 \pi n)$

$= \lim\limits_{n\to+\infty} \left[ n^2 (1 - \dfrac{\cos^2 \pi n}{n^2}) \right] = +\infty$

ព្រោះ $0 \le \dfrac{\cos^2 \pi n}{n^2} \le \dfrac{1}{n^2} \Rightarrow \lim\limits_{n\to+\infty} \dfrac{\cos^2 \pi n}{n^2} = 0$ ។

3. គណនាលីមីតនៃស្វ៊ីតខាងក្រោម

ក. $\lim\limits_{n\to+\infty}\left(\sqrt{n+1}-\sqrt{n}\right)$ ខ. $\lim\limits_{n\to+\infty}\sqrt{n}\left(\sqrt{n-3}-\sqrt{n}\right)$

គ. $\lim\limits_{n\to+\infty}\left(n\sqrt{n^2+1}-1\right)$

ឃ. $\lim\limits_{n\to+\infty}\left(\dfrac{n!}{(n+1)!-n!}-\dfrac{2}{n}+3\right)$ ។

**ដំណោះស្រាយ**

គណនាលីមីតនៃស្វ៊ីតខាងក្រោម

ក. $\lim\limits_{n\to+\infty}\left(\sqrt{n+1}-\sqrt{n}\right)$

$$=\lim_{n\to+\infty}\frac{n+1-n}{\sqrt{n+1}+\sqrt{n}}$$

$$=\lim_{n\to+\infty}\frac{1}{\sqrt{n+1}+\sqrt{n}}=0$$

ខ. $\lim\limits_{n\to+\infty}\sqrt{n}\left(\sqrt{n-3}-\sqrt{n}\right)$

$$=\lim_{n\to+\infty}\frac{\sqrt{n}(n-3-n)}{\sqrt{n-3}+\sqrt{n}}$$

$$=-3\lim_{n\to+\infty}\frac{\sqrt{n}}{\sqrt{n-3}+\sqrt{n}}$$

$$=-3\lim_{n\to+\infty}\frac{\sqrt{n}}{\sqrt{n}+\sqrt{n}}$$

$$=-3\lim_{n\to+\infty}\frac{\sqrt{n}}{2\sqrt{n}}=-\frac{3}{2}$$

គ. $\lim\limits_{n\to+\infty}\left(n\sqrt{n^2+1}-1\right)$

$= \lim\limits_{n\to+\infty}\left[n(\sqrt{n^2+1}-\frac{1}{n})\right]$

$= \lim\limits_{n\to+\infty} n\sqrt{n^2+1} = +\infty$

ឃ. $\lim\limits_{n\to+\infty}\left(\frac{n!}{(n+1)!-n!}-\frac{2}{n}+3\right)$

$= \lim\limits_{n\to+\infty}\left[\frac{n!}{n!(n+1)-n!}-\frac{2}{n}+3\right]$

$= \lim\limits_{n\to+\infty}\left(\frac{1}{n}-\frac{2}{n}+3\right) = \lim\limits_{n\to+\infty}\left(-\frac{1}{n}+3\right) = 3$

4.គេមានស៊ីតដែលកំនត់ចំពោះគ្រប់ $n \in IN$ មានតួទូទៅដូចខាងក្រោម៖

$U_n = \frac{n^3}{2^n}$ , $V_n = \frac{2^n}{n!}$ ដែល $n! = n(n-1)\times\ldots\times 1$

ក.គណនា $\lim\limits_{n\to+\infty}\frac{U_{n+1}}{U_n}$ និង $\lim\limits_{n\to+\infty}\frac{V_{n+1}}{V_n}$

ខ.គណនា $\lim\limits_{n\to+\infty}\frac{2^n+n^3}{n!+n^3}$

**ដំណោះស្រាយ**

ក.គណនា $\lim\limits_{n\to+\infty}\frac{U_{n+1}}{U_n}$ និង $\lim\limits_{n\to+\infty}\frac{V_{n+1}}{V_n}$

គេមាន $U_n = \frac{n^3}{2^n}$ , $V_n = \frac{2^n}{n!}$ ដែល $n! = n(n-1)\times\ldots\times 1$

គេបាន $\dfrac{U_{n+1}}{U_n}=\dfrac{\dfrac{(n+1)^3}{2^{n+1}}}{\dfrac{n^3}{2^n}}=\dfrac{(n+1)^3}{2n^3}=\dfrac{1}{2}(1+\dfrac{1}{n})^3$

គេបាន $\lim\limits_{n\to+\infty}\dfrac{U_{n+1}}{U_n}=\dfrac{1}{2}$ ។

ហើយ $\dfrac{V_{n+1}}{V_n}=\dfrac{\dfrac{2^{n+1}}{(n+1)!}}{\dfrac{2^n}{n!}}=\dfrac{2}{n+1}$

គេបាន $\lim\limits_{n\to+\infty}\dfrac{V_{n+1}}{V_n}=\lim\limits_{n\to+\infty}\dfrac{2}{n+1}=0$

ខ.គណនា $\lim\limits_{n\to+\infty}\dfrac{2^n+n^3}{n!+n^3}$

គេបាន $\lim\limits_{n\to+\infty}\dfrac{2^n+n^3}{n!+n^3}=\lim\limits_{n\to+\infty}\dfrac{2^n(1+\dfrac{n^3}{2^n})}{n!(1+\dfrac{n^3}{n!})}$

$$=\lim_{n\to+\infty}\frac{2^n}{n!}=+\infty$$

5.គណនាលីមីតនៃស្វ៊ីត $(a_n)$ ដែលគេស្គាល់តួដូចខាងក្រោមៈ

ក.$a_1 = 2 \quad , \quad a_{n+1} = \frac{1}{2}a_n + 3$

ខ.$a_1 = 3 \quad , \quad a_{n+1} = 2a_n - 5$

គ.$a_1 = 1 \quad , \quad a_{n+1} = \frac{1}{3}a_n + \frac{4}{3}$ ។

**ដំណោះស្រាយ**

គណនាលីមីតនៃស្វ៊ីត $(a_n)$

ក.$a_1 = 2 \quad , \quad a_{n+1} = \frac{1}{2}a_n + 3$

គណនាតួទូទៅនៃស្វ៊ីត $a_{n+1} = \frac{1}{2}a_n + 3$

សមីការសម្គាល់នៃស្វ៊ីតគឺ $r = \frac{1}{2}r + 3 \Rightarrow r = 6$

តាងស្វ៊ីតជំនួយ $b_n = a_n - 6$

គេបាន $b_{n+1} = a_{n+1} - 6 = \left(\frac{1}{2}a_n + 3\right) - 6 = \frac{1}{2}(a_n - 6)$

គេទាញ $b_{n+1} = \frac{1}{2}b_n$ នោះ $(b_n)$ ជាស្វ៊ីតធរណីមាត្រមាន $q = \frac{1}{2}$

និងតួ $b_1 = a_1 - 6 = 2 - 6 = -4$

គេបាន $b_n = -4 \times \left(\frac{1}{2}\right)^{n-1}$ នាំឱ្យ $a_n = 6 - 4\left(\frac{1}{2}\right)^{n-1}$

ដូចនេះ $\lim_{n \to +\infty} a_n = 6$ ។

ខ.$a_1 = 3 \quad , \quad a_{n+1} = 2a_n - 5$

ដោះស្រាយដូចខាងលើគេបាន $a_n = 5 - 2^n$ និង $\lim\limits_{n\to+\infty} a_n = -\infty$ ។

គ.$a_1 = 1 \quad , \quad a_{n+1} = \frac{1}{3}a_n + \frac{4}{3}$ ។

ដោះស្រាយដូចខាងលេគេបាន $a_n = 2 - \left(\frac{1}{3}\right)^{n-1}$ និង $\lim\limits_{n\to+\infty} a_n = 2$

6.ពិនិត្យស៊េរីខាងក្រោមនេះ តើជាស៊េរីរីក រឺ រួម?

ក.$\sum\limits_{n=0}^{\infty} 3.\left(\frac{3}{2}\right)^n$ ខ.$\sum\limits_{n=0}^{\infty} 1000(1.055)^n$

គ.$\sum\limits_{n=1}^{\infty} \frac{n+\sqrt{n}}{2n^3-1}$ ឃ.$\sum\limits_{n=1}^{\infty} \frac{2^n+1}{2^{n-1}}$

ង.$2 + \frac{3}{2} + \frac{9}{8} + \frac{27}{32} + \frac{81}{128} ...$ ច.$\sum\limits_{n=1}^{\infty} \left(\sqrt{2n+1} - \sqrt{2n-1}\right)$

**ដំណោះស្រាយ**

សិក្សាភាពរួម ឬ រីកនៃស៊េរី

ក.$\sum\limits_{n=0}^{\infty} 3.\left(\frac{3}{2}\right)^n$

ផលបូកដោយផ្នែករបស់ស៊េរីគឺ

$$S_n = \sum_{k=0}^{n} 3\left(\frac{3}{2}\right)^k = 3\times\frac{1-\left(\frac{3}{2}\right)^{n+1}}{1-\frac{3}{2}} = -3\left[1-\left(\frac{3}{2}\right)^{n+1}\right]$$

គេមាន $\lim\limits_{n\to+\infty} S_n = -3\lim\limits_{n\to+\infty}\left[1-\left(\frac{3}{2}\right)^{n+1}\right] = +\infty$

ដូចនេះ $\sum\limits_{n=0}^{\infty} 3.\left(\frac{3}{2}\right)^n$ ជាស៊េរីរីក ។

ខ. $\sum\limits_{n=0}^{\infty} 1000(1.055)^n$ ជាស៊េរីរីកព្រោះ $r = 1.055 > 1$ ។

គ. $\sum\limits_{n=1}^{\infty} \frac{n+\sqrt{n}}{2n^3-1}$ ជាស៊េរីរួម ។

ឃ. $\sum\limits_{n=1}^{\infty} \frac{2^n+1}{2^{n-1}}$

គេមាន $\lim\limits_{n\to+\infty} \frac{2^n+1}{2^{n-1}} = \lim\limits_{n\to+\infty}\left(2+\frac{1}{2^{n-1}}\right) = 2 \neq 0$

ដូចនេះ $\sum\limits_{n=1}^{\infty} \frac{2^n+1}{2^{n-1}}$ ជាស៊េរីរីក ។

ង. $2+\frac{3}{2}+\frac{9}{8}+\frac{27}{32}+\frac{81}{128}\ldots$

ផលបូកដោយផ្នែក $S_n = 2+\frac{3}{2}+\frac{9}{8}+\ldots+2\left(\frac{3}{4}\right)^{n-1}$

$$= 2\times\frac{1-\left(\frac{3}{4}\right)^n}{1-\frac{3}{4}} = 8\left[1-\left(\frac{3}{4}\right)^n\right]$$

ដោយ $\lim\limits_{n\to+\infty} S_n = 8\lim\limits_{n\to+\infty}\left[1-\left(\frac{3}{4}\right)^n = 8\right]$ នោះវាជាស៊េរីរួម ។

ច. $\sum_{n=1}^{\infty}\left(\sqrt{2n+1}-\sqrt{2n-1}\right)$

មានផលបូកដោយផ្នែក

$$S_n=\sum_{k=1}^{n}\left(\sqrt{2k+1}-\sqrt{2k-1}\right)=\sqrt{2n+1}-1$$

ដោយ $\lim_{n\to+\infty} S_n=\lim_{n\to+\infty}\left(\sqrt{2n+1}-1\right)=+\infty$

ដូចនេះ $\sum_{n=1}^{\infty}\left(\sqrt{2n+1}-\sqrt{2n-1}\right)$ ជាស៊េរីរីក ។

7.រកផលបូកនៃស៊េរីខាងក្រោម៖

ក. $1+0.1+0.01+0.001+...$ ខ. $\sum_{n=1}^{\infty}\frac{2}{4n^2-1}$

គ. $\sum_{n=1}^{\infty}\frac{1}{(2n-1)(2n+1)}$ ឃ. $\sum_{n=0}^{\infty}2\left(\cos\frac{\pi}{3}\right)^n$

ង. $\sum_{n=1}^{\infty}\frac{5(-1)^n}{4^n}$ ច. $\frac{2}{3}+\left(\frac{2}{3}\right)^2+\left(\frac{2}{3}\right)^3+...$

**ដំណោះស្រាយ**

រកផលបូកនៃស៊េរី ៖

ក. $1+0.1+0.01+0.001+...$

យើងឃើញថា 1 , 0.1 , 0.01 , ... ជាស៊េរីធរណីមាត្រអនន្តដែល

$a=1$ និង $r=0.1$ ។

ដូចនេះ $1+0.1+0.01+0.001+...=\frac{1}{1-0.1}=\frac{10}{9}$ ។

ខ. $\sum_{n=1}^{\infty}\frac{2}{4n^2-1}$

គេមាន $\frac{2}{4k^2-1}=\frac{(2k+1)-(2k-1)}{(2k+1)(2k-1)}=\frac{1}{2k-1}-\frac{1}{2k+1}$

គេបាន

$$\sum_{k=1}^{n}\left(\frac{2}{4k^2-1}\right)=\sum_{k=1}^{n}\left(\frac{1}{2k-1}-\frac{1}{2k+1}\right)=1-\frac{1}{2n+1}=\frac{2n}{2n+1}$$

កាលណា $n\to+\infty$ នោះ $\frac{2n}{2n+1}\to 1$

ដូចនេះ $\sum_{n=1}^{\infty}\frac{2}{4n^2-1}=1$

គ. $\sum_{n=1}^{\infty}\frac{1}{(2n-1)(2n+1)}=\frac{1}{2}$

ឃ. $\sum_{n=0}^{\infty}2\left(\cos\frac{\pi}{3}\right)^n=\frac{2}{1-\cos\frac{\pi}{3}}=4$

ង. $\sum_{n=1}^{\infty}\frac{5(-1)^n}{4^n}=5\times\frac{1}{1+\frac{1}{4}}=4$

ច. $\frac{2}{3}+\left(\frac{2}{3}\right)^2+\left(\frac{2}{3}\right)^3+...=\frac{2}{3}.\frac{1}{1-\frac{2}{3}}=2$

៤.គណនា

ក. $\lim_{n\to+\infty}\left(1-\frac{1}{2^2}\right)...\left(1-\frac{1}{n^2}\right)$

ពិនិត្យ $1-\frac{1}{k^2}=\frac{k^2-1}{k^2}=\frac{k-1}{k}\times\frac{k+1}{k}$

គេបាន $\prod_{k=2}^{n}\left(1-\frac{1}{k^2}\right)=\prod_{k=2}^{n}\left(\frac{k-1}{k}\right)\times\prod_{k=2}^{n}\left(\frac{k+1}{k}\right)$

$$=\frac{1}{n}.\frac{n+1}{2}=\frac{n+1}{2n}$$

ដូចនេះ . $\lim_{n\to+\infty}\left(1-\frac{1}{2^2}\right)...\left(1-\frac{1}{n^2}\right)=\lim_{n\to+\infty}\frac{n+1}{2n}=\frac{1}{2}$

ខ. $\lim_{n\to+\infty}\left(\frac{n}{\sqrt{n^4+1}}+\frac{n}{\sqrt{n^4+2}}+...+\frac{n}{\sqrt{n^4+n}}\right)$

ចំពោះគ្រប់ $k=1\ ,\ 2\ ,\ ...,n$ គេមាន

$n^4+1\le n^4+k\le n^4+n$

$\sqrt{n^4+1}\le\sqrt{n^4+k}\le\sqrt{n^4+n}$

$\frac{n}{\sqrt{n^4+n}}\le\frac{n}{\sqrt{n^4+k}}\le\frac{n}{\sqrt{n^4+1}}$

គេទាញ $\sum_{k=1}^{n}\frac{n}{\sqrt{n^4+n}}\le\sum_{k=1}^{n}\frac{n}{\sqrt{n^4+k}}\le\sum_{k=1}^{n}\frac{n}{\sqrt{n^4+1}}$

$$\frac{n^2}{\sqrt{n^4+n}}\le\sum_{k=1}^{n}\frac{n}{\sqrt{n^4+k}}\le\frac{n^2}{\sqrt{n^4+1}}$$

ដោយ $\lim_{n\to+\infty}\frac{n^2}{\sqrt{n^4+n}}=\lim_{n\to+\infty}\frac{n^2}{\sqrt{n^4+1}}=1$

គេទាញ $\lim\limits_{n\to+\infty}\sum\limits_{k=1}^{n}\frac{n}{\sqrt{n^4+k}}=1$ ។

ដូចនេះ $\lim\limits_{n\to+\infty}\left(\frac{n}{\sqrt{n^4+1}}+\frac{n}{\sqrt{n^4+2}}+...+\frac{n}{\sqrt{n^4+n}}\right)=1$

៩.គណនា

$$\lim_{n\to+\infty}\left[(q-1)+q^2\left(q^2-q\right)+...+q^{2(n-1)}\left(q^n-q^{n-1}\right)\right]$$

ដែល $q=2^{\frac{1}{2}}$ ។

## ដំណោះស្រាយ

$$\lim_{n\to+\infty}\left[(q-1)+q^2\left(q^2-q\right)+...+q^{2(n-1)}\left(q^n-q^{n-1}\right)\right]$$

$$=\lim_{n\to+\infty}\sum_{k=1}^{n}q^{2(k-1)}(q^k-q^{k-1})$$

$$=\lim_{n\to+\infty}\sum_{k=1}^{n}q^{3k-3}(q-1)$$

$$=\lim_{n\to+\infty}\frac{1-q^{3n}}{1-q^3}(q-1)$$

$$=\lim_{n\to+\infty}\frac{1-2^{\frac{3n}{2}}}{1-2^{\frac{3}{2}}}(2^{\frac{1}{2}}-1)=+\infty$$

ព្រោះ $\lim\limits_{n\to+\infty}2^{\frac{3n}{2}}=+\infty$ ។

10. គេឱ្យស្វ៊ីត $(a_n)$ កំណត់ដោយ $a_n = \frac{1}{2+q^n}$ ដែល $q \neq -1$ ។

សិក្សាលីមីតនៃស្វ៊ីត $(a_n)$ កាលណា $n \to +\infty$ ។

**ដំណោះស្រាយ**

សិក្សាលីមីតនៃស្វ៊ីត

គេបាន $\lim\limits_{n\to+\infty} a_n = \lim\limits_{n\to+\infty} \frac{1}{2+q^n}$

-បើ $q > 1$ នោះ $\lim\limits_{n\to+\infty} a_n = \lim\limits_{n\to+\infty} \frac{1}{2+q^n} = 0$

-បើ $q = 1$ នោះ $\lim\limits_{n\to+\infty} a_n = \lim\limits_{n\to+\infty} \frac{1}{2+q^n} = \frac{13}{}$

-បើ $-1 < q < 1$ នោះ $\lim\limits_{n\to+\infty} a_n = \lim\limits_{n\to+\infty} \frac{1}{2+q^n} = \frac{1}{2}$

-បើ $q < -1$ នោះ $\lim\limits_{n\to+\infty} a_n = \lim\limits_{n\to+\infty} \frac{1}{2+q^n} = \frac{1}{2}$

11.ចំពោះគ្រប់ $n \in IN$ គេមាន

$$S_n = \frac{2}{1\times 3} + \frac{2}{3\times 5} + \dots + \frac{2}{(2n-1)(2n+1)} = \sum_{p=0}^{n} \frac{2}{(2p+1)(2p+3)}$$

ក.គណនា $S_n$ ជាអនុគមន៍នៃ $n$ ដោយប្រើ $\frac{2}{(2p+1)(2p+3)}$

ជាទម្រង់ $\frac{a}{(2p+1)} + \frac{b}{(2p+3)}$ ។

ខ.គណនា $\lim\limits_{n\to+\infty} S_n$ ។

## ដំណោះស្រាយ

ក.គណនា $S_n$ ជាអនុគមន៍នៃ n

$$\frac{2}{(2p+1)(2p+3)}=\frac{a}{(2p+1)}+\frac{b}{(2p+3)}$$ ។

ឬ $2=a(2p+3)+b(2p+1)$

ឬ $2=(2a+2b)p+3a+b$

គេទាញ $\begin{cases}2a+2b=0\\3a+b=2\end{cases}$ នាំឱ្យ $a=1$ , $b=-1$

គេបាន $\dfrac{2}{(2p+1)(2p+3)}=\dfrac{1}{2p+1}-\dfrac{1}{2p+3}$

ហើយ $S_n=\sum_{p=0}^{n}\dfrac{2}{(2p+1)(2p+3)}$

$$=\sum_{p=0}^{n}\left(\frac{1}{2p+1}-\frac{1}{2p+3}\right)$$

$$=1-\frac{1}{2n+3}=\frac{2(n+1)}{2n+3}$$

ដូចនេះ $S_n=\dfrac{2(n+1)}{2n+3}$ ។

ខ.គណនា $\lim\limits_{n\to+\infty}S_n$

គេមាន $S_n=1-\dfrac{1}{2n+3}$

ដូចនេះ $\lim\limits_{n\to+\infty}S_n=\lim\limits_{n\to+\infty}(1-\dfrac{1}{2n+3})=1$ ។

12.គេមានស៊េរីអនន្តមួយ $r^2+\frac{r^2}{r^2+1}+\frac{r^2}{(r^2+1)^2}+...+\frac{r^2}{(r^2+1)^{n-1}}+...$

បង្ហាញថាស៊េរីអនន្តនោះរួមចំពោះគ្រប់តម្លៃ r ។

**ដំណោះស្រាយ**

បង្ហាញថាស៊េរីអនន្តរួមចំពោះគ្រប់តម្លៃr

គេមាន $r^2+\frac{r^2}{r^2+1}+\frac{r^2}{(r^2+1)^2}+...+\frac{r^2}{(r^2+1)^{n-1}}+...$

ផលបូលដោយផ្នែករបស់ស៊េរីនេះគឺ $S_n=\sum_{k=1}^{n}\frac{r^2}{(r^2+1)^{k-1}}$

ឬ $S_n=r^2\sum_{k=1}^{n}\frac{1}{(r^2+1)^{k-1}}$

$$=r^2\times\frac{1-\frac{1}{(r^2+1)^n}}{1-\frac{1}{r^2+1}}=(r^2+1)\left[1-\frac{1}{(r^2+1)^n}\right]$$

កាលណា $n\to+\infty$ នោះ $\frac{1}{(r^2+1)^n}\to 0$ ចំពោះគ្រប់ r ។

គេបាន $\lim_{n\to+\infty}S_n=r^2+1$ នាំឱ្យស៊េរីខាងលើជាស៊េរីបង្រួម ។

13.កំណត់ស៊េរីខាងក្រោម តើស៊េរីមួយណារួម មួយណារីក? បើជាស៊េរីរួម ចូររកផលបូក ។

ក. $\sum_{n=1}^{\infty}2\left(\cos\frac{\pi}{3}\right)^n$　　　　ខ. $\sum_{n=1}^{\infty}\left(\tan\frac{\pi}{4}\right)^n$

គ. $\sum_{n=1}^{\infty}\frac{n}{2n+5}$ ឃ. $\sum_{n=1}^{\infty}\frac{5(-1)^n}{4^n}$ ។

**ដំណោះស្រាយ**

សិក្សាភាពរីក រួមរបស់ស៊េរី

ក. $\sum_{n=1}^{\infty}2\left(\cos\frac{\pi}{3}\right)^n$ ជាស៊េរីរួមខិតទៅរក $\frac{2\cos\frac{\pi}{3}}{1-\cos\frac{\pi}{3}}=2$

ព្រោះវាជាស៊េរីធរណីមាត្រអនន្តមាន $|r|=\cos\frac{\pi}{3}=\frac{1}{2}<1$ ។

ខ. $\sum_{n=1}^{\infty}\left(\tan\frac{\pi}{4}\right)^n$

ដោយ $a_n=\left(\tan\frac{\pi}{4}\right)^n=1^n=1$ ហើយ $\lim_{n\to+\infty}a_n=1\neq 0$

ដូចនេះ $\sum_{n=1}^{\infty}\left(\tan\frac{\pi}{4}\right)^n$ ជាស៊េរីពង្រីក ។

គ. $\sum_{n=1}^{\infty}\frac{n}{2n+5}$ ដោយ $a_n=\frac{n}{2n+5}$ មានលីមីត

$\lim_{n\to+\infty}a_n=\lim_{n\to+\infty}\frac{n}{2n+5}=\frac{1}{2}$ នាំឱ្យ $\sum_{n=1}^{\infty}\frac{n}{2n+5}$ ជាស៊េរីពង្រីក ។

ឃ. $\sum_{n=1}^{\infty}\frac{5(-1)^n}{4^n}$ ជាស៊េរីរួមខិតទៅរក $\frac{-5}{1+\frac{1}{4}}=-4$

ព្រោះវាជាស៊េរីធរណីមាត្រអនន្តមាន $|r|=\left|-\frac{1}{4}\right|=\frac{1}{4}<1$ ។

14.គេមាន $\Delta ABC$ មួយមានក្រលាផ្ទៃស្មើនឹង 6 ឯកតា។

សង់$\Delta A'B'C'$ ដោយ A', B' និង C' ជាចំនុចកណ្តាលនៃជ្រុង $\Delta ABC$ ។ ចូរកំណត់ផលបូក $S = S_1 + S_2 + S_3 + \ldots$ ។

## ដំណោះស្រាយ

កំណត់ផលបូក $S = S_1 + S_2 + S_3 + \ldots$




តាង a , b , c ជាជ្រុង $\Delta ABC$

ដែលមានផ្ទៃក្រឡា $S_1 = 6$

និងកន្លះបរិមាត្រ $p = \dfrac{a+b+c}{2}$

តាង $S_2$ ជាក្រឡាផ្ទៃ$\Delta A'B'C'$

$S_3$ ជាក្រឡាផ្ទៃ $\Delta A''B''C''$

--------------------------------

ដោយ A' , B' , C' ជាចំណុចកណ្ដាលនៃ BC, CA, AB នោះ

$B'C' = \frac{a}{2}$ ; $A'C' = \frac{b}{2}$ , $A'B' = \frac{c}{2}$ និង $p' = \frac{p}{2}$

គេបាន $S_2 = \sqrt{\frac{p}{2}(\frac{p}{2}-\frac{a}{2})(\frac{p}{2}-\frac{b}{2})(\frac{p}{2}-\frac{c}{2})} = \frac{1}{4}S_1$

ដូចគ្នាដែរគេទាញ $S_3 = \frac{1}{4^2}S_1$ ; $S_4 = \frac{1}{4^3}S_1$ , .....

គេបាន $S = S_1 + S_2 + ..... = \frac{S_1}{1-q} = \frac{6}{1-\frac{1}{4}} = 8$ ។

## ជំពូកទី២

## មេរៀនសង្ខេប ដេរីវេនៃអនុគមន៍

◆ គេឱ្យអនុគមន៍ f កំណត់និងជាប់ហើយមានដេរីវេលើ I ។ បើមានពីរចំនួនពិត m និង M ដែលចំពោះគ្រប់ $x \in I : m \le f'(x) \le M$ នោះគ្រប់ចំនួនពិត $a , b \in I$ ដែល $a < b$ គេបាន $m(b-a) \le f(b) - f(a) \le M(b-a)$ ។

◆ គេឱ្យអនុគមន៍ f មានដេរីវេលើចន្លោះ $[a , b]$ ។ បើមានចំនួន M ដែលគ្រប់ $x \in [a,b] : |f'(x)| \le M$ នោះគេបាន :

$|f(b) - f(a)| \le M|b-a|$ ។

◆ បើf ជាអនុគមន៍ជាប់លើចន្លោះ $[a , b]$ មានដេរីវេលើចន្លោះ$(a , b)$ និង $f(a) = f(b)$ នោះមានចំនួន

$c \in (a,b)$ មួយយ៉ាងតិចដែល$f'(c) = 0$

◆ បើf ជាអនុគមន៍ជាប់លើចន្លោះ $[a , b]$ មានដេរីវេលើចន្លោះ$(a , b)$ នោះមានចំនួន $c \in (a,b)$ មួយយ៉ាងតិចដែល$f'(c) = \dfrac{f(b) - f(a)}{b-a}$ ។

## លំហាត់

1.រក $dy$ , $\Delta y$ , $dy - \Delta y$ និង $\frac{dy}{\Delta y}$ នៃអនុមន៍ខាងក្រោម

ក. $y = x^2 - 3x + 4$ ចំពោះ $x = 3$ , $\Delta x = 0.2$

ខ. $y = \sqrt{12 - 5x}$ ចំពោះ $x = 2$ , $\Delta x = 0.07$ ។

2.ប្រើឌីផេរ៉ង់ស្យែល ដេម្បីរកតម្លៃប្រហែលនៃចំនួនខាងក្រោមៈ

ក. $\sqrt{37}$ ខ. $\sqrt{65}$

គ. $\sqrt[3]{26}$ ឃ. $\sqrt[3]{126}$

ង. $\sqrt{50.4}$ ច. $\sqrt{79.5}$

ឆ. $\sqrt[3]{62.3}$ ជ. $\sqrt[3]{218.6}$

3. ក្រុមហ៊ុនផលិតសម្ភារៈប្រើប្រាស់មួយបានទទួលប្រាក់ចំនូលសរុបពីការលក់ សម្ភារៈ $x$ គ្រឿងដែលឱ្យតាមអនុគមន៍

$R(x) = 20x - \frac{x^2}{30}$ គិតជាម៉ឺនរៀលដែល $0 \le x \le 600$ ។

ដោយប្រើឌីផេរ៉ង់ប៉ាន់ស្មានតម្លៃប្រហែលនៃកំណើនប្រាក់ចំណូល បើ សម្ភារៈលក់ប្រែប្រួលពី 150 គ្រឿង ទៅ 160 គ្រឿង ។

4. រោងចក្រផលិតសម្ភារៈប្រើប្រាស់មួយបានចំណាយប្រាក់សរុបក្នុងការ

ផលិតសម្ភារៈ $x$ គ្រឿងដែលឱ្យតាមអនុគមន៍

$C(x) = 930 + 15x + 0.2x^2$ ពាន់រៀល ។

ដោយប្រើឌីផេរ៉ង់ប៉ាន់ស្មានតម្លៃប្រហែលនៃកំណើនប្រាក់ចំណាយបើសម្ភារៈ ដែលបានផលិតកើនពី 60 គ្រឿង ទៅ 62 គ្រឿង ។

5.សហគ្រាសផលិតសម្ភារៈអេឡិចត្រូនិចមួយ បានចំណាយប្រាក់សរុបក្នុង មួយខែសម្រាប់ផលិតសម្ភារៈ $x$ គ្រឿងដែលឱ្យតាមអនុគមន៍

$C(x) = 0.1x^2 + 4x + 200$ គិតជាពាន់រៀល ។ ហើយសហគ្រាសបាន ទទួលប្រាក់ចំណូលមកវិញឱ្យតាមអនុគមន៍

$R(x) = 54x - 0.3x^2$ គិតជាពាន់រៀល ។

ក.សរសេរអនុគមន៍ប្រាក់ចំណេញ $P(x)$

ខ.ដោយប្រើឌីផេរ៉ង់ប៉ាន់ស្មានតម្លៃប្រហែលនៃកំណើនប្រាក់ចំណេញ បើបរិមាណសម្ភារៈដែលបានលក់កើនពី 40 គ្រឿង ទៅ 44 គ្រឿង ។

6.តាមការអង្កេតរបស់អ្នកស្ថិតិបានឱ្យដឹងថា ចំនួនប្រជាពលរដ្ឋនៅក្នុងទីក្រុង មួយរយះពេល $t$ ឆ្នាំទៅមុខទៀត មានការកើនឡើងដែលឱ្យតាមអនុគមន៍

$P(t) = 10(40 + 2t)^2 - 160t$ （នាក់） ។

ដោយប្រើឌីផេរ៉ង់ស្សៀលដើម្បីប៉ាន់ស្មានកំណើនប្រជាពលរដ្ឋក្នុងទីក្រុងនោះ

បើ $t$ ប្រែប្រួលពី $6$ ទៅ $6.25$ ឆ្នាំ ។

7.បាល់មួយមានរាងជាស្វ៊ែ ។ ប្រើឌីផេរ៉ង់ស្យែលដើម្បីគណនាតម្លៃប្រហែលនៃកំណើនមាឌបាល់ បើពេលត្រូវកំដៅថ្ងៃបាល់រីកមាឌដែលកាំរបស់វាប្រែប្រួលពី $2m$ ទៅ $2.15m$ ។

8.គេឱ្យអនុគមន៍ $f$ មានដេរីវេលើ $(-2,\infty)$ ដែល $f(x)=\sqrt{x+2}$ ។

ក.រកតំលៃអមនៃ $f(x)$ ចំពោះគ្រប់ $x\in[-1,2]$ ។

ខ.បង្ហាញថា ចំពោះគ្រប់ $x\in[-1,2]$

គេបាន $\dfrac{1}{4}x+\dfrac{5}{4}\le\sqrt{x+2}\le\dfrac{1}{2}x+\dfrac{3}{2}$ ។

9.គេឱ្យអនុគមន៍ $f$ កំណត់លើ $\left[0,\dfrac{\pi}{2}\right)$ ដែល $f(x)=\tan x$ ។

បង្ហាញចំពោះគ្រប់ចំនួនពិត $a$ និង $b$ ដែល $0\le a\le b\le\dfrac{\pi}{2}$

គេបាន $\dfrac{b-a}{\cos^2 a}\le\tan b-\tan a\le\dfrac{b-a}{\cos^2 b}$ ។

10.គេឱ្យអនុគមន៍ $f$ កំណត់លើចន្លោះ $I$ ។ ប្រើទ្រឹស្តីបទរ៉ូល (បើអាច) រកគ្រប់តម្លៃ $c$ ក្នុងចន្លោះ $I$ ដែល $f'(c)=0$:

ក.$f(x)=x^3-4x$ , $c\in(-2,2)$

ខ.$f(x)=(x-1)(x-2)(x-3)$ , $c\in(1,3)$

គ.$f(x)=\dfrac{x^2-2x-3}{x+2}$ , $c\in(-1,3)$

ឃ.$f(x)=\dfrac{x^2-1}{x}$ , $c\in(-1,1)$

ង.$f(x)=\sin 2x$ , $c\in\left(\dfrac{\pi}{6},\dfrac{\pi}{3}\right)$

ច.$f(x)=\dfrac{x}{2}-\sin\dfrac{\pi x}{6}$ , $c\in(-1,0)$ ។

11.គេឱ្យអនុគមន៍f កំណត់លើចន្លោះ I ។ ប្រើទ្រឹស្តីបទតម្លៃមធ្យម រកគ្រប់តម្លៃ $c\in(a,b)$ ដែល $f'(c)=\dfrac{f(b)-f(a)}{b-a}$ :

ក.$f(x)=x^2$ , $c\in(-2,1)$

ខ.$f(x)=x(x^2-x-2)$ , $c\in(-1,1)$

គ.$f(x)=x^3$ , $c\in(0,1)$

ឃ.$f(x)=\dfrac{x}{x+1}$ , $c\in\left(-\dfrac{1}{2},2\right)$

12.សហគ្រាសផលិតសម្ភារៈអេឡិចត្រូនិចមួយបានចំនាយប្រាក់សរុបក្នុងមួយថ្ងៃសំរាប់ផលិតសម្ភារៈ $x$ គ្រឿងដែលឱ្យអនុគមន៍ $C(x)=2400+28x+0.02x^2$ គិតជាពាន់រៀល ។

ក.កំនត់ប្រាក់ចំណាយសរុបក្នុងការផលិតសម្ភារៈ 10 គ្រឿង 20 គ្រឿង និង 30 គ្រឿង ។

ខ.ប៉ាន់ស្មានតម្លៃប្រហែលនៃប្រាក់ចំណាយក្នុងការផលិតសម្ភារៈគ្រឿងទី 11 គ្រឿងទី 21 និង គ្រឿងទី 31 ។

13.រោងពុម្ពបោះពុម្ពទស្សនាវដ្ដីមួយបានចំណាយសរុបក្នុងមួយខែសម្រាប់បោះពុម្ពទស្សនាវដ្ដី $x$ ច្បាប់ ដែលឱ្យតាមអនុគមន៍ $C(x)=0.0001x^2+x+465$ គិតជាពាន់រៀល ហើយរោងពុម្ពបានលក់ចេញវិញ ទស្សនាវដ្ដី 1 ច្បាប់ថ្លៃ $P=D(x)=4-0.0002x$ ពាន់រៀល ។

ក.សរសេរអនុគមន៍ប្រាក់ចំនូលសរុប $R(x)$ ។

ខ. សរសេរអនុគមន៍ប្រាក់ចំនេញសរុប $P(x)$ ។

គ.គណនាប្រាក់ចំនេញសរុបបើក្នុង មួយខែរោងពុម្ពលក់អស់ 3000 ច្បាប់ 3500 ច្បាប់ និង 4000 ច្បាប់ ។

ឃ..ប៉ាន់ស្មានតម្លៃប្រហែលនៃប្រាក់ចំនេញដែលបានពីការលក់ទស្សនាវដ្ដីច្បាប់ទី 3001 ច្បាប់ទី 3501 និងច្បាប់ទី 4001 ។

14. សហគ្រាសផលិតសម្ភារៈប្រើប្រាស់មួយបានចំនាយប្រាក់សរុបក្នុងការផលិតសម្ភារៈ $x$ គ្រឿង ឱ្យតាមអនុគមន៍ $C(x)=480+26x+-0.1x^2$ ពាន់រៀល ។

ក.កំណត់អនុគមន៍ប្រាក់ចំណាយមធ្យម $\overline{C}(x)$ ។

ខ.គណនាប្រាក់ចំណាយមធ្យមបន្ថែម

កាលណា $x = 30$ , $x = 50$ , $x = 70$ ។

15. សហគ្រាសផលិតសម្ភារៈអេឡិចត្រូនិចមួយបានចំនាយប្រាក់សរុបក្នុងការផលិតសម្ភារៈ $x$ គ្រឿង ដែលឱ្យអនុគមន៍ $C(x) = 1080 + 42x + 0.3x^2$ ពាន់រៀល ។ កំណត់បរិមាណសម្ភារៈដែលសហគ្រាសត្រូវផលិតដើម្បីឱ្យប្រាក់ចំណាយមធ្យមមានកំរិតអប្បបរមា បើ $0 \le x \le 90$ ។

16.ក្រុមហ៊ុនផលិតសម្ភារៈប្រើប្រាស់មួយបានចំណាយសរុបក្នុងការផលិតសម្ភារៈ $x$ គ្រឿងឱ្យយាមអនុគមន៍ $C(x) = x^2 + 20x + 1050$ ពាន់រៀល ហើយក្រុមហ៊ុនបានលក់ចេញវិញទទួលបានប្រាក់ចំណូលសរុបឱ្យតាមអនុគមន៍ $R(x) = 140x - 0.5x^2$ ពាន់រៀល ។ កំណត់កំរិតបរិមាណសម្ភារៈដែលក្រុមហ៊ុនត្រូវផលិតនិងលក់ដើម្បីឱ្យក្រុមហ៊ុនទទួលបានប្រាក់ចំនេញអតិបរិមា បើ $0 \le x \le 70$ ។

## ដំណោះស្រាយ

1.រក $dy\,,\Delta y\,,dy-\Delta y$ និង $\frac{dy}{\Delta y}$ នៃអនុមន៍ខាងក្រោម

ក.$y = x^2 - 3x + 4$ ចំពោះ $x = 3$ , $\Delta x = 0.2$

ខ.$y = \sqrt{12-5x}$ ចំពោះ $x = 2$ , $\Delta x = 0.07$ ។

**ដំណោះស្រាយ**

រក $dy\,,\Delta y\,,dy-\Delta y$ និង $\frac{dy}{\Delta y}$ នៃអនុមន៍ខាងក្រោម

ក.$y = x^2 - 3x + 4$ ចំពោះ $x = 3$ , $\Delta x = 0.2$

គេបាន $dy = y'.dx = (2x-3).dx$

ដោយ $x = 3$ , $\Delta x = 0.2 \approx dx$

គេបាន $dy = (2\times 2 - 3)(0.2) = 0.2$ ។

ហើយ $$\begin{aligned}\Delta y &= f(x+\Delta x) - f(x)\\ &= f(3+0.2) - f(3)\\ &= f(3.2) - f(3)\\ &= \left[(3.2)^2 - 3(3.2) + 4\right] - \left[(3)^2 - 3(3) + 4\right]\\ &= (5.2)(0.2) - 3(0.2) = (2.2)(0.2) = 0.044\end{aligned}$$

ហើយ $dy - \Delta y = 0.2 - 0.044 = 0.156$ និង $\frac{dy}{\Delta y} = \frac{0.2}{0.044} = 4.54$ ។

ខ. $y=\sqrt{12-5x}$ ចំពោះ $x=2$ , $\Delta x=0.07$ ។

គេបាន $dy=y'.dx=-\dfrac{5}{2\sqrt{12-5x}}.dx$

$$=-\frac{5}{2\sqrt{12-10}}(0.07)$$

$$=-\frac{0.35}{2\sqrt{2}}=-0.123$$

ហើយ $\Delta y=f(2+0.07)-f(2)$

$$=\sqrt{12-5(2.07)}-\sqrt{12-5(2)}$$

$$=\sqrt{1.65}-\sqrt{2}=1.284-1.414=-0.13$$

ហើយ $dy-\Delta y=-0.123+0.13=0.007$ និង $\dfrac{dy}{\Delta y}=0.946$ ។

2.ប្រើឌីផេរ៉ង់ស្យែល ដើម្បីរកតម្លៃប្រហែលនៃចំនួនខាងក្រោម៖

ក. $\sqrt{37}$ ខ. $\sqrt{65}$

គ. $\sqrt[3]{26}$ ឃ. $\sqrt[3]{126}$

ង. $\sqrt{50.4}$ ច. $\sqrt{79.5}$

ឆ. $\sqrt[3]{62.3}$ ជ. $\sqrt[3]{218.6}$

**ដំណោះស្រាយ**

ប្រើឌីផេរ៉ង់ស្យែល ដើម្បីរកតម្លៃប្រហែលនៃចំនួនខាងក្រោម៖

ក. $\sqrt{37}$

គេមាន $f(x+\Delta x)=f(x)+f'(x).dx$

តាងអនុគមន៍ $f(x)=\sqrt{x}\Rightarrow f'(x)=\frac{1}{2\sqrt{x}}$

យក $x=36\ ;\ \Delta x=1=dx$

គេបាន $\sqrt{37}=\sqrt{36}+\frac{1}{2\sqrt{36}}\times 1=6+\frac{1}{12}=6.08$ ។

ខ.$\sqrt{65}$

គេមាន $f(x+\Delta x)=f(x)+f'(x).dx$

តាងអនុគមន៍ $f(x)=\sqrt{x}\Rightarrow f'(x)=\frac{1}{2\sqrt{x}}$

យក $x=64\ ;\ \Delta x=1=dx$

គេបាន $\sqrt{65}=\sqrt{64}+\frac{1}{2\sqrt{64}}\times 1=8+\frac{1}{16}=8.06$ ។

គ.$\sqrt[3]{26}$

គេមាន $f(x+\Delta x)=f(x)+f'(x).dx$

តាងអនុគមន៍ $f(x)=\sqrt[3]{x}=x^{\frac{1}{3}}\Rightarrow f'(x)=\frac{1}{3\sqrt[3]{x^2}}$

យក $x=27\ ;\ \Delta x=-1=dx$

គេបាន $\sqrt[3]{26}=\sqrt[3]{27}-\frac{1}{3\sqrt[3]{27^2}}=3-\frac{1}{27}=2.96$ ។

ឃ. $\sqrt[3]{126}$

គេមាន $f(x+\Delta x)=f(x)+f'(x).dx$

តាងអនុគមន៍ $f(x)=\sqrt[3]{x}=x^{\frac{1}{3}}\Rightarrow f'(x)=\frac{1}{3\sqrt[3]{x^2}}$

យក $x=125\ ;\ \Delta x=1=dx$

គេបាន $\sqrt[3]{125}=\sqrt[3]{125}+\frac{1}{3\sqrt[3]{125^2}}=5+\frac{1}{75}=5.013$ ។

ង. $\sqrt{50.4}=7.099$

ច. $\sqrt{79.5}=8.916$

ឆ. $\sqrt[3]{62.3}=3.964$

ជ. $\sqrt[3]{218.6}=6.023$

3. ក្រុមហ៊ុនផលិតសម្ភារៈប្រើប្រាស់មួយបានទទួលប្រាក់ចំនូលសរុបពីការលក់ សម្ភារៈ $x$ គ្រឿងដែលឱ្យតាមអនុគមន៍

$R(x) = 20x - \frac{x^2}{30}$ គិតជាម៉ឺនរៀលដែល $0 \le x \le 600$ ។

ដោយប្រើឌីផេរ៉ង់ស្យែលប៉ាន់ស្មានតម្លៃប្រហែលនៃកំណើនប្រាក់ចំណូល បើ សម្ភារៈលក់ប្រែប្រួលពី 150 គ្រឿង ទៅ 160 គ្រឿង ។

**ដំណោះស្រាយ**

ដោយប្រើឌីផេរ៉ង់ស្យែលប៉ាន់ស្មានតម្លៃប្រហែលនៃកំណើនប្រាក់ចំណូល

តាង $y = R(x) = 20x - \frac{x^2}{30}$

បើ សម្ភារៈលក់ប្រែប្រួលពី 150 គ្រឿង ទៅ 160 គ្រឿងនោះ $\Delta x = 10$

គេបាន $dR(x) = R'(x).dx$ តែ $R'(x) = 20 - \frac{x}{15}$

នោះ $dR(x) = (20 - \frac{150}{15}).10 = 100$ (គិតជាម៉ឺនរៀល) ។

4. រោងចក្រផលិតសម្ភារៈប្រើប្រាស់មួយបានចំណាយប្រាក់សរុបក្នុងការ ផលិតសម្ភារៈ $x$ គ្រឿងដែលឱ្យតាមអនុគមន៍

$C(x) = 930 + 15x + 0.2x^2$ ពាន់រៀល ។

ដោយប្រើឌីផេរ៉ង់ស្យែលប៉ាន់ស្មានតម្លៃប្រហែលនៃកំណើនប្រាក់ចំណាយបើសម្ភារៈដែលបានផលិតកើនពី 60 គ្រឿង ទៅ 62 គ្រឿង ។

**ដំណោះស្រាយ**

ដោយប្រើឌីផេរ៉ង់ស្យែលប៉ាន់ស្មានតម្លៃប្រហែលនៃកំណើនប្រាក់ចំណាយបើសម្ភារៈដែលបានផលិតកើនពី 60 គ្រឿង ទៅ 62 គ្រឿងនោះ

$\Delta x = 2$ ។

ដោយ $C(x) = 930 + 15x + 0.2x^2$ នោះ $C'(x) = 15 + 0.4x$

គេបាន $dC(x) = C'(x).dx = (15 + 0.4 \times 60)(2) = 78$ (ពាន់រៀល)

5.សហគ្រាសផលិតសម្ភារៈអេឡិចត្រូនិចមួយ បានចំណាយប្រាក់សរុបក្នុងមួយខែសម្រាប់ផលិតសម្ភារៈ $x$ គ្រឿងដែលឱ្យតាមអនុគមន៍ $C(x) = 0.1x^2 + 4x + 200$ គិតជាពាន់រៀល ។ ហើយសហគ្រាសបានទទួលប្រាក់ចំណូលមកវិញឱ្យតាមអនុគមន៍ $R(x) = 54x - 0.3x^2$ គិតជាពាន់រៀល ។

ក.សរសេរអនុគមន៍ប្រាក់ចំណេញ $P(x)$

ខ.ដោយប្រើឌីផេរ៉ង់ស្យែលប៉ាន់ស្មានតម្លៃប្រហែលនៃកំណើនប្រាក់ចំណេញបើបរិមាណសម្ភារៈដែលបានលក់កើនពី 40 គ្រឿង ទៅ 44 គ្រឿង ។

## ដំណោះស្រាយ

ក.សរសេរអនុគមន៍ប្រាក់ចំណេញ $P(x)$

គេបាន $P(x) = R(x) - C(x)$

$P(x) = 54x - 0.3x^2 - 0.1x^2 - 4x - 200$

ដូចនេះ $P(x) = -0.4x^2 + 50x - 200$ ។

ខ.ដោយប្រើឌីផេរ៉ង់ប៉ាន់ស្មានតម្លៃប្រហែលនៃកំណើនប្រាក់ចំណេញ

បើបរិមាណសម្ភារៈដែលបានលក់កើនពី 40 គ្រឿង ទៅ 44 គ្រឿង

នោះ $\Delta x = 44 - 40 = 4$ គ្រឿង ។

គេបាន $dP(x) = P'(x).dx$

ដោយ $P'(x) = -0.8x + 50$

គេបាន $dP(x) = (-0.8 \times 40 + 50)(4) = 72$ (គិតជាពាន់រៀល)

6.តាមការអង្កេតរបស់អ្នកស្ថិតិបានឱ្យដឹងថា ចំនួនប្រជាពលរដ្ឋនៅក្នុងទីក្រុង

មួយរយៈពេល $t$ ឆ្នាំទៅមុខទៀត មានការកើនឡើងដែលឱ្យតាមអនុគមន៍

$P(t) = 10(40 + 2t)^2 - 160t$ (នាក់) ។

ដោយប្រើឌីផេរ៉ង់ស្យែលដើម្បីប៉ាន់ស្មានកំណើនប្រជាពលរដ្ឋក្នុងទីក្រុងនោះ

បើ $t$ ប្រែប្រួលពី 6 ទៅ 6.25 ឆ្នាំ ។

**ដំណោះស្រាយ**

ដោយប្រើឌីផេរ៉ង់ស្យែលដើម្បីប៉ាន់ស្មានកំណើនប្រជាពលរដ្ឋក្នុងទីក្រុងនោះ

បើ t ប្រែប្រួលពី 6 ទៅ 6.25 ឆ្នាំនោះ $\Delta t = 6.25 - 6 = 0.25$ ឆ្នាំ

គេមាន $P(t) = 10(40+2t)^2 - 160t$

គេបាន $P'(t) = 40(40+2t) - 160$

ហើយ $dP(t) = P'(t).dt$

$$= \left[40(40+2\times 6) - 160\right](0.25) = 480 \text{ (នាក់)}$$

7.បាឡុងមួយមានរាងជាស្វ៊ែ ។ ប្រើឌីផេរ៉ង់ស្យែលដើម្បីគណនាតម្លៃប្រហែលនៃកំណើនមាឌបាឡុង បើពេលត្រូវកំដៅថ្ងៃបាឡុងរីកមាឌដែលកាំរបស់វាប្រែប្រួលពី 2m ទៅ 2.15m ។

**ដំណោះស្រាយ**

ប្រើឌីផេរ៉ង់ស្យែលដើម្បីគណនាតម្លៃប្រហែលនៃកំណើនមាឌបាឡុង

តាង $V(r)$ ជាមាឌរបស់បាឡុង ហើយ $r$ ជាកាំរបស់បាឡុង

គេមាន $V(r) = \frac{4\pi}{3}r^3 \Rightarrow V'(r) = 4\pi r^2$

ដោយ r ប្រែប្រួលពី 2m ទៅ 2.15m នោះ $\Delta r = 0.15\text{m}$

ហើយ $dV(r) = V'(r).dr$

$$= (4\times 3.14\times 2^2)(0.15) = 7.536m^3$$

8.គេឱ្យអនុគមន៍ f មានដេរីវេលើ $(-2,\infty)$ ដែល $f(x)=\sqrt{x+2}$ ។

ក.រកតំលៃអមនៃ $f'(x)$ ចំពោះគ្រប់ $x\in[-1,2]$ ។

ខ.បង្ហាញថា ចំពោះគ្រប់ $x\in[-1,2]$

គេបាន $\frac{1}{4}x+\frac{5}{4}\le\sqrt{x+2}\le\frac{1}{2}x+\frac{3}{2}$ ។

**ដំណោះស្រាយ**

ក.រកតំលៃអមនៃ $f(x)$ ចំពោះគ្រប់ $x\in[-1,2]$

$$f(x)=\sqrt{x+2}\Rightarrow f'(x)=\frac{1}{2\sqrt{x+2}}$$

គេមាន $-1\le x\le 2\Rightarrow 1\le x+2\le 4$ ឬ $1\le\sqrt{x+2}\le 2$

គេទាញ $\frac{1}{4}\le\frac{1}{2\sqrt{x+2}}\le\frac{1}{2}$

ដូចនេះ $\frac{1}{4}\le f'(x)\le\frac{1}{2}$ ។

ខ.បង្ហាញថា $\frac{1}{4}x+\frac{5}{4}\le\sqrt{x+2}\le\frac{1}{2}x+\frac{3}{2}$ ចំពោះគ្រប់ $x\in[-1,2]$

តាមវិសមភាពកំណើនមានកំណត់ចំពោះអនុគមន៍ f ក្នុង $x\in[-1,2]$

គេបាន $\frac{1}{4}(x+1)\le f(x)-f(-1)\le\frac{1}{2}(x+1)$ តែ $f(-1)=1$

$$\frac{1}{4}x+\frac{1}{4}\le\sqrt{x+2}-1\le\frac{1}{2}x+\frac{1}{2}$$

ដូចនេះ $\frac{1}{4}x+\frac{5}{4}\le\sqrt{x+2}\le\frac{1}{2}x+\frac{3}{2}$ ។

9.គេឱ្យអនុគមន៍ f កំណត់លើ $\left[0,\frac{\pi}{2}\right)$ ដែល $f(x)=\tan x$ ។

បង្ហាញចំពោះគ្រប់ចំនួនពិត a និង b ដែល $0\le a\le b<\frac{\pi}{2}$

គេបាន $\frac{b-a}{\cos^2 a}\le\tan b-\tan a\le\frac{b-a}{\cos^2 b}$ ។

**ដំណោះស្រាយ**

បង្ហាញចំពោះគ្រប់ចំនួនពិត a និង b ដែល $0\le a\le b\le\frac{\pi}{2}$

គេបាន $\frac{b-a}{\cos^2 a}\le\tan b-\tan a\le\frac{b-a}{\cos^2 b}$

គេមាន $f(x)=\tan x\Rightarrow f'(x)=\frac{1}{\cos^2 x}$

ចំពោះ $0\le a\le b<\frac{\pi}{2}$ បើ $a\le x\le b$ នោះ $\cos b\le\cos x\le\cos a$

ឬ $\frac{1}{\cos^2 a}\le f'(x)\le\frac{1}{\cos^2 b}$

ដោយអនុវត្តន៍វិសមភាពកំណើនមានកំណត់ទៅនឹងអនុគមន៍ f

ចំពោះ $x\in[a\ ,\ b\ ]$ គេបាន

$$\frac{1}{\cos^2 a}(b-a)\le f(b)-f(a)\le\frac{1}{\cos^2 b}(b-a)$$

ដូចនេះ $\frac{b-a}{\cos^2 a}\le\tan b-\tan a\le\frac{b-a}{\cos^2 b}$ ។

10.គេឱ្យអនុគមន៍ f កំណត់លើចន្លោះ I ។ ប្រើទ្រឹស្តីបទរ៉ូល (បើអាច)

រកគ្រប់តម្លៃ c ក្នុងចន្លោះ I ដែល $f'(c)=0$ :

ក. $f(x)=x^3-4x \quad , \quad c\in(-2,2)$

ខ. $f(x)=(x-1)(x-2)(x-3) \quad , \quad c\in(1,3)$

គ. $f(x)=\dfrac{x^2-2x-3}{x+2} \quad , \quad c\in(-1,3)$

ឃ. $f(x)=\dfrac{x^2-1}{x} \quad , \quad c\in(-1,1)$

ង. $f(x)=\sin 2x \quad , \quad c\in\left(\dfrac{\pi}{6},\dfrac{\pi}{3}\right)$

ច. $f(x)=\dfrac{x}{2}-\sin\dfrac{\pi x}{6} \quad , \quad c\in(-1,0)$ ។

**ដំណោះស្រាយ**

រកគ្រប់តម្លៃ c ក្នុងចន្លោះ I ដែល $f'(c)=0$ :

ក. $f(x)=x^3-4x \quad , \quad c\in(-2,2)$

គេមាន $f(x)$ ជាអនុគមន៍ពហុធាជាប់គ្រប់ $x\in(-2\ ,\ 2)$ ហើយ

$f(-2)=f(2)=0$ ។ តាមទ្រឹស្តីបទរ៉ូលមានចំនួន $c\in(-2\ ,\ 2\ )$

ដែល $f'(c)=0$ ។ គេមាន $f'(c)=3c^2-4$

បើ $f'(c)=0 \Rightarrow 3c^2-4=0 \Rightarrow c_1=-\frac{2\sqrt{3}}{3}$ , $c_2=\frac{2\sqrt{3}}{3}$

ខ.$f(x)=(x-1)(x-2)(x-3)$ , $c\in(1,3)$

គេមាន $f(x)$ ជាអនុគមន៍ពហុធាជាប់គ្រប់ $x\in(1\ ,\ 3)$ ហើយ

$f(1)=f(3)=0$ ។ តាមទ្រឹស្តីបទរ៉ូលមានចំនួន $c\in(1\ ,\ 3\ )$

ដែល $f'(c)=0$ ។

គេមាន $f(x)=(x-1)(x-2)(x-3)=x^3-6x^2+11x-6$

គេបាន $f'(x)=3x^2-12x+11$

បើ $f'(c)=0 \Rightarrow 3c^2-12c+11=0$

$\Delta'=36-33=3>0 \Rightarrow c_1=\frac{6-\sqrt{3}}{3}$ , $c_2=\frac{6+\sqrt{3}}{3}$ ។

គ.$f(x)=\frac{x^2-2x-3}{x+2}$ , $c\in(-1,3)$

គេមាន $f(x)$ ជាអនុគមន៍ពហុធាជាប់គ្រប់ $x\in(-1\ ,\ 3)$ ហើយ

$f(-1)=f(3)=0$ ។ តាមទ្រឹស្តីបទរ៉ូលមានចំនួន $c\in(1\ ,\ 3\ )$

ដែល $f'(c)=0$ ។

គេមាន $f'(x)=\frac{(2x-2)(x+2)-(x^2-2x-3)}{(x+2)^2}$

$$=\frac{2x^2+4x-2x-4-x^2+2x+3}{(x+2)^2}$$

$$=\frac{x^2+4x-1}{(x+2)^2}$$

បើ $f'(c)=\frac{c^2+4c-1}{(c+2)^2}=0$ នាំឱ្យ $c^2+4c-1=0$

$\Delta'=4+1=5>0 \Rightarrow c_1=2+\sqrt{5}$ , $c_2=2-\sqrt{5}$

ដូចនេះ $c_1=2+\sqrt{5}$ , $c_2=2-\sqrt{5}$ ។

11.គេឱ្យអនុគមន៍f កំណត់លើចន្លោះ I ។ ប្រើទ្រឹស្តីបទតម្លៃមធ្យម រកគ្រប់តម្លៃ $c\in(a,b)$ ដែល $f'(c)=\frac{f(b)-f(a)}{b-a}$ :

ក.$f(x)=x^2$ , $c\in(-2,1)$

ខ.$f(x)=x(x^2-x-2)$ , $c\in(-1,1)$

គ.$f(x)=x^3$ , $c\in(0,1)$

ឃ.$f(x)=\frac{x}{x+1}$ , $c\in\left(-\frac{1}{2},2\right)$

**ដំណោះស្រាយ**

រកគ្រប់តម្លៃ $c\in(a,b)$ ដែល $f'(c)=\frac{f(b)-f(a)}{b-a}$ :

ក.$f(x)=x^2$ , $c\in(-2,1)$

គេមាន $f'(x)=2x$

គេបាន $f'(c)=2c=\dfrac{f(1)-f(-2)}{1-(-2)}=\dfrac{1-4}{1+2}=-1$

គេទាញ $c=-\dfrac{1}{2}$ ។

ខ.$f(x)=x(x^2-x-2)$ , $c\in(-1,1)$

គេមាន $f(x)=x^3-x^2-2x \Rightarrow f'(x)=3x^2-2x-2$

គេបាន $f'(c)=3c^2-2c-2=\dfrac{f(1)-f(-1)}{1-(-1)}=\dfrac{-2-0}{2}=-1$

គេទាញ $3c^2-2c-1=0 \Rightarrow c_1=-\dfrac{1}{3}$ , $c_2=1$

ដោយ $c\in(-1,1)$ ដូចនេះ $c=-\dfrac{1}{3}$ ។

គ.$f(x)=x^3$ , $c\in(0,1)$

គេមាន $f'(x)=3x^2$

គេបាន $f'(c)=3c^2=\dfrac{f(1)-f(0)}{1-0}=1 \Rightarrow c=\pm\dfrac{\sqrt{3}}{3}$

ដោយ $c\in(0,1)$ ដូចនេះ $c=\dfrac{\sqrt{3}}{3}$ ។

ឃ.$f(x)=\dfrac{x}{x+1}$ , $c\in\left(-\dfrac{1}{2},2\right)$

គេមាន $f'(x)=\dfrac{1}{(x+1)^2}$

គេបាន $f'(c)=\frac{1}{(c+1)^2}=\frac{f(2)-f(-\frac{1}{2})}{2-(-\frac{1}{2})}=\frac{\frac{2}{3}+1}{\frac{5}{2}}=\frac{2}{3}$

គេទាញ $c_1=-1+\sqrt{\frac{3}{2}}$ , $c_2=-1-\sqrt{\frac{3}{2}}$ ។

12.សហគ្រាសផលិតសម្ភារះអេឡិចត្រូនិចមួយបានចំនាយប្រាក់សរុបក្នុង មួយថ្ងៃសំរាប់ផលិតសម្ភារះ $x$ គ្រឿងដែលឱ្យអនុគមន៏ $C(x)=2400+28x+0.02x^2$ គិតជាពាន់រៀល ។

ក.កំនត់ប្រាក់ចំណាយសរុបក្នុងការផលិតសម្ភារះ 10 គ្រឿង 20 គ្រឿង និង 30 គ្រឿង ។

ខ.ប៉ាន់ស្មានតម្លៃប្រហែលនៃប្រាក់ចំណាយក្នុងការផលិតសម្ភារះគ្រឿង ទី 11 គ្រឿងទី 21 និង គ្រឿងទី 31 ។

## ដំណោះស្រាយ

ក.កំនត់ប្រាក់ចំណាយសរុបក្នុងការផលិតសម្ភារះ 10 គ្រឿង 20 គ្រឿង និង 30 គ្រឿង

គេមាន $C(x)=2400+28x+0.02x^2$ (គិតជាពាន់រៀល)

-ប្រាក់ចំណាយសរុបក្នុងការផលិតសម្ភារះ 10 គ្រឿងគឺ

$C(10)=2400+280+2=2682$ ពាន់រៀល ។

-ប្រាក់ចំណាយសរុបក្នុងការផលិតសម្ភារៈ 20 គ្រឿងគឺ

$C(20) = 2400 + 560 + 8 = 2968$ ពាន់រៀល ។

-ប្រាក់ចំណាយសរុបក្នុងការផលិតសម្ភារៈ 30 គ្រឿងគឺ

$C(10) = 2400 + 540 + 18 = 2958$ ពាន់រៀល ។

ខ.ប៉ាន់ស្មានតម្លៃប្រហែលនៃប្រាក់ចំណាយក្នុងការផលិតសម្ភារៈគ្រឿងទី 11 គ្រឿងទី 21 និង គ្រឿងទី 31

គេមាន $C(x) = 2400 + 28x + 0.02x^2$ (គិតជាពាន់រៀល)

គេបាន $C'(x) = 28 + 0.04x$

-តម្លៃប្រហែលនៃប្រាក់ចំណាយក្នុងការផលិតសម្ភារៈគ្រឿងទី 11 គឺ

$C'(11) = 28 + 0.04 \times 11 = 28.44$ ពាន់រៀល ។

-តម្លៃប្រហែលនៃប្រាក់ចំណាយក្នុងការផលិតសម្ភារៈគ្រឿងទី 21 គឺ

$C'(21) = 28 + 0.04 \times 21 = 28.84$ ពាន់រៀល ។

-តម្លៃប្រហែលនៃប្រាក់ចំណាយក្នុងការផលិតសម្ភារៈគ្រឿងទី 31 គឺ

$C'(31) = 28 + 0.04 \times 31 = 29.24$ ពាន់រៀល ។

13.រោងពុម្ពបោះពុម្ពទស្សនាវដ្ដីមួយបានចំណាយសរុបក្នុងមួយខែសម្រាប់បោះពុម្ពទស្សនាវដ្ដី x ច្បាប់ ដែលឱ្យតាមអនុគមន៍

$C(x) = 0.0001x^2 + x + 465$ គិតជាពាន់រៀល ហើយរោងពុម្ពបានលក់

ចេញវិញ ទស្សនាវដ្តី 1 ច្បាប់ថ្លៃ $P = D(x) = 4 - 0.0002x$ ពាន់រៀល ។

ក.សរសេរអនុគមន៍ប្រាក់ចំនូលសរុប $R(x)$ ។

ខ. សរសេរអនុគមន៍ប្រាក់ចំនេញសរុប $P(x)$ ។

គ.គណនាប្រាក់ចំនេញសរុបបើក្នុង មួយខែរោងពុម្ពលក់អស់ 3000 ច្បាប់ 3500 ច្បាប់ និង 4000 ច្បាប់ ។

ឃ..ប៉ាន់ស្មានតម្លៃប្រហែលនៃប្រាក់ចំនេញដែលបានពីការលក់ ទស្សនាវដ្តីច្បាប់ទី 3001 ច្បាប់ទី 3501 និងច្បាប់ទី 4001 ។

**ដំណោះស្រាយ**

ក.សរសេរអនុគមន៍ប្រាក់ចំនូលសរុប $R(x)$

គេបាន $R(x) = P \times x = (4 - 0.0002x)x = 4x - 0.0002x^2$

ខ. សរសេរអនុគមន៍ប្រាក់ចំនេញសរុប $P(x)$

គេបាន $P(x) = R(x) - C(x)$

$$= 4x - 0.0002x^2 - 0.0001x^2 - x - 465$$

$$= -0.0003x^2 + 3x - 465$$

គ.គណនាប្រាក់ចំនេញសរុបបើក្នុង មួយខែរោងពុម្ពលក់អស់ 3000 ច្បាប់ 3500 ច្បាប់ និង 4000 ច្បាប់

-បើ $x = 3000$ ច្បាប់

នោះ $P(3000) = -0.0003(3000)^2 + 3(3000) - 465$

$= 5835$ ពាន់រៀល ។

-បើ $x = 3500$ ច្បាប់

នោះ $P(3500) = -0.0003(3500)^2 + 3(3500) - 465$

$= 6360$ ពាន់រៀល ។

-បើ $x = 4000$ ច្បាប់

នោះ $P(4000) = -0.0003(4000)^2 + 3(4000) - 465$

$= 6735$ ពាន់រៀល ។

ឃ.ប៉ាន់ស្មានតម្លៃប្រហែលនៃប្រាក់ចំនេញដែលបានពីការលក់ ទស្សនាវដ្ដីច្បាប់ទី 3001 ច្បាប់ទី 3501 និងច្បាប់ទី 4001 ។

គេមាន $P(x) = -0.0003x^2 + 3x - 465$

គេបាន $P'(x) = -0.0006x + 3$

-តម្លៃប្រហែលនៃប្រាក់ចំនេញបានពីការលក់ ទស្សនាវដ្ដីច្បាប់ទី 3001

គឺ $P'(3000) = -0.0006(3000) + 3 = 1.2$ ពាន់រៀល ។

-តម្លៃប្រហែលនៃប្រាក់ចំនេញបានពីការលក់ ទស្សនាវដ្ដីច្បាប់ទី 3501

គឺ $P'(3500) = -0.0006(3500) + 3 = 0.9$ ពាន់រៀល ។

-តម្លៃប្រហែលនៃប្រាក់ចំនេញបានពីការលក់ ទស្សនាវដ្តីច្បាប់ទី 4001

គឺ $P'(4000) = -0.0006(4000) + 3 = 0.6$ ពាន់រៀល ។

## ជំពូកទី៣ មេរៀនទី១

# អនុគមន៍អសនិទាន

**.អនុគមន៍** $y=\sqrt{ax+b}$ ដែល $a\neq 0$

ដែនកំណត់ : អនុគមន៍មានន័យកាលណា $ax+b\geq 0$

-បើ $a>0$ នោះ $x\geq -\frac{b}{a}$ ហើយ $D=[-\frac{b}{a},+\infty)$

-បើ $a<0$ នោះ $x\leq -\frac{b}{a}$ ហើយ $D=(-\infty\ ,-\frac{b}{a}]$

ដេរីវេ $y'=\frac{a}{2\sqrt{ax+b}}$

-បើ $a<0$ នោះ $y'<0$ នាំឱ្យអនុគមន៍ចុះជានិច្ចលើដែនកំណត់ ។

-បើ $a>0$ នោះ $y'>0$ នាំឱ្យអនុគមន៍កើនជានិច្ចលើដែនកំណត់ ។

**.អនុគមន៍** $y=\sqrt{ax^2+bx+c}$ មាន $\Delta=b^2-4ac$

◆ដែនកំណត់ : អនុគមន៍មានន័យកាលណា $ax^2+bx+c\geq 0$

**_ករណី** $a>0$

ក្រាបនៃ $y=ax^2+bx+c$ មានអាស៊ីមតូតទ្រេតពីរគឺ

ក-បើ $x\to+\infty$ នោះ $y=\sqrt{a}(x+\frac{b}{2a})$ ជាអាស៊ីមតូតទ្រេត ។

ក-បើ $x \to -\infty$ នោះ $y = -\sqrt{a}(x + \frac{b}{2a})$ ជាអាស៊ីមតូតទ្រេត

**_ករណី** $a < 0$

ក្រាបនៃអនុគមន៍ $y = \sqrt{ax^2 + bx + c}$ គ្មានអាស៊ីមតូតទេ ។

◆ដេរីវេ $y' = \frac{2ax + b}{2\sqrt{ax^2 + bx + c}}$ មានសញ្ញាដូច $2ax + b$

-បើ $a < 0$ អនុគមន៍មានអតិបរមាមួយត្រង់ $x = -\frac{b}{2a}$ ។

-បើ $a > 0$ អនុគមន៍មានអប្បបរមាមួយត្រង់ $x = -\frac{b}{2a}$ ។

## លំហាត់

1.រកអាស៊ីមតូតទ្រេតរបស់អនុគមន៍ $y = 2x + 3 - \sqrt{4x^2 + x + 1}$ ។

2.រកដេរីវេនៃអនុគមន៍ខាងក្រោមៈ

ក.$y = (2x - 3)\sqrt{x^2 - 3x + 4}$

ខ.$y = \sqrt{x^2 + 6x + 5} + \frac{x^2}{2} + 3$ ។

3.សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោមៈ

ក.$y = 3x - 2 + \sqrt{x - 1}$ ខ.$y = x + \sqrt{x^2 - 3x + 2}$

4.ក.សិក្សាអថេរភាព និង សង់ក្រាប $(C)$ នៃអនុគមន៍ $y = \sqrt{9 - x^2}$ ។

ខ.រកចំនុចនឹង ដែលបន្ទាត់ $d_m : mx - y + 3 - 4m = 0$

កាត់តាមចំពោះគ្រប់តំលៃ $m$ ។

គ.ប្រើក្រាប $(C)$ ពិភាក្សាតាមតម្លៃ $m$ អត្ថិភាពនៃឫសរបស់សមីការ

$\sqrt{9 - x^2} - mx + 4m - 3 = 0$ ។

5.គេឱ្យអនុគមន៍ $y = mx + m^2 + \sqrt{x^2 + 1}$ ។

ក.ស្រាយបញ្ជាក់ថា អាស៊ីមតូតទ្រេតខាងស្តាំរបស់ក្រាបខាងលើ ប៉ះនឹង ប៉ារ៉ាបូលនឹងមួយ ។

ខ.បើ $m = 1$ សិក្សាអថេរភាពនិងសង់ក្រាប C របស់អនុគមន៍ខាងលើ ។

6. គេឱ្យអនុគមន៍ $y = \sqrt{2x(4-x)}$ ។

ក.សិក្សាអថេរភាព និង សង់ក្រាប C របស់អនុគមន៍ ។

ខ.ប្រើក្រាប C ពិភាក្សាតាមតម្លៃ m អត្ថិភាពនៃឬសរបស់សមីការ $\sqrt{2x(4x-x)} = mx + 2\sqrt{2} - 5m$ ។

7.ក.កំណត់តម្លៃ m ដើម្បីឱ្យសមីការ $x + \sqrt{2x^2+1} = m$ មានឬស ។

ខ.កំណត់តម្លៃ m ដើម្បីឱ្យវិសមីការ $x + \sqrt{2x^2+1} < m$ មានឬស ។

8. គេឱ្យអនុគមន៍ $y = f(x) = x + \sqrt{4x^2+2x+1}$ ។

ក.សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ ។

ខ.ប្រើក្រាបរកតម្លៃ m ដើម្បីឱ្យវិសមីការ $\sqrt{4x^2+2x+1} \le m - x$ មានឬស ។

9.គេឱ្យអនុគមន៍ $y = f(x) = \frac{x}{2} + \frac{1}{2}\sqrt{12-3x^2}$ ។

ក.សិក្សាអថេរភាព និង សង់ក្រាប C នៃអនុគមន៍ ។

ខ.ស្រាយបញ្ជាក់ $-2 \le x\sqrt{12-3x^2} \le 4$ ។

គ.ដោះស្រាយសមីការ $\sqrt{12-3x^2}=4-x$ រួចផ្ទៀងផ្ទាត់លទ្ធផលនៃសមីការដោយក្រាបនៃអនុគមន៍ខាងលើ ។

10. គេឱ្យអនុគមន៍ $y=x+\sqrt{2x^2+1}$ មានក្រាប C ។

ក.រកអាស៊ីមតូតទ្រេតរបស់ក្រាប C ។

ខ.តាមក្រាបរកតម្លៃ m

ដើម្បីឱ្យសមីការ $x+\sqrt{2x^2+1}=m$ មានឫស ។

11.គូបមួយ ABCDEFGH មានរង្វាស់ជ្រុង a ។ I ជាចំនុចកណ្តាលនៃ [AB] ហើយ J ជាចំនុចកណ្តាលនៃ [EH] ។ ចំនុច M មួយរត់នៅលើជ្រុងនៃគូប ។ រកចំងាយខ្លីបំផុតដែល M រត់ពី I ទៅ J ។

## ដំណោះស្រាយ

1.រកអាស៊ីមតូតទ្រេតរបស់អនុគមន៍ $y = 2x + 3 - \sqrt{4x^2 + x + 1}$ ។

**ដំណោះស្រាយ**

រកអាស៊ីមតូតទ្រេត

គេមាន $y = 2x + 3 - \sqrt{4x^2 + x + 1}$

គេបាន $y = 2x + 3 - \sqrt{4}\,|x + \frac{1}{8}| + \varepsilon(x)$ ដែល $\lim_{x \to \pm\infty} \varepsilon(x) = 0$

-បើ $x \to +\infty$

នោះ $y = 2x + 3 - 2(x + \frac{1}{8}) = \frac{11}{4}$ ជាអាស៊ីមតូតដេករបស់ក្រាប ។

-បើ $x \to -\infty$

នោះ $y = 2x + 3 + 2(x + \frac{1}{8}) = 4x + \frac{13}{4}$ ជាអាស៊ីមតូតទ្រេត ។

2.រកដេរីវេនៃអនុគមន៍ខាងក្រោម៖

ក.$y = (2x - 3)\sqrt{x^2 - 3x + 4}$

ខ.$y = \sqrt{x^2 + 6x + 5} + \frac{x^2}{2} + 3$ ។

## ដំណោះស្រាយ

**រកដេរីវេនៃអនុគមន៍ខាងក្រោម៖**

ក. $y = (2x-3)\sqrt{x^2-3x+4}$

គេបាន $y' = (2x-3)'\sqrt{x^2-3x+4} + (\sqrt{x^2-3x+4})'(2x-3)$

$$= 2\sqrt{x^2-3x+4} + \frac{(2x-3)^2}{2\sqrt{x^2-3x+4}}$$

$$= \frac{4x^2-12x+16+4x^2-12x+9}{2\sqrt{x^2-3x+4}}$$

$$= \frac{8x^2-24x+25}{2\sqrt{x^2-3x+4}}$$

ខ. $y = \sqrt{x^2+6x+5} + \frac{x^2}{2} + 3$

គេបាន $y' = \frac{2x+6}{2\sqrt{x^2+6x+5}} + x$

$$= \frac{x+3}{\sqrt{x^2+6x+5}} + x$$

$$= \frac{x+3+x\sqrt{x^2+6x+5}}{\sqrt{x^2+6x+5}}$$

ដូចនេះ $y' = \frac{x+3+x\sqrt{x^2+6x+5}}{\sqrt{x^2+6x+5}}$ ។

3.សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោម៖

ក.$y = 3x - 2 + \sqrt{x - 1}$ ខ.$y = x + \sqrt{x^2 - 3x + 2}$

## ដំណោះស្រាយ

សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោម៖

ក.$y = 3x - 2 + \sqrt{x - 1}$

ដែនកំណត់ $D = [1, +\infty)$

ទិសដៅអថេរភាព

-ដេរីវេ $y' = 3 + \dfrac{1}{2\sqrt{x - 1}}$

-ចំពោះគ្រប់ $x > 1$ គេបាន $y' > 0$ នាំឱ្យ $y$ ជាអនុគមន៍កើន ។

គណនាលីមីត ៖ $\lim\limits_{x \to +\infty} (3x - 2 + \sqrt{x - 1}) = +\infty$ ។

តារាងអថេរភាព

| $x$ | $1$ $\qquad\qquad$ $+\infty$ |
|---|---|
| $y'$ | $+$ |
| $y$ | $0$ $\nearrow$ $+\infty$ |

## សំណង់ក្រាប




ខ. $y = x + \sqrt{x^2 - 3x + 2}$



4.ក.សិក្សាអថេរភាព និង សង់ក្រាប $(C)$ នៃអនុគមន៍ $y = \sqrt{9 - x^2}$ ។

ខ.រកចំនុចនឹង ដែលបន្ទាត់ $d_m : mx - y + 3 - 4m = 0$

កាត់តាមចំពោះគ្រប់តំលៃ $m$ ។

គ.ប្រើក្រាប $(C)$ ពិភាក្សាតាមតម្លៃ $m$ អត្ថិភាពនៃឫសរបស់សមីការ

$\sqrt{9 - x^2} - mx + 4m - 3 = 0$

**ដំណោះស្រាយ**

ក.សិក្សាអថេរភាព និង សង់ក្រាប $(C)$ នៃអនុគមន៍ $y = \sqrt{9 - x^2}$

ដែនកំណត់ $D = [-3\ ,\ 3\ ]$

ទិសដៅអថេរភាព

$$y' = \frac{-2x}{2\sqrt{9 - x^2}} = -\frac{x}{\sqrt{9 - x^2}}$$

បើ $y' = 0 \Rightarrow x = 0$

អនុគមន៍មានអតិបរមាធៀបត្រង់ $x = 0$ គឺ $y = (0) = 3$

តារាងអថេរភាព

| x | $-3$ | | 0 | | 3 |
|---|---|---|---|---|---|
| y' | | + | 0 | — | |
| y | 0 | ↗ | 3 | ↘ | 0 |

សំណង់ក្រាប




ខ.រកចំនុចនឹង ដែលបន្ទាត់ $d_m : mx - y + 3 - 4m = 0$

កាត់តាមចំពោះគ្រប់តំលៃ m

គេអាចសរសេរ $y - 3 = m(x - 4)$

សមីការនេះផ្ទៀងផ្ទាត់ជានិច្ចគ្រប់ m សមមូល $x = 4$ , $y = 3$

ដូចនេះ $I(4 ; 3)$ ជាចំនុចនឹង ។

គ.ប្រើក្រាប (C) ពិភាក្សាតាមតម្លៃ m អត្ថិភាពនៃឬសរបស់សមីការ

$\sqrt{9 - x^2} - mx + 4m - 3 = 0$ ជាសមីការអាប់ស៊ីសចំណុចប្រសព្វ

រវាង $(C) : y = \sqrt{9 - x^2}$ នឹង $d_m : y = mx - 4m + 3$

តាមក្រាហ្វិកគេបាន :

-ចំពោះ $m = 0$ សមីការមានឬសឌុប $x_1 = x_2 = 0$ ។

-ចំពោះ $m = \frac{3}{7}$ សមីការមានឬសតែមួយគត់គឺ $x = -3$ ។

-ចំពោះ $m = 3$ សមីការមានឬសតែមួយគត់គឺ $x = 3$ ។

-ចំពោះ $m \in (\frac{3}{7}, 3)$ សមីការមានឬសតែមួយគត់គឺ $-3 < x < 3$

-ចំពោះ $m > 3$ ឬ $m < 0$ សមីការគ្មានឬស ។

5.គេឱ្យអនុគមន៍ $y = mx + m^2 + \sqrt{x^2 + 1}$ ។

ក.ស្រាយបញ្ជាក់ថា អាស៊ីមតូតទ្រេតខាងស្ដាំរបស់ក្រាបខាងលើ ប៉ះនឹងប៉ារ៉ាបូលនឹងមួយ ។

គេមាន $y = mx + m^2 + \sqrt{x^2 + 1}$

$$y = mx + m^2 + |x| + \varepsilon(x) \text{ ដែល } \lim_{x \to \pm\infty} \varepsilon(x) = 0$$

គេទាញ $y = mx + m^2 + x = (m+1)x + m^2$ ជាអាស៊ីមតូតខាងស្ដាំរបស់ក្រាបតាង $y = mx + m^2 + \sqrt{x^2 + 1}$ ។

យក $P : y = ax^2 + bx + c$ ជាប៉ារ៉ាបូលនឹងត្រូវរក

សមីការអាប់ស៊ីស $ax^2 + bx + c = (m+1)x + m^2$

ឬ $ax^2 + (b - m - 1)x + c - m^2 = 0$ (E)

សមីការ (E) មានឬសឌុបគ្រប់ $m$ លុះត្រាតែ $\Delta = 0 \ \forall m \in IR$

$\Delta = (b - m - 1)^2 - 4a(c - m^2)$

$\Delta = b^2 - 2b(m+1) + (m+1)^2 - 4ac + 4am^2$

$= b^2 - 2mb - 2b + m^2 + 2m + 1 - 4ac + 4am^2$

$= (1 + 4a)m^2 + (2 - 2b)m + (b - 1)^2 - 4ac$

បើ $\Delta = 0 \ \forall m \in IR$ សមមូល $\begin{cases} a = -\frac{1}{4} \\ b = 1 \\ c = 0 \end{cases}$

គេបាន $P : y = -\frac{x^2}{4} + x$ ។

ខ.បើ $m = 1$ សិក្សាអថេរភាពនិងសង់ក្រាប $C$ របស់អនុគមន៍ខាងលើ

ចំពោះ $m = 1$ គេបាន $y = x + 1 + \sqrt{x^2 + 1}$



# ជំពូកទី៣

# អនុគមន៍ត្រីកោណមាត្រច្រាស

## .ចំណុចសំខាន់ៗសម្រាប់សិក្សាអនុគមន៍ត្រីកោណមាត្រ

-ដែនកំណត់

-ខួបនៃអនុគមន៍

-ភាពគូសេសនៃអនុគមន៍

-ទិសដៅអថេរភាពនៃអនុគមន៍

## .ខួបនៃអនុគមន៍

-ខួបនៃអនុគមន៍ $y = \sin(ax)$ គឺ $\frac{2\pi}{|a|}$

-ខួបនៃអនុគមន៍ $y = \cos(ax)$ គឺ $\frac{2\pi}{|a|}$

## .ភាពគូសេសនៃអនុគមន៍

-អនុគមន៍ $f(x)$ ជាអនុគមន៍សេសលើ $I$ កាលណា $\forall x \in I$ , $-x \in I$ ហើយ $f(-x) = -f(x)$ ។

-អនុគមន៍ $f(x)$ ជាអនុគមន៍គូលើ $I$ កាលណា $\forall x \in I$ , $-x \in I$ ហើយ $f(-x) = f(x)$ ។

## លំហាត់

1.សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ $y = \cos^2 .\sin 2x$ ។

2. សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោមៈ

ក.$y = 2\sin x - 3\cos x$ ខ.$y = 5\sin x + \cos x$ ។

3.សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោមៈ

ក.$y = \cos 2x - \cos 3x$ ខ.$y = 2x\cos 2x - \sin x$ ។

4.សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍

ក.$y = 2\sin x - \sin 2x$ ខ.$y = \cos^2 x + x\sin x$ ។

5. សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍

ក.$y = \dfrac{1 - \sin x}{\cos x}$ ខ.$y = \dfrac{\cos x - 1}{\sin x}$ ។

6. រកបរិមានៃអនុគមន៍ $y = \dfrac{\sin x}{2 + \cos x}$ លើចន្លោះ $[0, 2]$ ។

7.ប្រើក្រាបនៃ $y = \sin 2x - 3\sin x$ ដោះស្រាយសមីការ

$\sin 2x - 3\sin x = 0$ បើ $-2\pi \le x \le 2\pi$ ។

8. គេឱ្យអនុគមន៍ $y = a\sin 2x + \sin x$ ។

សិក្សាអថេរភាព និង សង់ក្រាបចំពោះ $a = 1$ ។

9.គេឱ្យអនុគមន៍ $y = \dfrac{a\sin x - \cos x - 1}{a\cos x}$ ។

សិក្សាអថេរភាព និង សង់ក្រាបចំពោះ $a = 1$ ។

លំហាត់ជំពូក ៣

1. សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោម៖

ក.$y = \sqrt{3x - 5}$ ខ.$y = \sqrt{7 - 4x}$ ។

2. សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោម៖

ក.$y = 2 + \sqrt{x^2 - 2x - 3}$ ខ.$y = 2 + \sqrt{8 - 2x^2}$ ។

3. សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោម៖

ក.$y = 2x - 1 - \sqrt{3x - 5}$ ខ.$y = x + 1 - \sqrt{4 - x^2}$ ។

4. សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោម៖

ក.$y = f(x) = \sin x + 2\sin\dfrac{x}{2}$ ខ.$y = f(x) = \dfrac{\cos x - 1}{2\cos x + 1}$ ។

5. សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍

$y = f(x) = \sqrt{3}\sin x + \cos x$

6.គេឱ្យអនុគមន៍ $y = -2x + m\sqrt{x^2 + 1}$

ក.សិក្សាអថេរភាព និង សង់ក្រាបចំពោះ $m = 4$ ។

ខ.រកតម្លៃ $m$ ដើម្បីឱ្យអនុគមន៍គ្មានតម្លៃបរមា ។

## ដំណោះស្រាយ

1.សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ $y=\cos^2 x.\sin 2x$ ។

**ដំណោះស្រាយ**

សិក្សាអថេរភាព និង សង់ក្រាប

$y=\cos^2 x.\sin 2x$

.ដែនកំណត់ $D=IR$

.ខួប : គេមាន $y=\cos^2 x\sin 2x=\frac{1}{2}(1+\cos 2x)\sin 2x$

អនុគមន៍មានខួប $p=\pi$

ព្រោះ $f(x+\pi)=\frac{1}{2}[1+\cos(2\pi+2x)]\sin(2\pi+2x)$

$$=\frac{1}{2}(1+\cos 2x)\sin 2x=f(x)$$

.ភាពគូសេស :

$f(x)$ ជាអនុគមន៍សេសព្រោះ $f(-x)=\cos^2(-x)\sin(-x)$

$$=-\cos^2 x\sin x$$

$$=-f(x)$$

ដូចនេះគេសិក្សាតែក្នុងចន្លោះ $[0,\frac{\pi}{2}]$

.ទិសដៅអថេរភាព

ដេរីវេ $f'(x)=\frac{1}{2}(1+\cos 2x)'\sin 2x+\frac{1}{2}(\sin 2x)'(1+\cos 2x)$

$$=-\sin^2 2x+\cos 2x(1+\cos 2x)$$

$$=-1+\cos^2 2x+\cos 2x+\cos^2 2x$$

$$=2\cos^2 2x+\cos 2x-1$$

$$=(2\cos 2x-1)(\cos 2x+1)$$

ដោយគ្រប់ $x\in IR:-1\le \cos 2x\le 1$ នោះ $\cos 2x+1\ge 0$

នាំឱ្យ $f'(x)$ មានសញ្ញាដូច $2\cos 2x-1$

-បើ $2\cos 2x-1=0\Rightarrow \cos 2x=\frac{1}{2}$ ឬ $2x=\frac{\pi}{3}\Rightarrow x=\frac{\pi}{6}$

-បើ $2\cos 2x-1>0\Rightarrow \cos 2x>\frac{1}{2}$ ឬ $0<x<\frac{\pi}{6}$

-បើ $2\cos 2x-1<0\Rightarrow \cos 2x<\frac{1}{2}$ ឬ $\frac{\pi}{6}<x<\frac{\pi}{2}$

តារាងអថេរភាព

| $x$ | $0$ | | $\frac{\pi}{6}$ | | $\frac{\pi}{2}$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | \| | $-$ | |
| $f(x)$ | $0$ | $\nearrow$ | $f(\frac{\pi}{6})$ | $\searrow$ | $0$ |

ក្នុងចន្លោះ $(0,\frac{\pi}{2})$ អនុគមន៍មានអតិបរមា $f(\frac{\pi}{6})=\frac{3\sqrt{3}}{8}$ ។

ចំពោះ $x=\frac{\pi}{2}$ គេបាន $f'(\frac{\pi}{2})=0$ និង $f(\frac{\pi}{2})=0$ ។

ដូចនេះត្រង់ $x=\frac{\pi}{2}$ ក្រាប (c) មានអក្ស័ (ox) ជាបន្ទាត់ប៉ះ ។



2. សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោម:

ក. $y = 2\sin x - 3\cos x$ ខ. $y = 5\sin x + \cos x$ ។

**ដំណោះស្រាយ**

សិក្សាអថេរភាព និង សង់ក្រាប

ក. $y = 2\sin x - 3\cos x$




ខ. $y = 5\sin x + \cos x$



## 3.សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោមៈ

ក.$y = \cos 2x - \cos 3x$ ខ.$y = 2x\cos 2x - \sin x$ ។

### ដំណោះស្រាយ

ក.$y = \cos 2x - \cos 3x$




ខ.$y = 2x\cos 2x - \sin x$



## 4.សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍

ក.$y = 2\sin x - \sin 2x$ ខ.$y = \cos^2 x + x\sin x$ ។

### ដំណោះស្រាយ

ក.$y = 2\sin x - \sin 2x$




ខ.$y = \cos^2 x + x\sin x$



## 5. សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍

ក. $y=\frac{1-\sin x}{\cos x}$ ខ. $y=\frac{\cos x-1}{\sin x}$ ។

### ដំណោះស្រាយ

ក. $y=\frac{1-\sin x}{\cos x}$




ខ. $y=\frac{\cos x-1}{\sin x}$



6. គេឱ្យអនុគមន៍ $y = a\sin 2x + \sin x$ ។

សិក្សាអថេរភាព និង សង់ក្រាបចំពោះ $a = 1$ ។

**ដំណោះស្រាយ**

សង់ក្រាបចំពោះ $a = 1$

គេបាន $y = \sin 2x + \sin x$




7.គេឱ្យអនុគមន៍ $y = \dfrac{a\sin x - \cos x - 1}{a\cos x}$ ។

សិក្សាអថេរភាព និង សង់ក្រាបចំពោះ $a = 1$ ។

**ដំណោះស្រាយ**

សង់ក្រាបចំពោះ $a = 1$

គេបាន $y = \dfrac{\sin x - \cos x - 1}{\cos x} = -1 + \dfrac{\sin x - 1}{\cos x}$


y
1
0
1
x

## លំហាត់ជំពូក៣ និងដំណោះស្រាយ

1. សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោម៖

ក. $y = \sqrt{3x-5}$ ខ. $y = \sqrt{7-4x}$ ។

### ដំណោះស្រាយ

សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍

ក. $y = \sqrt{3x-5}$

.ដែនកំណត់ $D = [\frac{5}{3}, +\infty)$

.ទិសដៅអថេរភាព

ដេរីវេ $y' = \frac{3}{2\sqrt{3x-5}}$

ចំពោះ $x > \frac{5}{3}$ គេបាន $y' > 0$ នាំឱ្យវាជាអនុគមន៍កើនលើ $(\frac{5}{3}, +\infty)$

លីមីត $\lim_{x\to+\infty} \sqrt{3x-5} = +\infty$

តារាងអថេរភាព

| x | $\frac{5}{3}$ | | $+\infty$ |
|---|---|---|---|
| y' | ‖ | + | |
| y | 0 | ↗ | $+\infty$ |



ខ.$y=\sqrt{7-4x}$

.ដែនកំណត់ $D=(-\infty,\frac{7}{4}]$

.ទិសដៅអថេរភាព

ដេរីវេ $y'=\frac{-2}{\sqrt{7-4x}}$

ចំពោះ $x<\frac{7}{4}$ គេបាន $y'<0$ នាំឱ្យវាជាអនុគមន៍ចុះលើ $(-\infty,\frac{7}{4})$

លីមីត $\lim\limits_{x\to-\infty}\sqrt{7-4x}=+\infty$

តារាងអថេរភាព

| x | $-\infty$ | $\frac{7}{4}$ |
|---|---|---|
| y' | − | ‖ |
| y | $+\infty$ ↘ | 0 |



2. សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោមៈ

ក. $y = 2 + \sqrt{x^2 - 2x - 3}$ ខ. $y = 2 + \sqrt{8 - 2x^2}$ ។

## ដំណោះស្រាយ

សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍

ក. $y = 2 + \sqrt{x^2 - 2x - 3}$




ខ. $y = 2 + \sqrt{8 - 2x^2}$



3. សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោម៖

ក. $y = 2x - 1 - \sqrt{3x-5}$ ខ. $y = x + 1 - \sqrt{4 - x^2}$ ។

**ដំណោះស្រាយ**

សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍

ក. $y = 2x - 1 - \sqrt{3x-5}$




ខ. $y = x + 1 - \sqrt{4 - x^2}$



4. សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍ខាងក្រោម៖

ក. $y = f(x) = \sin x + 2\sin\frac{x}{2}$ ខ. $y = f(x) = \frac{\cos x - 1}{2\cos x + 1}$ ។

**ដំណោះស្រាយ**

សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍

ក. $y = f(x) = \sin x + 2\sin\frac{x}{2}$




ខ. $y = f(x) = \frac{\cos x - 1}{2\cos x + 1}$



5. សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍

$$y = f(x) = \sqrt{3}\sin x + \cos x$$

**ដំណោះស្រាយ**

សិក្សាអថេរភាព និង សង់ក្រាបនៃអនុគមន៍

$$y = f(x) = \sqrt{3}\sin x + \cos x$$



ជំពូកទី៤ មេរៀនទី១

# អាំងតេក្រាលកំណត់

## .និយមន័យ

$f$ ជាអនុគមន៍ជាប់លើចន្លោះ $[a,b]$ ។

អាំងតេក្រាលកំណត់ពី $a$ ទៅ $b$ នៃ $y=f(x)$ កំណត់ដោយ

$$\int_a^b f(x).dx = F(b)-F(a)$$ ដែល $F'(x)=f(x)$ ។

## .ផ្ទៃក្រឡានៃផ្ទៃកប្លង់

-បើអនុគមន៍ $y=f(x)$ ជាប់លើចន្លោះ $[a,b]$ នោះផ្ទៃក្រឡានៃផ្ទៃកប្លង់ដែលខណ្ឌដោយខ្សែកោង អក្ស័អាប់ស៊ីស បន្ទាត់ឈរ $x=a$ , $x=b$ កំណត់ដោយ $S=\int_a^b f(x).dx$ បើ $f(x)\ge 0$



-បើអនុគមន៍ $y=f(x)$ ជាប់លើចន្លោះ $[a,b]$ នោះផ្ទៃក្រឡានៃផ្ទៃកប្លង់ដែលខណ្ឌដោយខ្សែកោង អក្ស័រអាប់ស៊ីស បន្ទាត់ឈរ $x=a$ , $x=b$ កំណត់ដោយ $S=-\int_a^b f(x).dx$ បើ $f(x)\le 0$ ។




-បើ f និង g ជាអនុគមន៍ជាប់លើ $[a,b]$ នោះគេបានផ្ទៃក្រឡានៅចន្លោះខ្សែកោងតាងអនុគមន៍ទាំងពីរកំណត់ដោយ $S=\int_a^b [f(x)-g(x)].dx$

ដែល $f(x)\ge g(x)$ គ្រប់ $x\in[a,b]$ ។



## លំហាត់

1.ដោយប្រើនិយមន័យគណនាអាំតេក្រាលខាងក្រោម៖

ក.$\int_0^2 3x\,dx$ ខ.$\int_2^4 4x\,dx$

គ.$\int_0^2 x^2\,dx$ ឃ.$\int_0^2 \left(x^2 - 5x\right)dx$

ង.$\int_1^2 x^2\,dx$ ។

2.គណនាតម្លៃប្រហែលនៃផ្ទៃក្រលាដែលខណ្ឌដោយក្រាបតាង $y = f(x)$ និងអក្ស $x'ox$ លើចន្លោះ $[a,b]$ ដែល៖

ក.$f(x) = 9 - x^2$ ដែល $[a,b] = [-3,2]$ , $n = 5$

ខ.$f(x) = \dfrac{1}{x+2}$ ដែល $[a,b] = [-1,3]$ , $n = 4$

3.គណនាក្រលាផ្ទៃខណ្ឌដោយក្រាបនិងអក្សអាប់ស៊ីសលើចន្លោះដែលឲ្យ៖

ក.$f(x) = x^2$ ដែល $x \in [1,3]$

ខ.$f(x) = x^2 + 2x - 3$ ដែល $x \in [1,3]$

គ.$f(x) = 2 - x^3$ ដែល $x \in [-3,-2]$

ឃ.$f(x) = \dfrac{3}{2x+1}$ ដែល $x \in [0,2]$ ។

4.គណនាក្រលាផ្ទៃខណ្ឌដោយក្រាបតាងអនុគមន៍ទាំងពីរៈ

ក.$f(x)=x^2+2$ និង $g(x)=x$ , $x\in[2,5]$

ខ.$f(x)=x^2$ និង $g(x)=x^3$ , $x\in[0,1]$

គ.$f(x)=\sqrt{2x+1}$ និង $g(x)=3x+2$ , $x\in[0,2]$

ឃ.$f(x)=e^{x-1}$ និង $g(x)=x$ , $x\in[1,4]$

5. គណនាក្រលាផ្ទៃខណ្ឌដោយខ្សែកោងតាងអនុគមន៍

$x=y^2$ និង $y=x-2$ ។

6. គណនាក្រលាផ្ទៃខណ្ឌដោយខ្សែកោងតាងអនុគមន៍

$y=f(x)$ និង $y=g(x)=\sqrt{2-x}$ និង $x'ox$ ។

7. គណនាក្រលាផ្ទៃខណ្ឌដោយខ្សែកោងតាងអនុគមន៍

$y=f(x)=\dfrac{1}{x+1}$ និង $y=g(x)=e^{0.7x}$ និង $x\in[0,4]$ ។

## ដំណោះស្រាយ

1.ដោយប្រើនិយមន័យគណនាអាំងតេក្រាលខាងក្រោម៖

ក.$\int_0^2 3x dx$ ខ.$\int_2^4 4x dx$

គ.$\int_0^2 x^2 dx$ ឃ.$\int_0^2 (x^2 - 5x) dx$

ង.$\int_1^2 x^2 dx$ ។

**ដំណោះស្រាយ**

ក.$\int_0^2 3x dx = \left[\frac{3x^2}{2}\right]_0^2 = 6 - 0 = 6$

ខ.$\int_2^4 4x dx = \left[2x^2\right]_2^4 = 32 - 8 = 24$

គ.$\int_0^2 x^2 dx = \left[\frac{1}{3}x^3\right]_0^2 = \frac{8}{3}$

ឃ.$\int_0^2 (x^2 - 5x) dx = \left[\frac{1}{3}x^3 - \frac{5}{2}x^2\right]_0^2 = (\frac{8}{3} - \frac{20}{2}) = -\frac{22}{3}$

ង.$\int_1^2 x^2 dx = \left[\frac{1}{3}x^3\right]_1^2 = \frac{8}{3} - \frac{1}{3} = \frac{7}{3}$ ។

2.គណនាក្រលាផ្ទៃខណ្ឌដោយក្រាបនិងអក្ស័រអាប់ស៊ីសលើចន្លោះដែលឱ្យៈ

ក.$f(x)=x^2$ ដែល $x\in[1,3]$

ខ.$f(x)=x^2+2x-3$ ដែល $x\in[1,3]$

គ.$f(x)=2-x^3$ ដែល $x\in[-3,-2]$

ឃ.$f(x)=\dfrac{3}{2x+1}$ ដែល $x\in[0,2]$ ។

**ដំណោះស្រាយ**

គណនាក្រលាផ្ទៃ

ក.$f(x)=x^2$ ដែល $x\in[1,3]$




គេបាន $S=\int_1^3 x^2dx$

$$=\left[\frac{1}{3}x^3\right]_1^3$$

$$=\frac{27}{3}-\frac{1}{3}=\frac{26}{3}$$

ដូចនេះ $S=\dfrac{26}{3}$ (ឯកតាផ្ទៃ)

ខ. $f(x) = x^2 + 2x - 3$ ដែល $x \in [1, 3]$




យើងបាន

$$S = \int_1^3 (x^2 + 2x - 3).dx$$

$$= \left[\frac{1}{3}x^3 + x^2 - 3x\right]_1^3$$

$$= 9 - (-\frac{5}{3}) = \frac{32}{3}$$

ដូចនេះ $S = \frac{32}{3}$ ឯកតាផ្ទៃ

គ. $f(x) = 2 - x^3$ ដែល $x \in [-3, -2]$

គេបាន $S = \int_{-3}^{-2} (2 - x^3).dx$

$$= \left[2x - \frac{x^4}{4}\right]_{-3}^{-2}$$

$$= (-4 - 4) - (-6 - \frac{81}{4})$$

$$= -2 + \frac{81}{4} = \frac{73}{4}$$

ឃ. $f(x)=\dfrac{3}{2x+1}$ ដែល $x\in[0,2]$ ។

គេបាន

$$S=\int_0^2\frac{3dx}{2x+1}$$

$$=3\left[\frac{1}{2}\ln|2x+1|\right]_0^2$$

$$=\frac{3}{2}\ln 5$$

ដូចនេះ $S=\dfrac{3}{2}\ln 5$ ឯកតាផ្ទៃ




3.គណនាក្រលាផ្ទៃខណ្ឌដោយក្រាបតាងអនុគមន៍ទាំងពីរ:

ក. $f(x)=x^2+2$ និង $g(x)=x$ , $x\in[2,5]$

ខ. $f(x)=x^2$ និង $g(x)=x^3$ , $x\in[0,1]$

គ. $f(x)=\sqrt{2x+1}$ និង $g(x)=3x+2$ , $x\in[0,2]$

ឃ. $f(x)=e^{x-1}$ និង $g(x)=x$ , $x\in[1,4]$

## ដំណោះស្រាយ

គណនាក្រលាផ្ទៃ

ក. $f(x) = x^2 + 2$ និង $g(x) = x$ , $x \in [2,5]$

យើងបាន




$$S = \int_2^5 (x^2 + 2 - x).dx$$

$$= \left[\frac{1}{3}x^3 + 2x - \frac{1}{2}x^2\right]_2^5$$

$$= \frac{235}{6} - \frac{14}{3} = \frac{69}{2}$$

ដូចនេះ $S = 34.5$ ឯកតាផ្ទៃ

ខ. $f(x) = x^2$ និង $g(x) = x^3$ , $x \in [0,1]$

គេបាន




$$S = \int_0^1 \left(x^2 - x^3\right).dx$$

$$= \left[\frac{1}{3}x^3 - \frac{1}{4}x^4\right]_0^1$$

$$= \frac{1}{3} - \frac{1}{4} = \frac{1}{12}$$

ដូចនេះ $S = \frac{1}{12}$ ឯកតាផ្ទៃ

គ. $f(x) = \sqrt{2x+1}$ និង $g(x) = 3x + 2$ , $x \in [0, 2]$




យើងបាន $S = \int_0^2 \left(3x + 2 - \sqrt{2x+1}\right).dx$

$$= \left[\frac{3}{2}x^2 + 2x - \frac{1}{3}(2x+1)^{\frac{3}{2}}\right]_0^2$$

$$= (10 - \frac{\sqrt{125}}{3}) - (0 - \frac{1}{3})$$

$$= \frac{31 - 5\sqrt{5}}{3}$$

ដូចនេះ $S = \dfrac{31 - 5\sqrt{5}}{3}$ ។

ឃ. $f(x) = e^{x-1}$ និង $g(x) = x$ , $x \in [1,4]$




គេបាន

$$S = \int_1^4 (e^{x-1} - x).dx$$

$$= \left[ e^{x-1} - \frac{1}{2}x^2 \right]_1^4$$

$$= (e^3 - 8) - (1 - \frac{1}{2})$$

$$= e^3 - \frac{17}{2}$$

ដូចនេះ $S = \frac{2e^3 - 17}{2}$ ។

4. គណនាក្រលាផ្ទៃខណ្ឌដោយខ្សែកោងតាងអនុគមន៍

$x = y^2$ និង $y = x - 2$ ។

**ដំណោះស្រាយ**

គណនាក្រលាផ្ទៃ







គេមាន $y = x - 2$ នាំឱ្យ $x = y + 2$

គេបាន $S = \int_{-1}^{2} (y + 2 - y^2).dy$

$$= \left[ \frac{1}{2} y^2 + 2y - \frac{1}{3} y^3 \right]_{-1}^{2}$$

$$= (6 - \frac{8}{3}) - (\frac{1}{2} - 2 + \frac{1}{3}) = \frac{20 - 3 + 12 - 2}{6} = \frac{9}{2}$$

5. គណនាក្រលាផ្ទៃខណ្ឌដោយខ្សែកោងតាងអនុគមន៍

$$y=f(x)=\frac{1}{x+1} \text{ និង } y=g(x)=e^{0.7x} \text{ និង } x\in[0,4] \text{ ។}$$

**ដំណោះស្រាយ**

គណនាក្រលាផ្ទៃ




$$S=\int_0^4 (e^{0.7x}-\frac{1}{x+1}).dx$$

$$=\left[\frac{1}{0.7}e^{0.7x}-\ln(x+1)\right]_0^4=20.45$$

ដូចនេះ $S=20.45$ ឯកតាផ្ទៃ ។

ជំពូកទី៤ មេរៀនទី២

# មាឌសូលីតនិងប្រវែងធ្នូ

◆ បើអនុគមន៍ f វិជ្ជមានហើយជាប់លើចន្លោះ $[a,b]$ នោះមាឌនៃសូលីដបរិវត្តន៍បានពីរង្វិលជុំវិញអក្ស័អាប់ស៊ីសនៃផ្ទៃដែលខណ្ឌដោយក្រាបតាងអនុគមន៍ $y=f(x)$ អក្ស័អាប់ស៊ីស បន្ទាត់ឈរ $x=a$ និង $x=b$ កំណត់ដោយ $V=\lim_{n\to+\infty}\sum_{k=1}^{n}\left[\pi f^2(x_k).\Delta x\right]=\pi\int_a^b f^2(x).dx$ ។

◆ មាឌនៃសូលីដបរិវត្តកំណត់បានពីរង្វិលជុំវិញអក្ស័ (ox) នៃផ្ទៃខណ្ឌដោយក្រាប $y=f(x)$ និង $y=g(x)$ លើចន្លោះ $[a,b]$ ដែល $f(x)\geq g(x)$ កំណត់ដោយ $V=\pi\int_a^b\left[f^2(x)-g^2(x)\right].dx$ ។

◆ អនុគមន៍ F ដែលកំណត់លើចន្លោះ $[a,b]$ ដោយ $F(x)=\int_a^x f(t).dt$ ហៅថាអនុគមន៍កំណត់តាមអាំងតេក្រាលកំណត់ ។

◆ តម្លៃមធ្យមនៃ f កំណត់ជាប់លើ $[a,b]$ គឺ $y_m=\frac{1}{b-a}\int_a^b f(x).dx$

◆ ប្រវែងធ្នូនៃក្រាបតាង f លើ $[a,b]$ គឺ $L=\int_a^b\sqrt{1+f'^2(x)}.dx$

## លំហាត់

1.ក.គណនាមាឌសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអក្ស $x'ox$ នៃផ្ទៃក្រលាដែលខណ្ឌដោយក្រាប តាងអនុគមន៍ $y = 2x + 1$ អក្ស $x'ox$ បន្ទាត់ឈរ $x = 1$ និង $x = 3$ ។

ខ.គណនាមាឌសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអក្ស $x'ox$ នៃផ្ទៃក្រលាដែលខណ្ឌដោយក្រាប តាងអនុគមន៍ $y = x^2 + 1$ អក្ស $x'ox$ បន្ទាត់ឈរ $x = 0$ និង $x = 3$ ។

គ.គណនាមាឌសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអក្ស $x'ox$ នៃផ្ទៃក្រលាដែលខណ្ឌដោយក្រាប តាងអនុគមន៍ $y = \sqrt{x} - 3$ អក្ស $x'ox$ បន្ទាត់ឈរ $x = 4$ ទៅ $x = 9$ ។

2.ក.គណនាមាឌសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអក្ស $x'ox$ នៃផ្ទៃក្រលាដែលខណ្ឌដោយក្រាប តាងអនុគមន៍ $f(x) = x^2$ និង $g(x) = 4x - x^2$ ។

ខ.គណនាមាឌសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអក្ស $x'ox$ នៃផ្ទៃក្រលាដែលខណ្ឌដោយក្រាប តាងអនុគមន៍ $f(x) = x^2 - 2x + 3$ និង $g(x) = 9 - x$ ។

3.ចំពោះអនុគមន៍ $F(x)=\int_1^x \sin \pi t\,dt$ ។ គណនា

ក.$F(-1)$ ខ.$F'(0)$

គ.$F'\left(\frac{1}{2}\right)$ ឃ.$F''(x)$ ។

4.ផ្ទៃក្រលា A ខណ្ឌដោយក្រាបតាងអនុគមន៍ $g(t)=4-\frac{4}{t^2}$ និង អក្ស័អាប់ស៊ីសលើចន្លោះ$[1,x]$ កំណត់ដោយ $A(x)=\int_1^x\left(4-\frac{4}{t^2}\right)dt$ ។

ក.គណនា A ជាអនុគមន៍នៃ x ។ តើក្រាបអនុគមន៍ A មានសមីការ អាស៊ីមតូតដេក រឺ ទេ?

ខ.រកសមីការអាស៊ីមតូតទ្រេតនៃក្រាបតាងអនុគមន៍ g ។

5. គណនា $F'(x)$ បើ

ក.$F(x)=\int_x^{x+2}(4t+1)dt$ ខ.$F(x)=\int_{-x}^{x} t^3 dt$

គ.$F(x)=\int_0^{\sin x}\sqrt{t}\,dt$ ឃ.$F(x)=\int_2^{x^2}\frac{1}{t^2}dt$

ង.$F(x)=\int_0^{x^3}\sin t\,dt$ ច.$F(x)=\int_{\sin x}^{0}\frac{1}{2+t}dt$ ។

6.ក.បង្ហាញថាបើ $f(t)$ ជាអនុគមន៍សេស នោះ $F(x)=\int_a^x f(t)dt$ គ្រប់ $x\in IR$ ជាអនុគមន៍សេសដែររឺទេ?

7.គេបោះដុំស្ករសូកូឡាបានទទួលវិក័យប័ត្រចំនួន 1200 រៀងរាល់ 30 ថ្ងៃម្តង ។ ស្ករសូកូឡាត្រូវបានលក់បន្តឱ្យអ្នកលក់រាយដោយអត្រាថេរនិង $x$ ជាថ្ងៃបន្ទាប់ពីទទួលវិក័យប័ត្រមកដល់ ហើយបញ្ជីទូទាត់កំណត់ដោយ $I(x) = 1200 - 40x$ ។

គណនាមធ្យមប្រចាំថ្ងៃនៃការទូទាត់ ។

គណនាមធ្យមប្រចាំថ្ងៃនៃលក់ស្ករសូកូឡា បើស្ករសូកូឡាមួយគ្រប់ថ្ងៃ 300 រៀល ។

8.ក.គណនាប្រវែងធ្នូនៃក្រាបតាងអនុគមន៍ $y = \frac{x^3}{3} + \frac{1}{4x}$ ពី $x = 1$ ទៅ $x = 3$ ។

ខ.ឧបមាថា $f(x) = \frac{1}{2}\left(e^{x} + e^{-x}\right)$ ។ បន្ទាត់ជួបអក្សអរដោនេត្រង់ B ហើយប៉ះនិងក្រាបតាង f ត្រង់ចំនុច $A(a, f(a))$ ដែល $a > 0$ ។ ប្រៀបធៀបប្រវែងនៃអង្គត់ AB និងប្រវែងធ្នូរនៃក្រាបតាង f នៅបន្លោះបន្ទាត់ឈរ $x = 0$ និង $x = a$ ។

9.រកផ្ទៃក្រលា S នៃស្វ៊ែរដែលមានកាំ $r$ ។

## លំហាត់ជំពូក៤

1.គណនាអាំងតេក្រាលខាងក្រោម៖

ក. $\int_{2}^{2}(4-x^2)(2+x)^n\,dx$

ខ. $\int_{6}^{8}\frac{x}{x^2-6x+8}dx$

គ. $\int_{0}^{1}\frac{x^2}{x^2-x-2}dx$

ឃ. $\int_{1}^{3}\frac{x-1}{\sqrt{x}}dx$

ង. $\int_{0}^{\pi}\cos mx\cos nx\,dx$

ច. $\int_{0}^{1}\frac{x}{1+3x^2}dx$

ឆ. $\int_{0}^{\frac{\pi}{2}}\frac{\sin 2x}{3+\cos^2 x}dx$

ជ. $\int_{0}^{\frac{\pi}{2}}x^2\cos^2 x\,dx$ ។

2.គណនា

ក. $\int_{0}^{\pi}e^{-at}\cos^2\frac{t}{2}dt \quad (a\neq 0)$

ខ. $\int_{1}^{e}\frac{\sin(\pi\ln x)}{x}dx$

គ. $\int_{0}^{\sqrt{\ln 6}}\frac{x}{e^{-x^2}+e^{x^2}+2}dx$

ឃ. $\int_{0}^{1}\left(4-x^2-\sqrt{1-x^2}\right)dx$

ង. $\int_{0}^{1}\frac{dx}{\sqrt{4-x^2}}$

ច. $\int_{0}^{a}\sqrt{2ax-x^2}\,dx$

ឆ. $\int_{0}^{a}(x^2+a^2)^{\frac{3}{2}}dx$

ជ. $\int_{0}^{1}\frac{2x}{x^2-x+1}dx$

3.គណនាមាឌសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអ័ក្ស $x'ox$ នៃផ្ទៃក្រលាខណ្ឌដោយក្រាភិចតាងអនុគមន៍ $f(x)=x+6$ និង $g(x)=x^2$ លើចន្លោះ $x\in[-2,3]$ ។

4. គណនាមាឌសូលីតបិវត្តកំណត់បានពីរង្វិលនៃផ្ទៃក្រលាខណ្ឌដោយក្រាភិច តាងអនុគមន៍ $y=\sqrt{3-x}$ និង អក្ស $x'ox$ , $(-1\le x\le 2)$ ជុំវិញអក្ស $x'ox$ ។

5. គណនាមាឌសូលីតបិវត្តកំណត់បានពីរង្វិលចំនួន $360^0$ ជុំវិញអក្ស អាប់ស៊ីសនៃផ្ទៃក្រលាខណ្ឌដោយក្រាភិចតាងអនុគមន៍ $y=1-x^2$ និង អក្ស $x'ox$ , $x\in[-1,1]$ ។

6. គណនាមាឌសូលីតបិវត្តកំណត់បានពីរង្វិលជុំវិញអក្ស $x'ox$ នៃផ្ទៃក្រលាខណ្ឌដោយក្រាភិចតាងអនុគមន៍ $f(x)=2x^2$ និង $g(x)=4x-x^2$ ។

7. គណនាមាឌសូលីតបិវត្តកំណត់បានពីរង្វិលជុំវិញអក្ស $x'ox$ នៃផ្ទៃក្រលាខណ្ឌដោយក្រាភិចតាងអនុគមន៍ $f(x)=2-x^2$ និង $g(x)=x$ លើចន្លោះ $x\in[0,1]$ ។

8. គណនាមាឌសូលីតបិវត្តកំណត់បានពីរង្វិល ចំនួន $180^0$ ជុំវិញអក្ស $x'ox$ នៃផ្ទៃក្រលាខណ្ឌដោយក្រាភិចតាងអនុគមន៍ $f(x)=8-x^2$ និង $g(x)=x^2$ ។

9.គណនាផ្ទៃក្រលាដែលខណ្ឌដោយក្រាបតាងអនុគមន៍ $y=\sin\frac{\pi}{2}x$ និង $y=x^4$ ។

10. គណនាផ្ទៃក្រលាដែលខណ្ឌដោយក្រាបតាងអនុគមន៍ $y=\sin^3 x$ និង $y=\cos^3 x$ នៅចន្លោះ $x=\frac{\pi}{4}$ និង $x=\frac{5\pi}{4}$ ។

11. គណនាផ្ទៃក្រលាដែលខណ្ឌដោយក្រាប $C_1$ និង $C_2$ អនុគមន៍ $y=\sin x \quad , \ (0\le x\le \pi)$ និង $y=\sin 3x \quad , \quad (0\le x\le \pi)$

12.ពិនិត្យក្រាប $y=\sin 2x$ និង $y=\cos x$ ដែល $0\le x\le \pi$ ។

ក.រកកូអរដោនេចំណុចប្រសព្វនៃក្រាបទាំងពីរ ។

ខ.រកផ្ទៃក្រលា $S$ ដែលខណ្ឌដោយក្រាបទាំងពីរ ។

13.$C$ ជាក្រាបតាង $f(x)=\ln(x+1)$ និង $L$ ជាបន្ទាត់ប៉ះនឹង $C$ ដែលមានមេគុណប្រាប់ទិសស្មើនឹង $\frac{1}{2}$ ។

ក.រកសមីការបន្ទាត់ប៉ះ $L$ ។

ខ.គណនាមាឌសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអ័ក្ស $x'ox$ នៃផ្ទៃក្រលាខណ្ឌដោយក្រាប $C$ , $L$ និង អ័ក្សអរដោនេ ។

14.តាង $C$ ជាក្រាប $y=e^{2x-1}$ និង $L$ ជាបន្ទាត់ប៉ះនឹង $C$ ត្រង់ចំនុច $P(1,e)$ ។

ក. រកសមីការបន្ទាត់ $L$ ។

ខ.រកផ្ទៃក្រលា $S$ ដែលខណ្ឌដោយក្រាប$C$ បន្ទាត់ $L$ និងអ័ក្សអរដោនេ ។

15. តាង C ជាក្រាប $y = xe^x$ , $L_1$ , $L_2$ ជាបន្ទាត់ប៉ះ C ដែលគូស ចេញពីចំនុច $\left(\frac{1}{2},0\right)$ ។

ក.រកសមីការបន្ទាត់ប៉ះ $L_1$ ,$L_2$ ។

ខ.រកផ្ទៃក្រលា S ដែលខណ្ឌដោយក្រាប C និង បន្ទាត់ប៉ះដែលមានក្នុង សំនួរទី 1។

## ដំណោះស្រាយ

1.ក.គណនាមាឌសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអក្សរ $x'ox$ នៃផ្ទៃក្រលាដែលខណ្ឌដោយក្រាប តាងអនុគមន៍ $y = 2x + 1$ អក្ស $x'ox$ បន្ទាត់ឈរ $x = 1$ និង $x = 3$ ។

ខ.គណនាមាឌសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអក្សរ $x'ox$ នៃផ្ទៃក្រលាដែលខណ្ឌដោយក្រាប តាងអនុគមន៍ $y = x^2 + 1$ អក្ស $x'ox$ បន្ទាត់ឈរ $x = 0$ និង $x = 3$ ។

គ.គណនាមាឌសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអក្សរ $x'ox$ នៃផ្ទៃក្រលាដែលខណ្ឌដោយក្រាប តាងអនុគមន៍ $y = \sqrt{x} - 3$ អក្ស $x'ox$ បន្ទាត់ឈរ $x = 4$ ទៅ $x = 9$ ។

## ដំណោះស្រាយ

ក.គណនាមាឌសូលីត

$$V = \pi\int_1^3 (2x+1)^2.dx$$

$$= \frac{\pi}{6}\left[(2x+1)^3\right]_1^3$$

$$= \frac{\pi}{6}(343 - 27) = \frac{158\pi}{3}$$

( ឯកតាមាឌ ) ។



ខ.គណនាមាឌសូលីតបរិវត្ត




$$V = \pi \int_0^3 (x^2+1)^2 dx$$

$$= \pi \int_0^3 (x^4+2x^2+1) dx$$

$$= \pi \left[ \frac{1}{4}x^4 + \frac{2}{3}x^3 + x \right]_0^3$$

$$= \frac{165\pi}{4}$$

ដូចនេះ $V = \frac{165\pi}{4}$ (ឯកតាមាឌ) ។

គ.គណនាមាឌសូលីតបរិវត្ត




យើងបាន $V = \pi \int_4^9 (\sqrt{x}-3)^2 dx = \pi \int_4^9 (x - 6\sqrt{x} + 9) dx$

$$= \pi \left[ \frac{x^2}{2} - 4x^{\frac{3}{2}} + 9x \right]_4^9 = \frac{3\pi}{2}$$ (ឯកតាមាឌ) ។

2.ក.គណនាមាឌសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអ័ក្ស$x'ox$ នៃផ្ទៃក្រលាដែលខណ្ឌដោយក្រាប តាងអនុគមន៍ $f(x)=x^2$ និង $g(x)=4x-x^2$ ។

ខ.គណនាមាឌសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអ័ក្ស$x'ox$ នៃផ្ទៃក្រលាដែលខណ្ឌដោយក្រាប តាងអនុគមន៍ $f(x)=x^2-2x+3$ និង $g(x)=9-x$ ។

**ដំណោះស្រាយ**

ក.គណនាមាឌសូលីតបរិវត្ត




យើងបាន $V=\pi\int_0^2\left[(4x-x^2)^2-(x^2)^2\right].dx$

$$V = \pi \int_0^2 (16x^2 - 8x^3)dx$$

$$V = \pi \left[\frac{16}{3}x^3 - 2x^4\right]_0^2 = \frac{32\pi}{3}$$

ដូចនេះ $V = \frac{32\pi}{3}$ （ឯកតាមាឌ） ។

ខ.គណនាមាឌសូលីតបរិវត្ត




គេបាន $V = \pi \int_{-2}^{3} \left[(9-x)^2 - (x^2 - 2x + 3)^2\right]dx$

បន្ទាប់ពីគណនាគេបាន $V = 250\pi$ （ឯកតាមាឌ） ។

3.ចំពោះអនុគមន៍ $F(x)=\int_1^x \sin \pi t dt$ ។ គណនា

ក.$F(-1)$ ខ.$F'(0)$

គ.$F'\left(\frac{1}{2}\right)$ ឃ.$F''(x)$ ។

**ដំណោះស្រាយ**

គេមាន $F(x)=\int_1^x \sin \pi t dt$

$$=\left[-\frac{1}{\pi}\cos \pi t\right]_1^x$$

$$=-\frac{1}{\pi}\cos \pi x-\frac{1}{\pi}$$

ក.$F(-1)$

គេបាន $F(-1)=-\frac{1}{\pi}(-1)-\frac{1}{\pi}=0$ ។

ខ.$F'(0)$

គេមាន $F'(x)=\sin \pi x$

គេបាន $F'(0)=0$

គ.$F'\left(\frac{1}{2}\right)$

គេបាន $F'(\frac{1}{2})=\sin\frac{\pi}{2}=1$ ។

ឃ.$F''(x)=\pi \cos \pi x$ ។

4.ផ្ទៃក្រលា A ខណ្ឌដោយក្រាបតាងអនុគមន៍ $g(t)=4-\frac{4}{t^2}$ និង អក្សអាប់ស៊ីសលើចន្លោះ$[1,x]$ កំណត់ដោយ

$A(x)=\int_1^x\left(4-\frac{4}{t^2}\right)dt$ ។

គណនា A ជាអនុគមន៍នៃ x ។ តើក្រាបអនុគមន៍ A មានសមីការ អាស៊ីមតូតដេក រឺ ទេ?

**ដំណោះស្រាយ**

ក.គណនា A ជាអនុគមន៍នៃ x

$$A(x)=\int_1^x\left(4-\frac{4}{t^2}\right).dt$$

$$=\left[4t+\frac{4}{t}\right]_1^x=4x+\frac{4}{x}-8$$

ដូចនេះ $A(x)=4x-8+\frac{4}{x}$ ។

ដោយ $\lim\limits_{x\to+\infty}A(x)=\lim\limits_{x\to+\infty}(4x-8+\frac{4}{x})=+\infty$ ។

នាំឱ្យក្រាបអនុគមន៍ A គ្មានសមីការអាស៊ីមតូតដេកទេ ។

5. គណនា $F'(x)$ បើ

ក. $F(x)=\int_{x}^{x+2}(4t+1)dt$ ខ. $F(x)=\int_{-x}^{x}t^3dt$

គ. $F(x)=\int_{0}^{\sin x}\sqrt{t}\,dt$ ឃ. $F(x)=\int_{2}^{x^2}\frac{1}{t^2}dt$

ង. $F(x)=\int_{0}^{x^3}\sin t\,dt$ ច. $F(x)=\int_{\sin x}^{0}\frac{1}{2+t}dt$ ។

## ដំណោះស្រាយ

គណនា $F'(x)$ បើ

ក. $F(x)=\int_{x}^{x+2}(4t+1)dt$

គេបាន $F(x)=\left[2t^2+t\right]_{x}^{x+2}$

$$=\left[2(x+2)^2+x+2\right]-(2x^2+x)$$

$$=2x^2+8x+8+x+2-2x^2-x$$

$$=8x+10$$

ដូចនេះ $F'(x)=8$ ។

ខ. $F(x)=\int_{-x}^{x}t^3dt$

គេបាន $F(x)=\left[\frac{1}{4}t^4\right]_{-x}^{x}=0$

ដូចនេះ $F'(x)=0$ ។

គ.$F(x)=\int_0^{\sin x}\sqrt{t}\,dt$

គេបាន $F(x)=\left[\frac{2}{3}t^{\frac{3}{2}}\right]_0^{\sin x}=\frac{2}{3}\sin^{\frac{3}{2}}x$

ដូចនេះ $F'(x)=\cos x\sqrt{\sin x}$

ឃ.$F(x)=\int_2^{x^2}\frac{1}{t^2}dt$

គេបាន $F(x)=\left[-\frac{1}{t}\right]_2^{x^2}=-\frac{1}{x^2}+\frac{1}{2}$

ដូចនេះ $F'(x)=\frac{2}{x^3}$ ។

ង.$F(x)=\int_0^{x^3}\sin t\,dt$

គេបាន $F(x)=\left[-\cos t\right]_0^{x^3}=-\cos x^3+1$

ដូចនេះ $F'(x)=3x^2\sin x^3$

ច.$F(x)=\int_{\sin x}^{0}\frac{1}{2+t}dt$ ។

គេបាន $F(x)=\left[\ln|2+t|\right]_{\sin x}^{0}=\ln 2-\ln|2+\sin x|$

ដូចនេះ $F'(x)=-\frac{(2+\sin x)'}{2+\sin x}=-\frac{\cos x}{2+\sin x}$ ។

6.ក.បង្ហាញថាបើ $f(t)$ ជាអនុគមន៍សេស នោះ $F(x)=\int_a^x f(t)dt$

គ្រប់ $x\in IR$ ជាអនុគមន៍សេសដែរឬទេ?

**ដំណោះស្រាយ**

សិក្សាភាពគូសេសនៃអនុគមន៍ $F(x)$

មាន $F(x)=\int_a^x f(t)dt$

គេបាន $F(-x)=\int_a^{-x} f(t).dt$

តាង $u=-t \Rightarrow du=-dt$

ចំពោះ $t=a$ នោះ $u=-a$ ហើយ $t=-x$ នោះ $u=x$

គេបាន $F(-x)=\int_{-a}^{x} f(-u)(-du)=\int_{x}^{-a} f(-u)du$

ឬ $F(-x)=\int_{x}^{-a} f(-t)dt=\int_{x}^{-a} f(t)dt$ ព្រោះ$f(t)$ ជាអនុគមន៍សេស

ឬ $F(-x)=-\int_{-a}^{x} f(t)dt$

-បើ $a=0$ នោះ $F(x)=\int_0^x f(t)dt$ និង $F(-x)=-\int_0^x f(t)dt$

គេបាន $F(-x)=-F(x)$ នោះ $F(x)$ ជាអនុគមន៍សេស ។

-បើ $a\neq 0$ នោះ $F(x)$ មិនមែនជាអនុគមន៍សេសទេ ។

7.ក.គណនាប្រវែងធ្នូនៃក្រាបតាងអនុគមន៍ $y = \frac{x^3}{3} + \frac{1}{4x}$ ពី $x = 1$ ទៅ $x = 3$ ។

ខ.ឧបមាថា $f(x) = \frac{1}{2}(e^x + e^{-x})$ ។ បន្ទាត់ជួបអក្ស័អរដោនេត្រង់ B ហើយប៉ះនិងក្រាបតាង f ត្រង់ចំនុច $A(a, f(a))$ ដែល $a > 0$ ។ ប្រៀបធៀបប្រវែងនៃអង្កត់ AB និងប្រវែងធ្នូរនៃក្រាបតាង f នៅបន្លោះបន្ទាត់ឈរ $x = 0$ និង $x = a$ ។

**ដំណោះស្រាយ**




ក.គណនាប្រវែងធ្នូ

តាមរូបមន្ត $L = \int_1^3 \sqrt{1 + y'^2}.dx$

ដោយ $y = \frac{x^3}{3} + \frac{1}{4x}$

គេបាន $y' = x^2 - \frac{1}{4x^2}$

$$L = \int_1^3 \sqrt{1 + (x^2 - \frac{1}{4x^2})^2}.dx$$

$$= \int_1^3 (x^2 + \frac{1}{4x^2})^2.dx$$

$$= \left[\frac{1}{3}x^3 - \frac{1}{4x}\right]_1^3 = \frac{53}{6}$$

**ខ.AB និងប្រវែងធ្នូរនៃក្រាបតាង f នៅចន្លោះបន្ទាត់ $x = 0$ និង $x = a$**




សមីការបន្ទាត់ T ប៉ះក្រាបតាង $f(x) = \frac{1}{2}(e^{x} + e^{-x})$ គឺ

$T : y - f(a) = f'(a)(x - a)$ ដែល $f'(a) = \frac{1}{2}(e^{a} - e^{-a})$

បើ $x = 0 \Rightarrow y = -af'(a) + f(a)$ នោះ $B(0\ ,\ -af'(a) + f(a))$

គេបាន $AB = \sqrt{a^2 + a^2 f'^2(a)} = a\sqrt{1 + f'^2(a)}$

$$= a\sqrt{1 + \frac{1}{4}(e^{a} - e^{-a})^2} = \frac{a}{2}(e^{a} + e^{-a})$$

ហើយ $L = \int_0^a \sqrt{1 + \frac{1}{4}(e^{x} - e^{-x})^2}.dx = \frac{1}{2}\int_0^a (e^{x} + e^{-x}).dx$

$$= \frac{1}{2}\left[e^{x} - e^{-x}\right]_0^a = \frac{1}{2}(e^{a} - e^{-a})$$ ។

## ជំពូកទី៥ មេរៀនទី១

# សមីការឌីផេរ៉ង់ស្យែលលំដាប់ទី១

សមីការឌីផេរ៉ង់ស្យែលលំដាប់ទី 1 មានរាងទូទៅ

- $\frac{dy}{dx} = f(x)$ មានចម្លើយទូទៅ $y = \int f(x).dx + c$
- $g(y).\frac{dy}{dx} = f(x)$ មានចម្លើយទូទៅ $G(y) = F(x) + C$

  ដែល $G(y) = \int g(y).dy$ ។
- $y'+ay = 0$ ឬ $\frac{dy}{dx} + ay = 0$ មានចម្លើយទូទៅ $y = A.e^{-ax}$

  ដែល A ជាចំនួនថេរ ។
- $y'+ay = p(x)$ មានចម្លើយទូទៅ $y = y_e + y_p$ ដែល $y_e$ ជាចម្លើយនៃសមីការ $y'+ay = 0$ និង $y_p$ ជាចម្លើយពិសេសមួយនៃសមីការ $y'+ay = p(x)$ ។

## លំហាត់

1.ដោះស្រាយសមីការឌីផេរ៉ង់ស្យែលៈ

ក.$y' = 2x^2 - x + 1$

ខ.$y' = e^{-2x}$

គ.$y' = \dfrac{2x}{x^2 + 1}$

ឃ.$y' = \dfrac{x}{x^2 - 1}$ កំណត់លើ $(-1, 1)$

ង.$xy' = 1$ កំណត់លើ $(0, +\infty)$ ។

2. ដោះស្រាយសមីការឌីផេរ៉ង់ស្យែលតាមលក្ខខណ្ឌដែលឱ្យៈ

ក.$\dfrac{y'}{y} = \cos x$ , $y\left(\dfrac{\pi}{2}\right) = e$

ខ.$y' = e^{2x}$ , $y(0) = 5$

គ.$(3x^2 - 2)y' = 6$ , $y(1) = 4$

ឃ.$\dfrac{y'}{\tan x} = 1$ , $y(0) = 0$

3.ដោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី1

ក.$\dfrac{dy}{dx} + 2y = 0$

ខ.$3\dfrac{dy}{dx} + y = 0$

គ.$2y' - 3y = 0$

ឃ.$y' + y\sqrt{2} = 0$ ។

4. ដោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី១តាមលក្ខខណ្ឌដែលឱ្យ:

ក. $-y'+2y=0$ , $y(3)=-2$ ខ. $2y'+y=0$ , $y(\ln 4)=\frac{1}{5}$

គ. $7y'+4y=0$ , $y(7)=e^{-4}$ ឃ. $2y'-5y=0$ , $y(1)=-3$

5. ចូរបង្ហាញថាអនុគមន៍និមួយៗចខាងក្រោមនេះជាចំលើយនៃសមីការឌីផេរ៉ង់ស្យែលនៅខាងស្តាំ:

ក. $y=x+e^{x}$ , $y'-y=1-x$

ខ. $y=e^{3x}-x-1$ , $y'-3y=3x+2$

គ. $y=\sin x+\cos x$ , $y'+y=2\cos x$

ឃ. $y=x+\ln x$ , $xy'-y=1-\ln x$ ។

6. គេមានសមីការឌីផេរ៉ង់ស្យែល $(E)$ : $y'+2y=x^2$ ។

ក. កំណត់ពហុធា $g$ មានដឺក្រេទី2 ដែលជាចំលើយពិសេសនៃ $(E)$ ។

ខ. តាង $h$ ជាអនុគមន៍ដែល $h(x)=f(x)-g(x)$ ។ បើ $h$ ដែលជាចំលើយពិសេសនៃសមីការឌីផេរ៉ង់ស្យែល $y'+2y=0$ នោះបង្ហាញថា $f$ ជាចំលើយទូរទៅនៃ $(E)$ ។

7. គេមានសមីការឌីផេរ៉ង់ស្យែល $(E): y'-2y=\frac{-2}{1+e^{-2x}}$ ។

ក.ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $y'-2y=0$ ដែលផ្ទៀងផ្ទាត់ $y(0)=1$ ។

ខ.តាង f ជាអនុគមន៍មានដេរីវេ IR ដែល $f(x)=e^{2x}g(x)$ ។ គណនា $f'(x)$ ជាអនុគមន៍នៃ $g(x)$ និង $g'(x)$ ។

គ.បង្ហាញថាបើ f ជាចម្លើយនៃ (E) លុះត្រាតែ $g'(x)=\frac{-2e^{-2x}}{1+e^{-2x}}$

ឃ.ទាញរកកន្សោម $g(x)$ រួច $f(x)$ ដែល f ជាចម្លើយនៃ (E) ។

8.ដោះស្រាយសមីការឌីផេរ៉ង់ស្យែល

ក. $\frac{dy}{dx}-y=e^{3x}$

ខ. $\frac{dy}{dx}+y=\frac{1}{e^{2x}+1}$

គ. $y'+y=1$

ឃ. $y'+y=\sin x$

9.ដោះស្រាយសមីការឌីផេរ៉ង់ស្យែលតាមលក្ខខណ្ឌដើម

ក. $y'-y=1$ , $y(0)=1$

ខ. $y'+2y=1$ , $y(0)=0$

10.ដោះស្រាយសមីការឌីផេរ៉ង់ស្យែល

ក. $\frac{dy}{dx}=\sin 5x$

ខ. $dx+e^{3x}dy=0$

គ. $e^{x}\frac{dy}{dx}=2x$

ឃ. $(x+1)\frac{dy}{dx}=x+6$

## លំហាត់ និង ដំណោះស្រាយ

1.ដោះស្រាយសមីការឌីផេរ៉ង់ស្យែលៈ

ក.$y' = 2x^2 - x + 1$ ខ.$y' = e^{-2x}$

គ.$y' = \dfrac{2x}{x^2+1}$

ឃ.$y' = \dfrac{x}{x^2-1}$ កំណត់លើ $(-1,1)$

ង.$xy' = 1$ កំណត់លើ $(0,+\infty)$ ។

### ដំណោះស្រាយ

ដោះស្រាយសមីការឌីផេរ៉ង់ស្យែលៈ

ក.$y' = 2x^2 - x + 1$

គេបាន $y = \int (2x^2 - x + 1).dx$

ដូចនេះ $y = \dfrac{2}{3}x^3 - \dfrac{1}{2}x^2 + x + c$

ខ.$y' = e^{-2x}$

គេបាន $y = \int e^{-2x}dx$

ដូចនេះ $y = -\dfrac{1}{2}e^{-2x} + c$

គ. $y'=\frac{2x}{x^2+1}$

គេបាន $y=\int \frac{2x}{x^2+1}.dx$

ដូចនេះ $=\ln(x^2+1)+C$

ឃ. $y'=\frac{x}{x^2-1}$ កំណត់លើ $(-1,1)$

គេបាន $y=\int \frac{x}{x^2-1}dx$

$$=\frac{1}{2}\int \left(\frac{1}{x+1}+\frac{1}{x-1}\right).dx$$

$$=\frac{1}{2}\int \frac{dx}{x+1}+\frac{1}{2}\int \frac{dx}{x-1}$$

$$=\frac{1}{2}\ln|x+1|+\frac{1}{2}\ln|x-1|+C$$

ដូចនេះ $y=\frac{1}{2}\ln\left|(x+1)(x-1)\right|+C$

ង. $xy'=1$ កំណត់លើ $(0,+\infty)$ ។

គេបាន $y'=\frac{1}{x}\Rightarrow y=\int \frac{dx}{x}=\ln|x|+C$

ដូចនេះ $y=\ln|x|+C$ ។

2. ដោះស្រាយសមីការឌីផេរ៉ង់ស្យែលតាមលក្ខខណ្ឌដែលឱ្យ៖

ក. $\frac{y'}{y} = \cos x$ , $y\left(\frac{\pi}{2}\right) = e$ ខ. $y' = e^{2x}$ , $y(0) = 5$

គ. $(3x^2 - 2)y' = 6x$ , $y(1) = 4$ ឃ. $\frac{y'}{\tan x} = 1$ , $y(0) = 0$

**ដំណោះស្រាយ**

ដោះស្រាយសមីការឌីផេរ៉ង់ស្យែល

ក. $\frac{y'}{y} = \cos x$ , $y\left(\frac{\pi}{2}\right) = e$

គេបាន $\int \frac{y'}{y} dx = \int \cos x dx$

$$\ln y = \sin x + c \Rightarrow y = e^{\sin x + c}$$

ចំពោះ $x = \frac{\pi}{2} \Rightarrow y(\frac{\pi}{2}) = e^{1+c} = e \Rightarrow c = 0$

ដូចនេះ $y = e^{\sin x}$ ។

ខ. $y' = e^{2x}$ , $y(0) = 5$

គេបាន $y = \int e^{2x} dx = \frac{1}{2} e^{2x} + c$

ចំពោះ $x = 0$ គេបាន $y(0) = \frac{1}{2} + c = 5 \Rightarrow c = \frac{9}{2}$

ដូចនេះ $y = \frac{1}{2} e^{2x} + \frac{9}{2}$

គ.$(3x^2-2)y'=6x \quad , \quad y(1)=4$

គេបាន $y=\int \dfrac{6xdx}{3x^2-2}=\ln|3x^2-2|+C$

បើ $x=1 \Rightarrow y(1)=C=4$

ដូចនេះ $y=\ln|3x^2-2|+4$

ឃ.$\dfrac{y'}{\tan x}=1 \ , \ y(0)=0$

គេបាន $y=\int \tan x dx=-\ln|\cos x|+C$

បើ $x=0 \Rightarrow y=C=0$

ដូចនេះ $y=-\ln|\cos x|$ ។

3.ដោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី1

ក.$\dfrac{dy}{dx}+2y=0$ ខ.$3\dfrac{dy}{dx}+y=0$

គ.$2y'-3y=0$ ឃ.$y'+y\sqrt{2}=0$ ។

**ដំណោះស្រាយ**

ដោះស្រាយសមីការឌីផេរ៉ង់ស្យែល

ក.$\dfrac{dy}{dx}+2y=0$ ដោយ $a=2$ នោះចម្លើយទូទៅរបស់សមីការ

គឺ $y=A.e^{-2x}$ ដែល A ជាចំនួនថេរ ។

ខ.$3\frac{dy}{dx}+y=0$ ឬ $\frac{dy}{dx}+\frac{1}{3}y=0$

ដោយ $a=\frac{1}{3}$ នោះចម្លើយទូទៅរបស់សមីការគឺ $y=A.e^{-\frac{1}{3}x}$

ដែល A ជាចំនួនថេរ ។

គ.$2y'-3y=0$ ឬ $y'-\frac{3}{2}y=0$

ដោយ $a=-\frac{3}{2}$ នោះចម្លើយទូទៅរបស់សមីការគឺ $y=A.e^{\frac{3}{2}x}$

ដែល A ជាចំនួនថេរ ។

ឃ.$y'+y\sqrt{2}=0$

ដោយ $a=\sqrt{2}$ នោះចម្លើយទូទៅរបស់សមីការគឺ $y=A.e^{\sqrt{2}x}$

ដែល A ជាចំនួនថេរ ។

4. ដោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី១តាមលក្ខខណ្ឌ ដែលឱ្យ:

ក.$-y'+2y=0$ , $y(3)=-2$ ខ.$2y'+y=0$ , $y(\ln 4)=\frac{1}{5}$

គ.$7y'+4y=0$ , $y(7)=e^{-4}$ ឃ.$2y'-5y=0$ , $y(1)=-3$

**ដំណោះស្រាយ**

ដោះស្រាយសមីការឌីផេរ៉ង់ស្យែល

ក. $-y'+2y=0$ , $y(3)=-2$

សមីការអាចសរសេរ $y'-2y=0$

ដោយ $a=2$ នោះចម្លើយទូទៅរបស់សមីការគឺ $y=Ae^{2x}$

បើ $x=3 \Rightarrow y(3)=Ae^{6}=-2 \Rightarrow A=-2e^{-6}$

ដូចនេះ $y=-2e^{2x-6}$ ។

ខ. $2y'+y=0$ , $y(\ln 4)=\frac{1}{5}$

សមីការអាចសរសេរ $y'+\frac{1}{2}y=0$

ដោយ $a=\frac{1}{2}$ នោះចម្លើយទូទៅរបស់សមីការគឺ $y=Ae^{-\frac{1}{2}x}$

បើ $x=\ln 4 \Rightarrow y(\ln 4)=Ae^{-\frac{1}{2}\ln 4}=\frac{1}{5} \Rightarrow A=\frac{2}{5}$

ដូចនេះ $y=\frac{2}{5}e^{-\frac{1}{2}x}$ ។

គ. $7y'+4y=0$ , $y(7)=e^{-4}$ ។សមីការអាចសរសេរ $y'+\frac{4}{7}y=0$

ដោយ $a=\frac{4}{7}$ នោះចម្លើយទូទៅរបស់សមីការគឺ $y=Ae^{-\frac{4}{7}x}$

បើ $x=7 \Rightarrow y(7)=Ae^{-4}=e^{-4} \Rightarrow A=1$

ដូចនេះ $y=e^{-\frac{4}{7}x}$ ។

ឃ.$2y'-5y=0\ ,\ y(1)=-3$

សមីការអាចសរសេរ $y'-\frac{5}{2}y=0$

ដោយ $a=\frac{5}{2}$ នោះចម្លើយទូទៅរបស់សមីការគឺ $y=Ae^{\frac{5}{2}x}$

បើ $x=1\Rightarrow y(1)=Ae^{\frac{5}{2}}=-3\Rightarrow A=-3e^{-\frac{5}{2}}$

ដូចនេះ $y=-3e^{\frac{5}{2}(x-1)}$ ។

5.ចូរបង្ហាញថាអនុគមន៍និមួយៗចខាងក្រោមនេះជាចំលើយនៃសមីការឌីផេរ៉ង់ស្យែលនៅខាងស្តាំៈ

ក.$y=x+e^{x}\ ,\ y'-y=1-x$

ខ.$y=e^{3x}-x-1\ ,\ y'-3y=3x+2$

គ.$y=\sin x+\cos x\ ,\ y'+y=2\cos x$

ឃ.$y=x+\ln x\ ,\ xy'-y=1-\ln x$ ។

**ដំណោះស្រាយ**

ការបង្ហាញ

ក.$y=x+e^{x}\ ,\ y'-y=1-x$

មាន $y=x+e^{x}\Rightarrow y'=1+e^{x}$

គេបាន $y'-y=(1+e^{x})-(x+e^{x})=1-x$ ពិត

ដូចនេះ $y = x + e^x$ ជាចម្លើយនៃសមីការ $y' - y = 1 - x$ ។

ខ. $y = e^{3x} - x - 1$ , $y' - 3y = 3x + 2$

គេមាន $y' = 3e^{3x} - 1$

គេបាន $y' - 3y = 3e^{3x} - 1 - 3e^{3x} + 3x + 3 = 3x + 2$ ពិត

ដូចនេះ $y = e^{3x} - x - 1$ ជាចម្លើយសមីការ $y' - 3y = 3x + 2$ ។

គ. $y = \sin x + \cos x$ , $y' + y = 2\cos x$

គេមាន $y' = \cos x - \sin x$

គេបាន $y' + y = \cos x - \sin x + \cos x + \sin x = 2\cos x$ ពិត

ដូចនេះ $y = \sin x + \cos x$ ជាចម្លើយសមីការ $y' + y = 2\cos x$ ។

ឃ. $y = x + \ln x$ , $xy' - y = 1 - \ln x$

គេមាន $y' = 1 + \dfrac{1}{x} \Rightarrow xy' = x + 1$

គេបាន $xy' - y = x + 1 - x - \ln x = 1 - \ln x$ ពិត

ដូចនេះ $y = x + \ln x$ ជាចម្លើយរបស់សមីការ $xy' - y = 1 - \ln x$

6.គេមានសមីការឌីផេរ៉ង់ស្យែល $(E): y'+2y = x^2$ ។

ក.កំណត់ពហុធា g មានដឺក្រេទី2 ដែលជាចំលើយពិសេសនៃ $(E)$ ។

ខ.តាង h ជាអនុគមន៍ដែល $h(x)=f(x)-g(x)$ ។ បើ h ដែលជាចំលើយពិសេសនៃសមីការឌីផេរ៉ង់ស្យែល $y'+2y = 0$ នោះបង្ហាញថា f ជាចំលើយទូរទៅនៃ $(E)$ ។

**ដំណោះស្រាយ**

ក.កំណត់ពហុធា g មានដឺក្រេទី2 ដែលជាចំលើយពិសេសនៃ $(E)$

តាង $g(x) = ax^2 + bx + c$ ជាចម្លើយរបស់សមីការ $(E)$

គេបាន $g'(x) + 2g(x) = x^2 \quad (1)$

តែ $g'(x) = 2ax + b$ នោះទំនាក់ទំនង (1) អាចសរសេរ

$2ax + b + 2(ax^2 + bx + c) = x^2$

$2ax^2 + (2a + 2b)x + b + 2c = x^2$

គេទាញ $a = \frac{1}{2}$ , $b = -\frac{1}{2}$ , $c = \frac{1}{4}$

ដូចនេះ $g(x) = \frac{1}{2}x^2 - \frac{1}{2}x + \frac{1}{4}$ ។

ខ. បង្ហាញថា f ជាចំលើយទូរទៅនៃ $(E)$ ។

មាន h ជាអនុគមន៍ដែល $h(x)=f(x)-g(x)$

បើ h ជាចំលើយពិសេសនៃសមីការឌីផេរ៉ង់ស្យែល $y'+2y = 0$

គេបាន $h'(x)+2h(x)=0$ ដោយ $h'(x)=f'(x)-g'(x)$

នោះ $f'(x)-g'(x)+2f(x)-2g(x)=0$

$$[\ f'(x)+2f(x)\ ]-[\ g'(x)+2g(x)\ ]=0 \quad (2)$$

យក (1) ជួសក្នុង (2) គេបាន

$f'(x)+2f(x)-x^2=0 \Rightarrow f'(x)+2f(x)=x^2$ ។

សម្រាយបញ្ជាក់នេះមានន័យថា បើ $h$ ជាចំលើយពិសេសនៃសមីការឌីផេរ៉ង់ស្យែល $y'+2y=0$ នោះ $f$ ជាចំលើយទូរទៅនៃ $(E)$ ។

7. គេមានសមីការឌីផេរ៉ង់ស្យែល $(E):\ y'-2y=\dfrac{-2}{1+e^{-2x}}$ ។

ក.ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $y'-2y=0$ ដែលផ្ទៀងផ្ទាត់ $y(0)=1$ ។

ខ.តាង $f$ ជាអនុគមន៍មានដេរីវេ IR ដែល $f(x)=e^{2x}g(x)$ ។

គណនា $f'(x)$ ជាអនុគមន៍នៃ $g(x)$ និង $g'(x)$ ។

គ.បង្ហាញថាបើ $f$ ជាចម្លើយនៃ $(E)$ លុះត្រាតែ $g'(x)=\dfrac{-2e^{-2x}}{1+e^{-2x}}$

ឃ.ទាញរកកន្សោម $g(x)$ រួច $f(x)$ ដែល $f$ ជាចម្លើយនៃ $(E)$ ។

## ដំណោះស្រាយ

ក.ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $y'-2y=0$ ដែលផ្ទៀងផ្ទាត់ $y(0)=1$ ៖

គេមាន $y'-2y=0 \Rightarrow y=A.e^{2x}$ ដែល $A$ ជាចំនួនថេរ

បើ $x=0 \Rightarrow y(0)=A=1$ ។

ដូចនេះ $y=e^{2x}$ ។

ខ.គណនា $f'(x)$ ជាអនុគមន៍នៃ $g(x)$ និង $g'(x)$

គេមាន $f(x)=e^{2x}g(x)$

គេបាន $f'(x)=2e^{2x}g(x)+e^{2x}g'(x)$

ដូចនេះ $f'(x)=[2g(x)+g'(x)]e^{2x}$ ។

គ.បង្ហាញថាបើ $f$ ជាចម្លើយនៃ $(E)$ លុះត្រាតែ $g'(x)=\dfrac{-2e^{-2x}}{1+e^{-2x}}$

បើ $f$ ជាចម្លើយនៃ $(E): y'-2y=\dfrac{-2}{1+e^{-2x}}$ នោះគេបាន

$f'(x)-2f(x)=\dfrac{-2}{1+e^{-2x}}$ ដោយ $f(x)=e^{2x}g(x)$

និង $f'(x)=[2g(x)+g'(x)]e^{2x}$ នោះគេបាន

$$[2g(x)+g'(x)]e^{2x}-2e^{2x}g(x)=\frac{-2}{1+e^{-2x}}$$

គេទាញ $g'(x)=\dfrac{-2e^{-2x}}{1+e^{-2x}}$ ។

ម្យ៉ាងទៀតបើ $g'(x)=\dfrac{-2e^{-2x}}{1+e^{-2x}}$

ហើយដោយ $f'(x)=[2g(x)+g'(x)]e^{2x}$ គេបាន

$$f'(x)=[2g(x)+\frac{-2e^{-2x}}{1+e^{-2x}}]e^{2x}$$

$f'(x)=2g(x)e^{2x}-\dfrac{2}{1+e^{-2x}}$ ដោយ $f(x)=g(x).e^{2x}$

$$f'(x)=2f(x)-\frac{2}{1+e^{-2x}}\Rightarrow f'(x)-2f(x)=\frac{-2}{1+e^{-2x}}$$

ដូចនេះ បើ $f$ ជាចម្លើយនៃ (E) លុះត្រាតែ $g'(x)=\dfrac{-2e^{-2x}}{1+e^{-2x}}$ ។

ឃ.ទាញរកកន្សោម $g(x)$ រួច $f(x)$ ដែល $f$ ជាចម្លើយនៃ (E)

គេមាន $g'(x)=\dfrac{-2e^{-2x}}{1+e^{-2x}}$

គេបាន $g(x)=\displaystyle\int\frac{-2e^{-2x}}{1+e^{-2x}}.dx=\int\frac{(1+e^{-2x})'}{1+e^{-2x}}.dx$

ដូចនេះ $g(x)=\ln|1+e^{-2x}|+C$ ។

ម្យ៉ាងទៀតដោយ $f(x)=g(x).e^{2x}$

ដូចនេះ $f(x)=e^{2x}.\ln(1+e^{-2x})+C.e^{2x}$ ដែល $C\in IR$ ។

៩.ដោះស្រាយសមីការឌីផេរ៉ង់ស្យែល

ក. $\frac{dy}{dx} - y = e^{3x}$ ខ. $\frac{dy}{dx} + y = \frac{1}{e^{2x}+1}$

គ. $y' + y = 1$ ឃ. $y' + y = \sin x$

**ដំណោះស្រាយ**

ដោះស្រាយសមីការឌីផេរ៉ង់ស្យែល

ក. $\frac{dy}{dx} - y = e^{3x}$

តាង $y_p = ke^{3x}$ ជាចម្លើយពិសេសនៃ $\frac{dy}{dx} - y = e^{3x}$ និង $y_e$ ជាចម្លើយនៃសមីការ $\frac{dy}{dx} - y = 0$ នោះ $y = y_e + y_p$ ជាចម្លើយទូទៅនៃសមីការ $\frac{dy}{dx} - y = e^{3x}$ ។

គេបាន $\frac{dy}{dx} - y = 0$ នាំឱ្យ $y_e = A.e^{x}$ ដែល $A \in IR$

ដោយ $y_p = ke^{3x}$ ជាចម្លើយពិសេសនៃ $\frac{dy}{dx} - y = e^{3x}$ នោះគេបាន

$\frac{dy_p}{dx} - y_p = e^{3x}$ តែ $\frac{dy_p}{dx} = 3ke^{3x}$

គេបាន $3ke^{3x} - ke^{3x} = e^{3x} \Rightarrow k = \frac{1}{2}$ ។ គេបាន $y_p = \frac{1}{2}e^{3x}$ ។

ដូចនេះ $y = A.e^{x} + \frac{1}{2}e^{3x}$ ដែល $A$ ជាចំនួនថេរ ។

ខ. $\frac{dy}{dx}+y=\frac{1}{e^{2x}+1}$

ឬ $y'+y=\frac{1}{e^{2x}+1}$

គុណអង្គទាំងពីរនឹង $e^{x}$ គេបាន

$$y'e^{x}+e^{x}y=\frac{e^{x}}{e^{2x}+1}$$

$$(ye^{x})'=\frac{e^{x}}{e^{2x}+1}\Rightarrow ye^{x}=\int\frac{e^{x}dx}{e^{2x}+1}$$

តាង $t=e^{x}\Rightarrow dt=e^{x}dx$

គេបាន $ye^{x}=\int\frac{dt}{t^{2}+1}=\arctan(t)+C$

ឬ $ye^{x}=\arctan(e^{x})+C$

ដូចនេះ $y=e^{-x}\arctan(e^{x})+C.e^{-x}$ ។

គ. $y'+y=1$ ឬ $y'+y-1=0$

តាង $z=y-1$ នោះ $z'=y'$

សមីការអាចសរសេរ $z'+z=0\Rightarrow z=A.e^{-x}$

ដោយ $z=y-1\Rightarrow y=z+1=A.e^{-x}+1$ ដែល $A\in IR$ ។

ឃ. $y'+y=\sin x$

ចម្លើយ $y=A.e^{-x}+\frac{1}{2}(\sin x-\cos x)$ ដែល $A\in IR$ ។

៩.ដោះស្រាយសមីការឌីផេរ៉ង់ស្យែលតាមលក្ខខណ្ឌដើម

ក.$y'-y=1\ ,\ y(0)=1$ ខ.$y'+2y=1\ ,\ y(0)=0$

**ដំណោះស្រាយ**

ដោះស្រាយសមីការឌីផេរ៉ង់ស្យែលតាមលក្ខខណ្ឌដើម

ក.$y'-y=1\ ,\ y(0)=1$

គេមាន $y'-y=1$

គុណអង្គទាំងពីរនឹង $e^{-x}$ គេបាន

$$y'e^{-x}-e^{-x}y=e^{-x}$$

$$(ye^{-x})'=e^{-x}$$

$$\Rightarrow ye^{-x}=\int e^{-x}dx$$

$$\Rightarrow ye^{-x}=-e^{-x}+k$$

$$\Rightarrow \quad y=-1+ke^{-x}$$

បើ $x=0$ នោះ $y(0)=-1+k=1\Rightarrow k=2$

ដូចនេះ $y=-1+2e^{-x}$ ។

ខ.$y'+2y=1\ ,\ y(0)=0$

ដោះស្រាយដូចខាងលើដែរគេបានចម្លើយរបស់សមីការគឺ

$y=\frac{1}{2}-\frac{1}{2}e^{-2x}$ ។

10.ដោះស្រាយសមីការឌីផេរ៉ង់ស្យែល

ក.$\frac{dy}{dx} = \sin 5x$ ខ.$dx + e^{3x}dy = 0$

គ.$e^{x}\frac{dy}{dx} = 2x$ ឃ.$(x+1)\frac{dy}{dx} = x+6$

**ដំណោះស្រាយ**

ដោះស្រាយសមីការឌីផេរ៉ង់ស្យែល

ក.$\frac{dy}{dx} = \sin 5x$

គេទាញ $y = \int \sin 5x.dx = -\frac{1}{5}\cos 5x + C$

ខ.$dx + e^{3x}dy = 0$

គេទាញ $y = \int e^{-3x}dx = -\frac{1}{3}e^{-3x} + C$

គ.$e^{x}\frac{dy}{dx} = 2x$

គេទាញ $y = \int 2xe^{-x}dx$

តាង $f(x) = 2x \Rightarrow f'(x) = 2$

ហើយ $g'(x) = e^{-x} \Rightarrow g(x) = \int e^{-x}.dx = -e^{-x}$

តាមរូបមន្ត $\int f(x).g'(x).dx = f(x)g(x) - \int g(x)f'(x).dx$

គេបាន $y = -2xe^{-x} + \int 2e^{-x}dx = -2xe^{-x} - 2e^{-x} + C$

ដូចនេះ $y = -2(x+1)e^{-x} + C$ ។

ឃ.$(x+1)\dfrac{dy}{dx} = x+6$

គេបាន $y = \int \dfrac{x+6}{x+1}.dx$

$$y = \int (1+\frac{5}{x+1})dx$$

$$y = x + 5\ln|x+1| + C$$

ជំពូកទី៥ មេរៀនទី២

# សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី២

## 1_សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់២

*និយមន័យ*

សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី២ អូម៉ូសែន និងមានមេគុណជាចំនួនថេរជាសមីការដែលអាចសរសេរជារាងទូទៅ $ay''+by'+cy=0$ ដែល $a\neq 0$ , $a,b,c\in IR$ ។

## ២_ដំណោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់២អូម៉ូសែន និងមានមេគុណជាចំនួនថេរ

*ក.សមីការសម្គាល់*

សមីការសម្គាល់នៃសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី២ អូម៉ូសែន និងមានមេគុណជាចំនួនថេរ $ay''+by'+cy=0$ ជាសមីការដឺក្រេទីពីរ $a\lambda^2+b\lambda+c=0$ ដែល $a\neq 0$ , $a,b,c\in IR$ ។

### ខ.វិធីដោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់២

ឧបមាថាគេមានសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់2ដូចខាងក្រោម៖

$(E): \quad y''+by'+cy=0$ ដែល $b\ ,\ c\in IR$ ។

◆សមីការ (E) មានសមីការសម្គាល់ $\lambda^2+b\lambda+c=0$ (1)

◆គណនា $\Delta=b^2-4c$

-ករណី $\Delta>0$ សមីការ (1) មានឫសពីរជាចំនួនពិតផ្សេងគ្នាគឺ $\lambda_1=\alpha$

$\lambda_2=\beta$ នោះសមីការ (E) មានចម្លើយទូទៅជាអនុគមន៍រាង

$y=A.e^{\alpha x}+B.e^{\beta x}$ ដែល A , B ជាចំនួនថេរមួយណាក៏បាន ។

-ករណី $\Delta=0$ សមីការ (1) មានឫសឌុបគឺ $\lambda_1=\lambda_2=\alpha$

នោះសមីការ (E) មានចម្លើយទូទៅជាអនុគមន៍រាង

$y=Ax.e^{\alpha x}+B.e^{\alpha x}$ ដែល A , B ជាចំនួនថេរមួយណាក៏បាន ។

-ករណី $\Delta<0$ សមីការ (1) មានឫសពីរផ្សេងគ្នាជាចំនួនកុំផ្លិចឆ្លាស់គ្នាគឺ

$\lambda_1=\alpha+i.\beta$ និង $\lambda_2=\alpha-i.\beta$ ( $\alpha\ ,\ \beta\in IR$ )

នោះសមីការ (E) មានចម្លើយទូទៅជាអនុគមន៍រាង

$y=(A\cos\beta x+B\sin\beta x)e^{\alpha x}$

ដែល A , B ជាចំនួនថេរមួយណាក៏បាន ។

## ៣_ដំណោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់២មិនអូម៉ូសែននិងមានមេគុណជាចំនួនថេរ

ឧបមាថាគេមានសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី2មិនអូម៉ូសែន

$y''+by'+cy = P(x)$ ដែល $P(x) \neq 0$ ។

ដើម្បីដោះស្រាយសមីការនេះគេត្រូវ :

◆ស្វែងរកចម្លើយពិសេសមិនអូម៉ូសែន តាងដោយ $y_P$ របស់សមីការ $y''+by'+cy = P(x)$ ដែល $y_P$ មានទម្រង់ដូច $P(x)$ ។

◆រកចម្លើយទូទៅតាងដោយ $y_c$ នៃសមីការលីនេអ៊ែលំដាប់ទី2អូម៉ូសែន $y''+by'+cy = 0$ ។

◆គេបានចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី2 មិនអូម៉ូសែនជាផលបូករវាង $y_P$ និង $y_c$ គឺ $y = y_P + y_C$ ។

## លំហាត់

1.ផ្ទៀងផ្ទាត់ថាអនុគមន៍ f ជាចម្លើយនៃសមីការឌីផេរ៉ង់ស្យែលដែលឱ្យ

ក.$f(x) = (2x+1)e^{-x}$ , $y''+2y'+y = 0$

ខ.$f(x) = e^{-x}\sin x$ , $y''+2y'+2y = 0$

គ.$f(x) = Ae^{x} + Bxe^{x}$ , $y''-2y'+y = 0$

ដែល A និង B ជាចំនួនថេរណាមួយក៏បាន ។

2. ដោះស្រាយសមីការ

ក.$2y''-3y'+y = 0$

ខ.$-4y''+7y'+2y = 0$

គ.$y''-2y' = 0$

ឃ.$y''-3y'+3y = 0$

ង.$2y''+3y'-2y = 0$

ច.$y''-3y'+y = 0$

3.ក្នុងករណីនីមួយៗខាងក្រោម គេឱ្យ f ជាអនុគមន៍កំណត់លើ IR ។ រកសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទីពីរ អូម៉ូសែនដែលមានអនុគមន៍ f ជាចម្លើយ

ក.$f(x) = (x+1)e^{-2x}$

ខ.$f(x) = 2e^{-x} + 3e^{3x}$

គ.$f(x) = (2\cos 3x - 3\sin 3x)e^{x}$

4. ដោះស្រាយសមីការឌីផេរ៉ង់ស្យែលតាមលក្ខខណ្ឌដែលឱ្យៈ

ក. $y''-y=0$ , $y(0)=1$ , $y'(0)=-2$

ខ. $y''-2y'+3y=0$ , $y(0)=2$ , $y'(0)=1$

គ. $y''+y=0$ , $y(\frac{\pi}{2})=3$ , $y'(\frac{\pi}{2})=2$

ឃ. $y''-3y'+2y=0$ , $y(0)=1$ , $y'(0)=3$ ។

5.គេមានសមីការឌីផេរ៉ង់ស្យែល $y''-4y'+2y=4$

ក.រកអនុគមន៍ថេរ $k$ ដែលជាចម្លើយពិសេសនៃ $(E)$

ខ.ដោះស្រាយសមីការ $y''-4y'+2y=4$

គ.រកចំលើយពិសេសនៃ $(E)$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌដើម

$y(0)=2\sqrt{2}$ , $y'(0)=0$ ។

## ដំណោះស្រាយ

1.ផ្ទៀងផ្ទាត់ថាអនុគមន៍ f ជាចម្លើយនៃសមីការឌីផេរ៉ង់ស្យែលដែលឱ្យ

ក.$f(x) = (2x+1)e^{-x}$ , $y''+2y'+y=0$

ខ.$f(x) = e^{-x}\sin x$ , $y''+2y'+2y=0$

គ.$f(x) = Ae^{x} + Bxe^{x}$ , $y''-2y'+y=0$

ដែល A និង B ជាចំនួនថេរណាមួយក៏បាន ។

**ដំណោះស្រាយ**

ផ្ទៀងផ្ទាត់ថាអនុគមន៍ f ជាចម្លើយនៃសមីការឌីផេរ៉ង់ស្យែល

ក.$f(x) = (2x+1)e^{-x}$ , $y''+2y'+y=0$

អនុគមន៍ $f(x) = (2x+1)e^{-x}$ ជាចម្លើយសមីការ $y''+2y'+y=0$

លុះត្រាតែ $f(x), f'(x), f''(x)$ ផ្ទៀងផ្ទាត់នឹងសមីការពោលគឺ

$f''(x)+2f'(x)+f(x)=0$ ចំពោះគ្រប់ x ។

គេមាន $f'(x) = 2e^{-x} - (2x+1)e^{-x} = (-2x+1)e^{-x}$

និង $f''(x) = -2e^{-x} - (-2x+1)e^{-x} = (2x-3)e^{-x}$

គេបាន

$$f''(x)+2f'(x)+f(x) = (2x-3-4x+2+2x+1)e^{-x} = 0$$

ដូចនេះអនុគមន៍ f ជាចម្លើយនៃសមីការឌីផេរ៉ង់ស្យែលដែលឱ្យ ។

ខ. $f(x)=e^{-x}\sin x \quad , \; y''+2y'+2y=0$

គេមាន $f'(x)=-e^{-x}\sin x+e^{-x}\cos x$

ឬ $f'(x)=-f(x)+e^{-x}\cos x \quad (1)$

ហើយ $f''(x)=-f'(x)-e^{-x}\cos x-e^{-x}\sin x$

ឬ $f''(x)=-f'(x)-e^{-x}\cos x-f(x) \quad (2)$

បូកសមីការ (1) និង (2) គេទទួលបាន

$f''(x)+f'(x)=-f'(x)-2f(x)$

ឬ $f''(x)+2f'(x)+2f(x)=0$ ។

ដូចនេះ $f(x)=e^{-x}\sin x$ ជាចម្លើយរបស់ $y''+2y'+2y=0$ ។

គ. $f(x)=Ae^{x}+Bxe^{x} \quad , \; y''-2y'+y=0$

ដែល A និង B ជាចំនួនថេរណាមួយក៏បាន ។

គេមាន $f'(x)=Ae^{x}+Be^{x}+Bxe^{x}$

និង $f''(x)=Ae^{x}+2Be^{x}+Bxe^{x}$

គេបាន $f''(x)-2f'(x)+f(x)=0$ ពិត

ដូចនេះ $f(x)=Ae^{x}+Bxe^{x}$ ជាចម្លើយរបស់សមីការឌីផេរ៉ង់ស្យែល

$y''-2y'+y=0$ ដែល A និង B ជាចំនួនថេរណាមួយក៏បាន ។

2. ដោះស្រាយសមីការ

ក. $2y''-3y'+y=0$ ខ. $-4y''+7y'+2y=0$

គ. $y''-2y'=0$ ឃ. $y''-3y'+3y=0$

ង. $2y''+3y'-2y=0$ ច. $y''-3y'+y=0$

**ដំណោះស្រាយ**

ក. $2y''-3y'+y=0$

មានសមីការសម្គាល់ $2\lambda^2-3\lambda+1=0$

ដោយ $a+b+c=0 \Rightarrow \lambda_1=1\ ;\ \lambda_2=\frac{c}{a}=\frac{1}{2}$

ដូចនេះចម្លើយទូទៅរបស់សមីការឌីផេរ៉ង់ស្យែលនេះគឺជាអនុគមន៍

$y=Ae^{x}+Be^{\frac{1}{2}x}$ ដែល A , B ជាចំនួនថេរ ។

ខ. $-4y''+7y'+2y=0$

មានសមីការសម្គាល់ $-4\lambda^2+7\lambda+2=0$

ដោយ $\Delta=49+32=9^2 \Rightarrow \lambda_1=2\ ;\ \lambda_2=\frac{c}{a}=-\frac{1}{4}$

ដូចនេះចម្លើយទូទៅរបស់សមីការឌីផេរ៉ង់ស្យែលនេះគឺជាអនុគមន៍

$y=Ae^{2x}+Be^{-\frac{1}{4}x}$ ដែល A , B ជាចំនួនថេរ ។

គ.$y''-2y'=0$

មានសមីការសម្គាល់ $\lambda^2-2\lambda=0$

គេទាញឬស $\lambda_1=0\ ;\ \lambda_2=2$

ដូចនេះចម្លើយទូទៅរបស់សមីការឌីផេរ៉ង់ស្យែលនេះគឺជាអនុគមន៍

$y=A+Be^{2x}$ ដែល A , B ជាចំនួនថេរ ។

ឃ.$y''-3y'+3y=0$

មានសមីការសម្គាល់ $\lambda^2-3\lambda+3=0$

ដោយ $\Delta=9-12=-3\Rightarrow\lambda_{1,2}=\frac{3}{2}\pm i\frac{\sqrt{3}}{2}$

គេទាញ $\alpha=\frac{3}{2}$ , $\beta=\frac{\sqrt{3}}{2}$ ។

ដូចនេះចម្លើយទូទៅរបស់សមីការឌីផេរ៉ង់ស្យែលនេះគឺជាអនុគមន៍

$y=(C\cos\frac{\sqrt{3}}{2}x+D\sin\frac{\sqrt{3}}{2}x)e^{\frac{3x}{2}}$ ដែល C , D ជាចំនួនថេរ

ង.$2y''+3y'-2y=0$

ចម្លើយ $y=Ae^{-2x}+Be^{\frac{1}{2}x}$ ដែល A , B ជាចំនួនថេរ ។

ច.$y''-3y'+y=0$

ចម្លើយ $y=Ae^{\frac{3-\sqrt{5}}{2}x}+Be^{\frac{3+\sqrt{5}}{2}x}$ ដែល A , B ជាចំនួនថេរ ។

3.ក្នុងករណីនីមួយៗខាងក្រោម គេឱ្យ f ជាអនុគមន៍កំណត់លើ IR ។ រកសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទីពីរ អូម៉ូសែនដែលមានអនុគមន៍ f ជាចម្លើយ

ក.$f(x)=(x+1)e^{-2x}$ ខ.$f(x)=2e^{-x}+3e^{3x}$

គ.$f(x)=(2\cos 3x-3\sin 3x)e^{x}$

**ដំណោះស្រាយ**

រកសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទីពី

ក.$f(x)=(x+1)e^{-2x}$

គេមាន $f'(x)=e^{-2x}-2(x+1)e^{-2x}=(-2x-1)e^{-2x}$

ហើយ $f''(x)=-2e^{-2x}-2(-2x-1)e^{-2x}$

ឬ $f''(x)=4xe^{-2x}$ ។

គេមាន $f''(x)+4f'(x)+4f(x)=(4x-8x-4+4x+4)e^{-2x}=0$

ដូចនេះ $y''+4y'+4y=0$ ជាសមីការដែលត្រូវរក ។

ខ.$f(x)=2e^{-x}+3e^{3x}$

ចម្លើយ $y''-2y'-3y=0$

គ.$f(x)=(2\cos 3x-3\sin 3x)e^{x}$

ចម្លើយ $y''-2y'+10y=0$ ។

4. ដោះស្រាយសមីការឌីផេរ៉ង់ស្យែលតាមលក្ខខណ្ឌដែលឱ្យ៖

ក. $y''-y=0$ , $y(0)=1$ , $y'(0)=-2$

ខ. $y''-2y'+3y=0$ , $y(0)=2$ , $y'(0)=1$

គ. $y''+y=0$ , $y(\frac{\pi}{2})=3$ , $y'(\frac{\pi}{2})=2$

ឃ. $y''-3y'+2y=0$ , $y(0)=1$ , $y'(0)=3$ ។

**ដំណោះស្រាយ**

ដោះស្រាយសមីការឌីផេរ៉ង់ស្យែលតាមលក្ខខណ្ឌដែលឱ្យ៖

ក. $y''-y=0$ , $y(0)=1$ , $y'(0)=-2$

មានសមីការសម្គាល់ $\lambda^2-1=0$

គេទាញឫស $\lambda_1=1$ ; $\lambda_2=-1$

ដូចនេះចម្លើយទូទៅរបស់សមីការឌីផេរ៉ង់ស្យែលនេះគឺជាអនុគមន៍

$y=Ae^x+Be^{-x}$ ហើយ $y'=Ae^x-Be^{-x}$

ដោយ $y(0)=1$ និង $y'(0)=-2$

គេបាន $\begin{cases} A+B=1 \\ A-B=-2 \end{cases}$ នាំឱ្យ $A=-\frac{1}{2}$ , $B=-\frac{3}{2}$

ដូចនេះ $y=-\frac{1}{2}e^x-\frac{3}{2}e^{-x}$ ។

ខ.$y''-2y'+3y=0$ , $y(0)=2$ , $y'(0)=1$

ចម្លើយ $y=(\cos\sqrt{2}x-\frac{\sqrt{2}}{2}\sin\sqrt{2}x)e^{x}$

គ.$y''+y=0$ , $y(\frac{\pi}{2})=3$ , $y'(\frac{\pi}{2})=2$

ចម្លើយ $y=-2\cos x+3\sin x$

ឃ.$y''-3y'+2y=0$ , $y(0)=1$ , $y'(0)=3$

ចម្លើយ $y=-e^{x}+2e^{2x}$

5.គេមានសមីការឌីផេរ៉ង់ស្យែល $y''-4y'+2y=4$

ក.រកអនុគមន៍ថេរ $k$ ដែលជាចម្លើយពិសេសនៃ $(E)$

ខ.ដោះស្រាយសមីការ $y''-4y'+2y=4$

គ.រកចំលើយពិសេសនៃ $(E)$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌដើម

$y(0)=2\sqrt{2}$ , $y'(0)=0$ ។

**ដំណោះស្រាយ**

ក.រកអនុគមន៍ថេរ $k$ ដែលជាចម្លើយពិសេសនៃ $(E)$

បើអនុគមន៍ $y=k$ ជាចម្លើយ ពិសេសនៃ $(E)$ នោះគេបាន

$(k)''-4(k)'+2k=4$

$$2k=4\Rightarrow k=2$$

ដូចនេះ $y_p=2$ ជាចម្លើយពិសេសនៃ $(E)$ ។

ខ.ដោះស្រាយសមីការ $y''-4y'+2y=4$

តាង $y_c$ ជាចម្លើយនៃ $y''-4y'+2y=0$

គេបាន $y=y_c+y_p$ ជាចម្លើយរបស់សមីការ$y''-4y'+2y=4$ ។

សមីការ $y''-4y'+2y=0$ មានសមីការសម្គាល់ $\lambda^2-4\lambda+2=0$

$\Delta'=4-2=2\Rightarrow\lambda_1=2+\sqrt{2}\ ,\ \lambda_2=2-\sqrt{2}$

គេទាញ $y=Ae^{(2+\sqrt{2})x}+Be^{(2-\sqrt{2})x}$ ។

គ.រកចំលើយពិសេសនៃ $(E)$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌដើម

គេមាន $y=Ae^{(2+\sqrt{2})x}+Be^{(2-\sqrt{2})x}$

គេបាន $y'=(2+\sqrt{2})Ae^{(2+\sqrt{2})x}+(2-\sqrt{2})Be^{(2-\sqrt{2})x}$

ដោយ $y(0)=2\sqrt{2}$ , $y'(0)=0$ នោះគេបាន

$$\begin{cases}A+B=2\sqrt{2}\\(2+\sqrt{2})A+(2-\sqrt{2})B=0\end{cases}\Rightarrow A=-2+\sqrt{2}\ ,B=2+\sqrt{2}$$

ដូចនេះ $y=(-2+\sqrt{2})e^{(2+\sqrt{2})x}+(2+\sqrt{2})e^{(2-\sqrt{2})x}$

## លំហាត់ទី១

១.ដោះស្រាយសមីការ $g''(x)-5g'(x)+6g(x)=0 \quad (E)$

២. កំនត់ចំលើយ $g(x)$ មួយនៃសមីការ $(E)$ ដែល $g(0)=0$

និង $g'(0)=1$ ។

( ប្រធានប្រឡងឆមាសទី២ឆ្នាំ២០០៤)

## ដំណោះស្រាយ

១. ដោះស្រាយសមីការ $g''(x)-5g'(x)+6g(x)=0 \quad (E)$

មានសមីការសំគាល់ $r^2-5r+6=0$

ដោយ $\Delta=25-24=1$ នាំឱ្យមានឫស

$$r_1=\frac{5-1}{2}=2 \quad ,r_2=\frac{5+1}{2}=3$$

តាមរូបមន្ត $g(x)=A.e^{r_1x}+B.e^{r_2x} \quad ,A,B\in IR$

ដូចនេះចំលើយសមីការ $g(x)=A.e^{2x}+B.e^{3x} \quad ,A,B\in IR$

២. កំនត់ចំលើយ $g(x)$ មួយនៃសមីការ $(E)$

គេមាន $g(x)=A.e^{2x}+B.e^{3x}$

នាំឱ្យ $g'(x)=2A.e^{2x}+3B.e^{3x}$

តាមបំរាប់គេមាន $\begin{cases} g(0)=0 \\ g'(0)=1 \end{cases}$ សមមូល $\begin{cases} A+B=0 \\ 2A+3B=1 \end{cases}$

នាំឱ្យ $\begin{cases} A=-1 \\ B=1 \end{cases}$

ដូចនេះ $g(x)=-e^{2x}+e^{3x}$ ។

## លំហាត់ទី២

ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E): y''-3y'+2y=0$

ដោយដឹងថា $y(0)=1$ , $y'(0)=0$ ។

## ដំណោះស្រាយ

ដោះស្រាយសមីការឌីផេរ៉ង់ស្យែលៈ

$$(E): y''-3y'+2y=0$$

មានសមីការសំគាល់ $r^2 - 3r + 2 = 0$

ដោយ $a + b + c = 0$ នាំឱ្យ $r_1 = 1 \; , r_2 = \frac{c}{a} = 2$

តាមរូបមន្ត $y = Ae^{r_1 x} + Be^{r_2 x}$ គេបាន

$y = A.e^x + B.e^{2x}$ និង $y' = A.e^x + 2B.e^{2x} \; , A, B \in IR$

ដោយតាមបំរាប់គេមាន $\begin{cases} y(0) = 1 \\ y'(0) = 0 \end{cases}$ ឬ $\begin{cases} A + B = 1 \\ A + 2B = 0 \end{cases}$

នាំឱ្យ $\begin{cases} A = 2 \\ B = -1 \end{cases}$

ដូចនេះ $y = 2e^x - e^{2x}$ ជាចំលើយសមីការ ។

## លំហាត់ទី៣

គេឱ្យសមីការឌីផេរ៉ង់ស្យែល

$(E): y'' - 4y' + 4y = 4x^2 - 24x + 34$

ក-កំនត់ចំនួនពិត $a, b$ និង $c$ ដើម្បីឱ្យ $y_P(x) = ax^2 + bx + c$ ជាចំលើយដោយពិសេសមួយរបស់សមីការ $(E)$ ។

ខ-បង្ហាញថាអនុគមន៍ $y = y_P(x) + y_c(x)$ ជាចំលើយទូទៅរបស់ $(E)$ នោះអនុគមន៍ $y_c(x)$ជាចំលើយរបស់សមីការអូម៉ូសែន $(E'): y''-4y'+4y = 0$ ។

គ-ដោះស្រាយសមីការ $(E')$រួចរកចំលើយទូទៅរបស់សមីការ $(E)$ ។

**ដំណោះស្រាយ**

ក. កំនត់ចំនួនពិត $a, b$ និង $c$

$$(E): y''-4y'+4y = 4x^2 - 24x + 34$$

ដើម្បីឱ្យអនុគមន៍ $y_P(x) = ax^2 + bx + c$ ជាចំលើយដោយពិសេសមួយរបស់សមីការ $(E)$លុះត្រតែអនុគមន៍ $y_p(x), y'_p(x)$ និង $y''_p(x)$ ផ្ទៀងផ្ទាត់នឹងសមីការ $(E)$ ។

គេបាន $(E): y''_p(x) - 4y'_P(x) + 4y_p(x) = 4x^2 - 24x + 34$

ដោយ $\begin{cases} y_P(x) = ax^2 + bx + c \\ y'_p(x) = 2ax + b \\ y''_p(x) = 2a \end{cases}$

គេបាន

$$(2a)-4(2ax+b)+4(ax^2+bx+c)=4x^2-24x+34$$

នាំឱ្យ

$$4ax^2+(4b-8a)x+(2a-4b+4c)=4x^2-24x+34$$

គេទាញបាន $\begin{cases}4a=4\\4b-8a=-24\\2a-4b+4c=34\end{cases}$ នាំឱ្យ $\begin{cases}a=1\\b=-4\\c=4\end{cases}$

ដូចនេះ $a=1\ \ ,b=-4\ \ ,c=-4$

និង $y_P(x)=x^2-4x+4=(x-2)^2$ ។

ខ-ការបង្ហាញ

អនុគមន៍ $y=y_P(x)+y_c(x)$ ជាចំលើយរបស់ $(E)$

លុះត្រាអនុគមន៍ $y, y', y''$ ផ្ទៀងផ្ទាត់សមីការ$(E)$ ។

ដោយគេមាន $y'=y'_p(x)+y'_c(x)$

និង $y''=y''_p(x)+y''_c(x)$ នោះគេបាន :

$$\left[y''_p + y''_c\right] - 4\left[y'_p + y'_c\right] + 4\left[y_p + y_c\right] = 4x^2 - 24x + 34$$

$$\left[y''_p - 4y'_p + 4y_p\right] + \left[y''_c - 4y'_c + 4y_c\right] = 4x^2 - 24x + 34 \quad (1)$$

តាមសម្រាយខាងលើគេមាន

$$y''_p(x) - 4y'_P(x) + 4y_p(x) = 4x^2 - 24x + 34 \quad (2)$$

( ព្រោះ $y_p(x)$ ជាចំលើយរបស់សមីការ $(E)$ ) ។

តាមទំនាក់ទំនង ( 1 ) និង ( 2) គេទាញបាន :

$$4x^2 - 24x + 34 + \left[y''c - 4y'_c + 4y_c\right] = 4x^2 - 24x + 34$$

នាំឱ្យគេទាញបាន $y''_c(x) - 4y'_c(x) + 4y_c(x) = 0$

ទំនាក់ទំនងនេះបញ្ជាក់ថាអនុគមន៍ $y_h(x)$ ជាចំលើយរបស់

សមីការ $(E'): y'' - 4y' + 4y = 0$ ។

គ-ដោះស្រាយសមីការ $(E'): y'' - 4y' + 4y = 0$

សមីការសំគាល់ $r^2 - 4r + 4 = 0$ , $\Delta' = 4 - 4 = 0$

នាំឱ្យសមីការមានឫសឌុប $r_1 = r_2 = r_0 = 2$

ដូចនេះចំលើយសមីការ $(E')$ ជាអនុគមន៍

$y_c(x) = (Ax + B).e^{2x} \quad , A, B \in IR$ ។

ទាញរកចំលើយទូទៅរបស់សមីការ $(E)$:

តាមសំរាយខាងលើចំលើយសមីការ $(E)$ គឺជាអនុគមន៍ទំរង់

$y = y_p(x) + y_c(x)$

ដោយគេមាន $y_p(x) = (x-2)^2$ និង $y_c(x) = (Ax + B).e^{2x}$

ដូចនេះ $y = (x-2)^2 + (Ax + B).e^{2x} \quad , A, B \in IR$

ជាចំលើយរបស់សមីការ $(E)$ ។

## លំហាត់ទី៤

គេឱ្យសមីការឌីផេរ៉ង់ស្យែល $(E): y'-4y=-4x^2+10x-6$

ក-កំនត់ចំនួនពិត $a,b$ និង $c$ ដើម្បីឱ្យ $y_P(x)=ax^2+bx+c$

ជាចំលើយដោយពិសេសមួយរបស់សមីការ $(E)$ ។

ខ-បង្ហាញថាអនុគមន៍ $y=y_P(x)+y_h(x)$ ជាចំលើយទូទៅរបស់

$(E)$ នោះអនុគមន៍ $y_h(x)$ ជាចំលើយរបស់សមីការអូម៉ូសែន

$(E'): y'-4y=0$ ។

គ-ដោះស្រាយសមីការ $(E')$ រួចរកចំលើយទូទៅរបស់សមីការ $(E)$ ។

## ដំណោះស្រាយ

ក- កំនត់ចំនួនពិត $a,b$ និង $c$

$$(E): y'-4y=-4x^2+10x-6$$

ដើម្បីឱ្យអនុគមន៍ $y_P(x)=ax^2+bx+c$ ជាចំលើយពិសេស

មួយរបស់សមីការ $(E)$ លុះត្រាតែអនុគមន៍

$y_p(x), y'_p(x)$ និង $y''_p(x)$ ផ្ទៀងផ្ទាត់នឹងសមីការ $(E)$ ។

គេបាន $(E): y'_P(x) - 4y_p(x) = -4x^2 + 10x - 6$

ដោយ $\begin{cases} y_P(x) = ax^2 + bx + c \\ y'_p(x) = 2ax + b \end{cases}$

គេបាន $(2ax + b) - 4(ax^2 + bx + c) = -4x^2 + 10x - 6$

នាំឱ្យ $-4ax^2 - (4b - 2a)x + (b - 4c) = -4x^2 + 10x - 6$

គេទាញបាន $\begin{cases} -4a = -4 \\ 4b - 2a = -10 \\ b - 4c = -6 \end{cases}$ នាំឱ្យ $\begin{cases} a = 1 \\ b = -2 \\ c = 1 \end{cases}$

ដូចនេះ $a = 1 \ , b = -2 \ , c = 1$

និង $y_P(x) = x^2 - 2x + 1 = (x - 1)^2$ ។

ខ-ការបង្ហាញ

អនុគមន៍ $y = y_P(x) + y_h(x)$ ជាចំលើយរបស់ $(E)$

លុះត្រាអនុគមន៍ $y, y'$ ផ្ទៀងផ្ទាត់សមីការ$(E)$ ។

ដោយគេមាន $y' = y'_p(x) + y'_h(x)$ នោះគេបាន ៖

$$\left[y'_p(x)+y'_h(x)\right]-4\left[y_p(x)+y_h(x)\right]=-4x^2+10x-6$$

$$\left[y'_p(x)-4y_p(x)\right]+\left[y'_h(x)-4y_h(x)\right]=-4x^2+10x-6 \quad (1)$$

តាមសម្រាយខាងលើគេមាន

$$y'_P(x)-4y_p(x)=-4x^2+10x-6 \quad (2)$$

( ព្រោះ $y_p(x)$ ជាចំលើយរបស់សមីការ $(E)$ ) ។

តាមទំនាក់ទំនង (1) និង (2) គេទាញបាន :

$$-4x^2+10x-6+\left[y'_h(x)-4y_h(x)\right]=-4x^2+10x-6$$

នាំឱ្យគេទាញបាន $y'_h(x)-4y_h(x)=0$ ។

ទំនាក់ទំនងនេះបញ្ជាក់ថាអនុគមន៍ $y_h(x)$ ជាចំលើយរបស់

សមីការ $(E'): y'-4y=0$ ។

គ-ដោះស្រាយសមីការ $(E'): y'-4y=0$

ដោយ $a=4$ ដូចនេះចំលើយសមីការ $(E')$ ជាអនុគមន៍

$$y_h(x)=k.e^{4x} \quad ,k\in IR$$ ។

ទាញរកចំលើយទូទៅរបស់សមីការ (E):

តាមសំរាយខាងលើចំលើយសមីការ (E) គឺជាអនុគមន៍ទំរង់

$$y = y_p(x) + y_h(x)$$

ដោយគេមាន $y_p(x) = (x-1)^2$ និង $y_h(x) = k.e^{4x}$

ដូចនេះ $y = (x-1)^2 + k.e^{4x} \quad , k \in IR$ ។